# ខ្មែរ

# 高棉

# Khmer



8/2014 NO.35

ISSN 2095-249X

9 772095 249114 08

ខ្មែរ 高棉 8/2014 NO.35

# 读《高棉》看中国

中柬友谊的桥梁　文化交流的纽带　友好往来的使者　经贸合作的平台

# អានទស្សនាវដ្ដី "ខ្មែរ" ទស្សនាប្រទេសចិន




**主管：** 中华人民共和国国务院新闻办公室　**主办：** 云南省人民政府新闻办公室　**编辑出版：** 《高棉》杂志社

**社址：** 中国云南省昆明市[illegible]路[illegible]号　**邮编：** [illegible]　**E-mail：** magazinekh[illegible]@163.com

**编辑部电话：** 86 871 64[illegible]81311（传真）　**办公室电话：** 86 871 64[illegible]　**发行部电话：** 86 871 6410[illegible]

# KAI WAH PLAZA INTERNATIONAL HOTEL

KUNMING

佳华广场酒店

★★★★★

中国 · 昆明



The Kai Wah Plaza International Hotel is located in the city center of Kunming, the "Spring City" of China. The property offers spectacular views of both the city and surrounding mountains. Located only 15 minutes from Kunming International Airport, this hotel is the ideal venue to organize your corporate stay, conference, tour, exhibition, or other social events. This 5 star property is the only hotel in Kunming with a western General Manager. The hotel has 525 elegant guest rooms, including 163 suites. The Kai Wah Tower Floors are our exclusive new facilities, guaranteeing maximum convenience to the discerning traveler. The hotel's meeting facilities are the best among the most extensive in the city and boast an 880 square meter ballroom.

KAI WAH PLAZA INTERNATIONAL HOTEL









TEL:86-871-3562828
FAX:86-871-3561818
No.157 Beijing Road,Kunming,China
Website:http://www.kaiwahplaza.com

# 云南建工集团有限公司

## ក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CO.,

云南建工集团有限公司是在云南建工集团总公司基础上，于2009年11月6日改制而成。目前，集团已发展成为集工程总承包、房地产开发、城市建设投资开发、建筑工程施工、机电设备安装、商品混凝土生产、路桥市政工程施工、钢结构工程施工、水利水电工程施工、地基工程施工、建材与设备供销、建筑科研、勘察设计、建筑劳务于一体的多层次大型企业集团；是云南省政府国资委履行出资人职责的20户省管企业和15户省属重要骨干企业之一。集团现有全资子公司、控股公司和直管企事业单位31个；现有在职职工16000人，各类专业技术人员7797人，其中具有高级职称751人。

近年来，集团努力进行结构调整，千方百计拓展市场，综合实力显著增强，为云南的经济建设和社会发展做出了显著贡献。2013年完成总产值434.23亿元，完成竣工面积828.1万平方米。科技水平显著提高，国际市场的开拓能力不断增强。截至2013年12月，集团累计获得全国建筑工程鲁班奖22项，国家优质工程银质奖32项，詹天佑土木工程大奖提名奖1项，全国用户满意工程13项，全国和省级以上科技进步奖400多项，获部省级优质工程奖390项，连续9次入选中国承包商60强。截至2013年9月，集团公司连续22次入选中国企业500强。集团先后在也门、南非、泰国、老挝、乌干达、伊拉克、马尔代夫、毛里求斯、赤道几内亚、柬埔寨等国家承接各类工程，并荣获老挝政府颁发的“发展勋章”、“劳动勋章”等荣誉。2010年至2013年，集团公司连续四年进入美国《工程新闻记录》（ENR）杂志全球最大225家国际承包商排行榜，创造了良好的国际声誉。集团以高效、优质的服务和重合同、守信用的严谨作风，赢得了广大客户、行业主管部门、金融机构的充分信赖，连年被评为AA级企业，享有较高的商誉，“云南建工”品牌已经成为国内建筑业界的知名品牌。

在实现较快发展的基础上，集团全力加快战略转型的步伐，加快企业的股份制改造，将集团进一步发展成拥有设计、科研、施工、咨询、投融资建设一体化发展能力的核心竞争力更强的现代大型建筑企业集团和中国西部一流建工集团。

ក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CO., LTD. (YCEG) គឺជាក្រុមហ៊ុនមួយដែលត្រូវបានបង្កើតឡើងដោយកែសម្រួលរចនាសម្ព័ន្ធពីក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CORPORATION នៅថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០០៩ ។ សព្វថ្ងៃ ក្រុមហ៊ុននេះបានក្លាយជាក្រុមហ៊ុនគ្រុបខ្នាតធំដែលប្រមូលផ្តុំនូវមុខងារចម្រុះ ដូចជាម៉ៅការធ្វើវិស្វកម្ម អភិវឌ្ឍន៍អចលនវត្ថុ វិនិយោគនិងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធក្នុងទីក្រុង អនុវត្តការសាងសង់ដំឡើងគ្រឿងបរិក្ខារអគ្គិសនី ផលិតបេតុង សាងសង់ស្ពាននិងផ្លូវថ្នល់ អនុវត្តវិស្វកម្មគ្រោងដែកថែប អនុវត្តវិស្វកម្មធារាសាស្ត្រនិងវារីអគ្គិសនី អនុវត្តការសាងសង់គ្រឹះ អគារលក់ដូរសម្ភារៈសំណង់និងបរិក្ខារស្រាវជ្រាវអំពីវិទ្យាសាស្ត្រស្ថាបត្យកម្មគូរប្លង់ខាងស្ថាបត្យកម្ម និងផ្តល់ពលកម្មសាងសង់ជាដើម ។វាជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនទាំង ២០ ដែលមានគណៈកម្មាធិការគ្រប់គ្រងទ្រព្យសម្បត្តិជាតិខេត្តយូណានជាអ្នកវិនិយោគនិងជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនសំខាន់ទាំង ១៥ នៃខេត្តយូណាន ។ បច្ចុប្បន្ន ក្រុមហ៊ុន YCEG មានសាខាក្រុមហ៊ុនកាន់កាប់ភាគហ៊ុននិងអង្គភាពក្រោមចំណុះផ្ទាល់ចំនួន ៣១ និងមានបុគ្គលិកការងារ ១៦០០០ នាក់ អ្នកបច្ចេក-ទេសចំនួន ៧៧៩៧ នាក់ ព្រមទាំងអ្នកជំនាញការចំនួនជាង ៧៥១ រូប ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ក្រុមហ៊ុន YCEG បានខិតខំកែសម្រួលរចនាសម្ព័ន្ធពង្រីកទីផ្សារដោយពេញទំហឹង ដែលបានធ្វើឱ្យក្រុមហ៊ុនមានសមត្ថភាពចម្រុះកាន់តែខ្លាំងឡើងៗ និងបានចូលរួមចំណែកជាច្រើនក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនិងសង្គមកិច្ចនៃខេត្តយូណាន ។ នៅឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានសម្រេចផលិតកម្មតម្លៃសរុប ៤៣៤២៣ លានយាន់ប្រាក់ចិន និងបានបញ្ចប់ការសាងសង់ជាស្ថាពរ ដែលមានទំហំសរុប ៨,២៨១ លានម៉ែត្រការ៉េ ។ អាស្រ័យលើនេះ ក្រុមហ៊ុន YCEG មានកម្រិតបច្ចេកទេសវិទ្យាសាស្ត្រកាន់តែខ្ពស់ឡើងនិងមានសមត្ថភាកាន់តែខ្លាំងសម្រាប់ពង្រីកទីផ្សារអន្តរជាតិ ។ គិតមកទល់ខែធ្នូ ឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានទទួលនូវរង្វាន់វិស្វកម្មស្ថាបត្យកម្មលូបាន ថ្នាក់ជាតិចំនួន ២២ រង្វាន់ប្រាក់វិស្វកម្មគុណភាពខ្ពស់ចំនួន ៣២ រង្វាន់លើកឈ្មោះនៃរង្វាន់វិស្វកម្មសាងសង់ ចានធានអ៊ីវ ចំនួន ១ រង្វាន់វិស្វកម្មទទួលការពេញចិត្តពីអាតិថិជនទូទាំងប្រទេសចំនួន ១៣ រង្វាន់រីកចម្រើនខាងវិទ្យាសាស្ត្រថ្នាក់ជាតិនិងថ្នាក់ខេត្តចំនួនជាង ៤០០ និងរង្វាន់វិស្វកម្មគុណភាពខ្ពស់ថ្នាក់ខេត្ត និងថ្នាក់ក្រសួងចំនួន ៣៩០ ព្រមនិងបានត្រូវជ្រើសរើសជាក្រុមហ៊ុនម៉ៅការខ្លាំងទាំង ៦០ របស់ប្រទេសចិន ៩ លើកជាប់គ្នា ។ គិតមកទល់ខែកញ្ញា ឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានជាប់ឈ្មោះជាសហគ្រាសខ្លាំងទាំង ៥០០ របស់ចិន ២២ លើកជាប់គ្នា ។ ក្រុមហ៊ុន YCEG ធ្លាប់បានទទួលបន្ទុកធ្វើវិស្វកម្មគ្រប់ប្រភេទនៅប្រទេសច្រើនលើពិភពលោកដែលរួមមានប្រទេសយ៉េមែន អាហ្វ្រិកខាងត្បូង ថៃ ឡាវ អ៊ូហ្គង់ដា អ៊ីរ៉ាក់ ម៉ាល់ឌីវ ម៉ូរីស ហ្គីណេអេក្វាទ័រនិងកម្ពុជាជាដើម ។ មិនតែប៉ុណ្ណោះ ក្រុមហ៊ុន YCEG ក៏បានទទួលមេដាយអភិវឌ្ឍន៍ មេដាយពលកម្ម និងកិត្តិយសមួយចំនួនទៀតពីរដ្ឋាភិបាលឡាវដែរ ។ ក្នុងអំឡុងពេលពីឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៣ ក្រុមហ៊ុន YCEG បានត្រូវដាក់បញ្ចូលក្នុងបញ្ជីក្រុមហ៊ុនម៉ៅការអន្តរជាតិធំជាងគេទាំង ២២៥ លើពិភពលោកក្នុងទស្សនាវដ្តី“កំណត់ហេតុអំពីព័ត៌មានវិស្វកម្ម”(ENR)របស់សហរដ្ឋអាមេរិកក្នុងរយៈពេល ៤ ឆ្នាំជាប់ ដែលបានធ្វើឱ្យក្រុមហ៊ុនមានកិត្តិនាមល្អប្រសើរលើឆាកអន្តរជាតិ ។ ជារួម ក្រុមហ៊ុន YCEG បានទទួលនូវការជឿទុកចិត្តយ៉ាងពេញលេញពីសំណាក់អាតិថិជនស្ថាប័នគ្រប់គ្រងនិងគ្រឹះស្ថានហិរញ្ញវត្ថុ ដោយផ្អែកលើសេវាកម្ម ដែលមានគុណភាពនិងប្រសិទ្ធភាពខ្ពស់ ព្រមទាំងរចនាបថស្មោះត្រង់ ។ ជាពិសេស ក្រុមហ៊ុន YCEG បានត្រូវបោះឆ្នោតជ្រើសរើសជាសហគ្រាសថ្នាក់ AA ជាច្រើនជាប់និងមានឈ្មោះល្បីខាងពាណិជ្ជកម្ម ដោយបានធ្វើឱ្យ “YCEG” (ក្រុមហ៊ុនស្ថាបត្យកម្មយូណាន)ក្លាយជាម៉ាកល្បីឈ្មោះមួយលើវិស័យស្ថាបត្យកម្មក្នុងប្រទេសចិន ។

ដោយឈរលើមូលដ្ឋានរីកចម្រើនយ៉ាងឆាប់រហ័ស ក្រុមហ៊ុន YCEG បានផ្តោតការយកចិត្តទុកដាក់លើការពន្លឿនដំណើរផ្លាស់ទម្រង់ជាយុទ្ធសាស្ត្រ ជំរុញការកែទម្រង់សហគ្រាសទៅជារបបភាគហ៊ុន ដើម្បីកសាងក្រុមហ៊ុន YCEG ឱ្យទៅជាសហគ្រាសស្ថាបត្យកម្មទំនើបខ្នាតធំ ដែលមានសមត្ថភាពចម្រុះខ្លាំងក្លាដោយប្រមូលផ្តុំនូវការគូរប្លង់ស្រាវជ្រាវវិទ្យាសាស្ត្រអនុវត្តការសាងសង់ពិគ្រោះយោបល់និងធ្វើវិនិយោគ ព្រមនិងជាសហគ្រាសស្ថាបត្យកម្មលំដាប់ថ្នាក់លេខ ១ នៅតំបន់ខាងលិចប្រទេសចិន ។



**អ្នកគ្រប់គ្រងទូទៅ :** ការិយាល័យព័ត៌មាននៃក្រុមប្រឹក្សាកិច្ចការរដ្ឋ សាធារណរដ្ឋប្រជាមានិតចិន
**អ្នករៀបចំ :** ការិយាល័យព័ត៌មានសាលាខេត្តយូណាន
**អ្នកជួយរៀបចំ :** ក្រុមហ៊ុន YUNNAN CONSTRUCTION ENGINEERING GROUP CO., LTD.
**អ្នករៀបរៀងនិងបោះពុម្ពផ្សាយ :** ទីភ្នាក់ងារទស្សនាវដ្ដី "ខ្មែរ"
**អគ្គទីប្រឹក្សា :** ZHAO JIN MAOWENGUO
**ទីប្រឹក្សា :** YANG WENHU XUAN YUCAI CAI CHUNSHENG ZHANG RUICAI LI LIANBIN LIU RONG
**នាយកទីភ្នាក់ងារ :** LI QIAN
**នាយករង :** GUO JIANCHU WU JINGBO TIAN HUQING HAIJIANG
**អគ្គនិពន្ធនាយក :** YANG YUN
**ប្រធានការិយាល័យនិពន្ធទូទៅ :** YU ZHENGYU
**ប្រធានការិយាល័យផ្នែកនិពន្ធ :** LI KE
**អ្នកនិពន្ធភាសាចិន :** LI QIUJU
**អ្នកនិពន្ធភាសាខ្មែរ :** YANG GUIQIONG SHEN YAN LIU RONG
**អ្នកពិនិត្យការបកប្រែ :** LU YUCHU ស្វាយ ណារិន
**អ្នកពិនិត្យនិងសម្រួលការបកប្រែ(ជនជាតិខ្មែរ) :** ស៊ីឡេង
**បកប្រែ :** វិទ្យាស្ថានភាសាអាស៊ីអាហ្វ្រិកនៃសកលវិទ្យាល័យភាសាបរទេសប៉េកាំង LIXUANZHI
**រចនារូបភាព :** LIU FAN
**អ្នកត្រួតពិនិត្យប្រព័ន្ធបណ្ដាញ :** ZHANG SHOUYI
**ជំនួយការ :** ZHANG JUNHONG
**អនុប្រធានផ្នែកប្រព័ន្ធបណ្ដាញ :** LI TAO
**អ្នករៀបរៀងប្រព័ន្ធបណ្ដាញ :** LI WENJUN
**បោះពុម្ពផ្សាយ :** ZOU HEPING CHEN LONG
**អ្នកចូលរួមការរៀបរៀង :** LU RUI WANG WEIYUN
**អាស័យដ្ឋាន :** ផ្ទះលេខ ៥៧៧ ផ្លូវហួនឈឹងស៊ី ទីក្រុងគុនមិញ ខេត្តយូណាន ប្រទេសចិន
**លេខកូដប្រៃសណីយ៍ :** ៦៥០០៣៤
**លេខទូរស័ព្ទនិងទូរសារផ្នែកនិពន្ធ :** ៨៦-៨៧១-៦៤១៨១៦១១
**លេខទូរស័ព្ទការិយាល័យ :** ៨៦-៨៧១-៦៤១០១៦៤៤
**អ៊ីម៉ែល :** magazinekh@163.com
**វេបសាយ :** http://www.yunnangateway.com
**អាសយដ្ឋាននៃទីស្នាក់ការអ្នកយកព័ត៌មានប្រចាំនៅរាជធានីភ្នំពេញរបស់ទស្សនាវដ្ដី"ខ្មែរ" :**
ផ្ទះលេខ ១៥ ផ្លូវ ៦០៤ សង្កាត់បឹងកក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
**ទូរស័ព្ទលេខ :** ០០៨៥៥-០១២៩៨២០៦៥
**ទូរសារលេខ :** ០០៨៥៥-០២៣៨៨៤០២៨
**លេខទូរស័ព្ទផ្នែកបោះពុម្ពផ្សាយ :** ៨៦-៨៧១-៦៤១០១៧២៧
**ក្របខ័ណ្ឌនៃការចែកចាយ :** បោះពុម្ពផ្សាយនិងចែកចាយជាសាធារណៈនៅក្នុង និងក្រៅប្រទេសចិន
**លេខកូដបោះពុម្ពផ្សាយតាមប្រៃសណីយ៍ :** ៦៤-៣៧
**ថ្ងៃ-ខែ-ឆ្នាំបោះពុម្ពផ្សាយ :** ថ្ងៃទីមួយប្រចាំខែ
**លេខស្តង់ដារអន្តរជាតិ :** ISSN 2095-249X
**លេខក្នុងប្រទេសចិន :** CN 53-1219/C
**លេខអាជ្ញាប័ណ្ណផ្សាយពាណិជ្ជកម្ម :** ៥៣០០០០៤០០០០៩៤
**បោះពុម្ពដោយ :** រោងបោះពុម្ពចូលីង ទីក្រុងគុនមិញ
**តម្លៃកំណត់ :** ១៥ យាន់(ប្រាក់ចិន)


ទឹកជ្រោះជីវឡុងនៅស្រុកឡភីង
罗平九龙瀑布　刘恩鸿 摄

主管：中华人民共和国国务院新闻办公室
主办：云南省人民政府新闻办公室
协办：云南建工集团有限公司
编辑出版：《高棉》杂志社

总顾问：赵　金　卯稳国
顾问：杨文虎　宣宇才　蔡春生　张瑞才
李联斌　刘　荣
社长：李　茜
副社长：郭建初　吴静波　田虎青　海　江
总编辑：杨　云
总编室主任：禹正玉
编辑总监：李　可
中文编辑：李秋菊
柬文编辑：杨桂琼　沈　燕　刘　蓉
译审：陆禹初　Svay Narin
外籍审稿：SY LENG
翻译：北京外国语大学亚非学院　李轩志
美术设计：刘　帆
网络总监：张守义
总监助理：张俊宏
网络部副主任：李　涛
网络编辑：李文君
发行：邹和平　陈　龙
编务：陆　蕊　汪伟云

社址：中国云南省昆明市环城西路577号
邮编：650034
编辑部电话：86-871-64181611（传真）
办公室电话：86-871-64101644
E-mail：magazinekh@163.com
http：//www.yunnangateway.com
金边记者站：柬埔寨王国金边市堆谷区万谷湖一分区604路15号
电话：00855-012982065　023884028（传真）

发行部电话：86-871-64101727
发行范围：国内外公开发行
邮发代号：64-37
出版日期：每月1日
国际标准刊号：ISSN 2095-249X
国内统一刊号：CN 53-1219/C

广告经营许可证号：5300004000094
印刷：昆明卓林包装印刷有限公司
定价：15元（人民币）

# មាតិកា 目 录




## 06 អត្ថបទពិសេសប្រចាំលេខនេះ 本期特稿

06 វប្បធម៌ចិនជាដួងព្រលឹងរួមរបស់កូនចៅចិនទាំងក្នុងនិងក្រៅប្រទេសចិន
10 កំណែទម្រង់របស់ចិន កាលានុវត្តភាពនៃពិភពលោក



## 14 ប្រទេសចិនបច្ចុប្បន្ន 今日中国

14 ទេសចរចិនមានសារៈសំខាន់ចំពោះពិភពលោកទាំងមូល
18 ព្រែកជីកយក្សនិងផ្លូវសូត្ររបស់ប្រទេសចិនត្រូវបានចុះបេតិកភ័ណ្ឌពិភពលោក
22 ណាននីង បើកទូលាយកាន់តែស៊ីជម្រៅ កាន់តែមានទំនុកចិត្តលើខ្លួនឯង



## 24 សុបិនចិន 中国梦

24 ច្រកអន្តរជាតិផ្លូវដែក ធានហ៊ី ក្រុងក្វាងចូវ
26 ច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទីង
28 ច្រកអន្តរជាតិផ្លូវគោក ឆាងយាន់
30 កសាងទីក្រុងស្រែចំការទំនើបកម្ម លើកស្ទួយកម្រិតជីវភាពរស់នៅនិងសម្រេចសុបិនរបស់ប្រជាជន



## 32 ចំណាប់អារម្មណ៍អំពីអាស៊ាន 聚焦东盟

32 សហគមន៍ចិននិងអាស៊ានជំរុញដល់ការអភិវឌ្ឍន៍និងស្ថិរភាពក្នុងតំបន់
36 តំបន់ពាណិជ្ជកម្មសេរីជំរុញការអភិវឌ្ឍវិស័យចរាចរណ៍ទំនិញឆ្លងដែនរវាងប្រទេសចិននិងអាស៊ាន
38 ប្រទេសចិននិងកម្ពុជាមាននិស្ស័យជ្រាលជ្រៅ ផ្លាស់ប្ដូរនិងរៀនសូត្រពីគ្នាទៅវិញទៅមកច្រើនអនេក



## 40 ច្រកទ្វារនៃខេត្តយូណាន 云南之窗

40 យូស៊ីដ៏ស្រស់ស្អាតបង្ហាញពីជីវិតដ៏សុភមង្គល
44 លោហធាតុមានពណ៌នាំមុខផ្នែក"យុគសម័យលោហធាតុមិនមែនដែក"
46 ខេត្តយូណានលើចុងអណ្ដាត សុរាស្ដេចបុរាណយូណាន



## 48 ក្រុងនិទាឃរដូវដ៏ស្រស់ស្អាត ក្រុងគុនមីងដ៏មានសុភមង្គល 美丽春城 幸福昆明

48 ក្រុងគុនមីងបោះជំហានយ៉ាងក្លៀវក្លាទៅកាន់តំបន់អាស៊ីខាងត្បូង
50 ផ្សារលក់ផ្កា តូវណាន នៅក្រុងគុនមីង



## 52 កម្លាំងទាក់ទាញនៃប្រទេសកម្ពុជា 魅力柬埔寨

52 មនោសញ្ចេតនាចំពោះស្វាយរបស់ប្រជាជនកម្ពុជា



## 56 ទេសចរណ៍ 旅游

56 ភ្នំថៃហាង



## 58 ប្រវត្តិសាស្ត្រនិងវប្បធម៌ 历史文化

58 វិហារវិញ្ញូកខុងជឺនៅក្រុងអានស៊ុន ខេត្តគុយចូវ



## 60 ប្រពៃណីទំនៀមទម្លាប់ប្រជាជន 民族风情

60 ពិធីបុណ្យចម្រៀងរបស់ជនជាតិប៉ៃនៅភ្នំសីប៉ាវ



## 62 ការសិក្សាភាសាចិន 学汉语

62 ចំណេះដឹងមូលដ្ឋាន(៣៥)



# វប្បធម៌ចិនជាដួងព្រលឹងរួមរបស់កូនចៅចិនទាំងក្នុងនិងក្រៅប្រទេសចិន



ឯកឧត្តមស៊ី ជីនភីង ប្រធានាធិបតីចិនថ្លែងសុន្ទរកថាសំខាន់
中国国家主席习近平发表重要讲话 cnsphoto

## 中华文化是海内外中华儿女共同的魂

中国国家主席习近平于2014年6月6日在北京会见第七届世界华侨华人社团联谊大会代表，并发表重要讲话。他强调，团结统一的中华民族是海内外中华儿女共同的根，博大精深的中华文化是海内外中华儿女共同的魂，实现中华民族伟大复兴是海内外中华儿女共同的梦。（翟茜茜 译）

នៅថ្ងៃទី ៦ ខែមិថុនា ឆ្នាំ ២០១៤ នៅក្រុងប៉េកាំង ឯកឧត្តមស៊ី ជីនភីង ប្រធានាធិបតីចិនបានជួបប្រាស្រ័យជាមួយនឹងតំណាងនៃមហាមីទីងមិត្តភាពនៃសមាគមអាណិកជនចិននិងជនជាតិចិនលើពិភពលោកលើកទី ៧ ព្រមនិងថ្លែងសុន្ទរកថាគន្លឹះ ។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ប្រជាជាតិដែលសាមគ្គីគ្នានិងបង្រួបបង្រួមជាឫសគល់រួមរបស់កូនចៅចិនទាំងក្នុងនិងក្រៅប្រទេស ការសម្រេចបាននូវការងើបឡើងវិញដ៏មហិមារបស់ប្រជាជាតិចិនជាសុបិនរួមរបស់កូនចៅចិនទាំងក្នុងនិងក្រៅប្រទេស ។ ឫសគល់ពីដូនតាធ្វើឱ្យយើងមានមនោសញ្ចេតនា



ឯកឧត្តមស៊ី ជីនភីង ប្រធានាធិបតីចិន ជួបប្រាស្រ័យជាមួយនឹងតំណាងនៃមហាមីទីងមិត្តភាពនៃសមាគមអាណិកជនចិននិងជនជាតិចិនលើពិភពលោកលើកទី ៧
中国国家主席习近平会见第七届世界华侨华人社团联谊大会代表 新华社 图



ទិដ្ឋភាពនៃមហាមីទីង
大会现场 cnsphoto




មហាមីទីងមិត្តភាពនៃសមាគមអាណិកជនចិននិងជនជាតិចិនលើពិភពលោកលើកទី ៧ ប្រារព្ធធ្វើនៅក្រុងប៉េកាំង
第七届世界华侨华人社团联谊大会在北京举行 cnsphoto

ជ្រាលជ្រៅ ដួងព្រលឹងរួមនេះធ្វើឱ្យយើងមានដួងចិត្តផ្សារជាប់គ្នា សុបិនរួមធ្វើឱ្យយើងរួមចិត្តរួមថ្លើម យើងមុខជាអាចចារទំព័រថ្មីក្នុងយុគសម័យនៃការអភិវឌ្ឍន៍ប្រជាជាតិចិនជាក់ជាពុំខាន ។

ឯកឧត្តមស៊ី ជីនភីង បានថ្លែងថា ពាក្យបុរាណចិនមួយឃ្លាពោលថា ពេលអ្នកស្រុកកំណើតជួបមុខគ្នាតែងតែរំភើបចិត្តរហូតដល់ស្រក់ទឹកភ្នែក រូបខ្ញុំក៏ដូច្នេះដែរ ពេលជួបជាមួយអ្នកទាំងអស់គ្នា ខ្ញុំមានអារម្មណ៍ស្និទ្ធស្នាលណាស់ ។ នៅគ្រប់តំបន់លើពិភពលោក មានអាណិកជននិងជនរួមជាតិចិននៅឯនាយសមុទ្រពីមួយជំនាន់ទៅមួយជំនាន់បានទទួលនិងបន្តផ្សព្វផ្សាយទំនៀមទម្លាប់ប្រពៃណីដ៏ល្អអស្ចារ្យរបស់ប្រជាជាតិចិន មិនបំភ្លេចមាតុប្រទេស មិនបំភ្លេចអត្តសញ្ញាណរបស់បុព្វបុរស មិនបំភ្លេចខ្លួនជាកូនចៅចិន បានសកម្មផ្តល់ការគាំទ្រដល់បុព្វហេតុបដិវត្តន៍ ការកសាងនិងការកែទម្រង់នៃប្រទេសចិន និងបានរួមវិភាគទានសំខាន់ក្នុងការធ្វើឱ្យប្រជាជាតិចិនរីកចម្រើនទៅមុខ ជំរុញបុព្វហេតុសន្តិភាពនិងការបង្រួបបង្រួមជាតិ ពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការដ៏មេត្រីភាពរវាងប្រជាជនចិននិងប្រជាជននៃប្រទេសនានាលើពិភពលោក ។ ប្រជាជានចិននឹងចងចាំស្នាដៃរបស់អាណិកជនចិននិងជនជាតិចិនដ៏ច្រើនលើសលប់នៅទូទាំងពិភពលោកជាដរាប ។

បច្ចុប្បន្ននេះ ប្រជាជនចិនកំពុងធ្វើការតស៊ូ ដើម្បីសម្រេចគោលដៅ“សតវត្សរ៍ពីរ” និងសុបិនចិនដែលធ្វើឱ្យប្រជាជាតិចិនមានភាពរុងរឿងថ្កុំថ្កើងឡើងវិញ ។ ក្នុងដំណើរដ៏មហិមានេះ អាណិកជនចិននិងជនជាតិចិននៅឯនាយសមុទ្រប្រាកដជាអាចដើរតួនាទីដ៏សំខាន់ដែលមិនអាចជំនួសបានជាមិនខាន ។ សុបិនចិនជាសុបិនរបស់ប្រទេសជាតិ សុបិនរបស់ជនជាតិ ហើយក៏ជាសុបិនរបស់កូនចៅចិនគ្រប់រូបផងដែរ ។ អាណិកជនចិននិងជនជាតិចិននៅឯនាយសមុទ្រដ៏ច្រើនលើសលប់មានមនោសញ្ចេតនាស្នេហាជាតិ មានកម្លាំងសេដ្ឋកិច្ចដ៏រឹងមាំ ធនធានបញ្ញាដ៏សម្បូរ ទំនាក់ទំនងខាងពាណិជ្ជកម្មដ៏ទូលំទូលាយ ដែលជាកម្លាំងសំខាន់សម្រាប់សម្រេចសុបិនចិន ។ ឱ្យតែកូនចៅចិនសាមគ្គីគ្នាជាធ្លុងមួយ រួមវិភាគទានទាំងកាយនិងចិត្ត មុខជាអាចប្រមូលផ្តុំនូវកម្លាំងដ៏ខ្លាំងក្លាសម្រាប់សម្រេចសុបិនជាមិនខាន ។

ឯកឧត្តមស៊ី ជីនភីង បានចង្អុលបង្ហាញថា អរិយធម៌ចិនមានប្រវត្តិសាស្ត្រជាង ៥០០០ ឆ្នាំមកហើយ ជាកម្លាំងស្មារតីដ៏ខ្លាំងរបស់ប្រជាជាតិចិន ដែលមានភាពរឹងមាំនិងរីកចម្រើនដោយឥតឈប់ឈរ ។ ជនរួមជាតិយើងមិនថារស់នៅឯណាសុទ្ធតែមានជិតជាមនូវវប្បធម៌ចិនទាំងអស់ ។ វប្បធម៌ចិនជាហ្សែនស្មារតីរួមរបស់កូនចៅចិន ។ សង្ឃឹមថា អ្នកទាំងអស់គ្នាអាចទទួលនិងបន្តផ្សព្វផ្សាយវប្បធម៌ចិនជាបន្តទៀត មិនគ្រាន់តែត្រូវក្រេបយកកម្លាំងស្មារតីពីវប្បធម៌ចិនប៉ុណ្ណោះទេ ហើយក៏ត្រូវសកម្មជំរុញការផ្លាស់ប្តូរវប្បធម៌រវាងចិននិងបរទេស ពិពណ៌នារឿងរ៉ាវរបស់ចិន ផ្សព្វផ្សាយនូវសំឡេងរបស់ចិន ធ្វើឱ្យប្រជាជនចិននិងបរទេសមានការយល់ដឹងនិងយោគយល់គ្នា សំដៅបង្កើតបរិយាកាសដ៏ល្អប្រសើរសម្រាប់ការសម្រេចសុបិនចិន ។

សុបិនចិនជាសុបិនរបស់ប្រជាជនចិន ដែលស្វែងរកសុភមង្គល ហើយផ្សារភ្ជាប់ជាមួយសុបិនរបស់ប្រជាជនគ្រប់ប្រទេសដែលស្វែងរកសុភមង្គលផងដែរ ។ ប្រទេសល្អ ជនជាតិល្អ អ្នកទាំងអស់គ្នាទើបទទួលបានប្រយោជន៍ល្អ ។ ពិភពលោកល្អ ប្រទេសចិនទើបទទួលបានភាពល្អ ។ ប្រទេសចិនប្រកាន់ខ្ជាប់ការដើរតាមមាគ៌ាអភិវឌ្ឍន៍ដោយសន្តិភាពជាកម្លាំងវិជ្ជមានក្នុងការជួយជំរុញអភិវឌ្ឍន៍ពិភពលោកឱ្យមានភាពរុងរឿងថ្កុំថ្កើង ។ អាណិកជននិងជនជាតិចិននៅឯនាយសមុទ្រដ៏ច្រើនលើសលប់ត្រូវតែប្រើនូវឧត្តមភាពនិងលក្ខណៈសម្បត្តិរបស់ខ្លួន សកម្មបង្កើតនិងជំរុញការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសកំពុងរស់នៅនិងប្រទេសចិនលើគ្រប់វិស័យ ហើយចូលរួមនិងតបស្នងសងគុណសង្គមដែលខ្លួនរស់នៅឱ្យបានកាន់តែប្រសើរថែមទៀត រួមវិភាគទានថ្មីជាបន្តបន្ទាប់ក្នុងការជំរុញសន្តិភាពនិងការអភិវឌ្ឍន៍របស់ពិភពលោក ។



ឯកឧត្តមស៊ី ជីនភីង ប្រធានាធិបតីចិន ថតរូបអនុស្សាវរីយ៍ជាមួយតំណាងនៃមហាមីទីងមិត្តភាពនៃសមាគមអាណិកជនចិននិងជនជាតិចិនលើពិភពលោកលើកទី ៧
中国国家主席习近平同第七届世界华侨华人社团联谊大会代表合影留念 cnsphoto

# កំណែទម្រង់របស់ចិន កាលានុវត្តភាពនៃពិភពលោក

ផែនទីបង្ហាញផ្លូវរបស់ចិន ទទួលបានការចាប់អារម្មណ៍ពីពិភពលោក ។ សហគមន៍អន្តរជាតិបានទទួលស្គាល់ជាទូទៅថា ប្រទេសចិនគឺជាប្រទេសមួយ ដែលមានកម្លាំងរស់រវើកបំផុតក្នុងការធ្វើកំណែទម្រង់ ។ បច្ចុប្បន្ន បដិវត្តន៍ឧស្សាហកម្ម និងបច្ចេកវិទ្យាថ្មីនៃពិភពលោកកំពុងត្រូវបំផុសឡើងជាបន្តបន្ទាប់ ជាហេតុនាំឱ្យបណ្ដាប្រទេសនានាខិតខំកែសម្រួលរចនាសម្ព័ន្ធរបស់ខ្លួនដើម្បីសម្របទៅនឹងស្ថានការណ៍ថ្មី ព្រមនិងចាត់វិធានការកែទម្រង់ជាចាំបាច់ ។ ប្រទេសចិនធ្វើកំណែទម្រង់ឱ្យកាន់តែ



“ទិដ្ឋភាពចិន”និងស្នាដៃចិន ដែលត្រូវបង្ហាញតាមរយៈ“បង្អួចពិព័រណ៍ពិភពលោក”
世博之窗中的“中国镜像”与中国贡献 新华社 图

## 中国的改革 世界的机遇

中国全面深化改革，深谋探索深水区和攻坚期进取之道，展示了大国应有的自信、清醒和定力，赢得世界的赞叹和期待。

中国全面深化改革，不仅将为中国现代化建设提供强大的推动力量，而且将为世界带来新的发展机遇。

ការធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយកាន់តែស៊ីជម្រៅ និងការស្វែងរកមាគ៌ាសម្រាប់ពុះពារឧបសគ្គធំៗក្នុងការកែទម្រង់របស់ប្រទេសចិន បានបង្ហាញជូនពិភពលោកនូវជំនឿចិត្តដ៏មោះមុត ស្មារតីច្បាស់លាស់និងសមត្ថភាពខ្លាំងក្លារបស់ប្រទេសដ៏ធំមួយនេះ ព្រមនិងបានទទួលនូវការកោតសរសើរ និងការរំពឹងទុកពីសំណាក់ប្រជាជនទូទាំងពិភពលោក ។

ការធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោងកាន់តែស៊ីជម្រៅ មិនគ្រាន់តែនឹងអាចជាកម្លាំងចលករដ៏ខ្លាំងក្លាសម្រាប់ការកសាងភាពទំនើបភាវូបនីយកម្មនៃប្រទេសចិនប៉ុណ្ណោះទេ ហើយថែមទាំងនឹងអាចនាំមកនូវកាលានុវត្តភាពអភិវឌ្ឍន៍ថ្មីជូនពិភពលោកទាំងមូលទៀតផង ។



ទេសភាពស្រស់ស្អាតនៅឈូងសមុទ្រ Victoria តំបន់ហុងកុង
香港维多利亚湾两岸美景 新华社 图

ស៊ីជម្រៅ គឺជាវិធានការសមស្របនឹងនិន្នាការអភិវឌ្ឍន៍ និងជាសកម្មភាពសំខាន់មួយដែលក្ដាប់ជាប់នូវឱកាសសម្រេចភាពទំនើបភាវូបនីយកម្មជាតិ និងស្ដារប្រជាជាតិឱ្យមានភាពរុងរឿងឡើងវិញ ។ ទាំងនេះនឹងអាចនាំមកនូវផលប្រយោជន៍ទាំងក្នុងពេលបច្ចុប្បន្ននិងពេលអនាគត ។

កំណត់យកកំណែទម្រង់របបសេដ្ឋកិច្ចជាចំណុចសំខាន់ រៀបចំទំនាក់ទំនងរវាងរដ្ឋាភិបាលនិងទីផ្សារឱ្យបានល្អប្រសើរថែមទៀត ដើម្បីធ្វើឱ្យទីផ្សារមានតួនាទីជាកម្លាំងស្នូលក្នុងការបែងចែក និងប្រើប្រាស់ធនធានទីផ្សារចិនប្រាកដជានឹងអាចបង្កើតបាននូវបរិយាកាសពាណិជ្ជកម្មកាន់តែពេញលក្ខណៈ ឱកាសពាណិជ្ជកម្មកាន់តែច្រើនសន្ធឹក ព្រមនិងអាចមានកម្លាំងទាក់ទាញកាន់តែខ្លាំងចំពោះពិភពលោកទាំងមូលទៀតផង ។ ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន AUDI របស់ប្រទេសអាល្លឺម៉ង់បានមានប្រសាសន៍ថា នេះគឺជាវិធានការសំខាន់ដែលនឹងអាចជួយជំរុញកំណើនសេដ្ឋកិច្ចការប្រកួតប្រជែងនិងការកែច្នៃ ។

ប្រតិបត្តិការរបស់ចិនទទួលបានការកោតសរសើរពីពិភព-លោកទាំងមូល ។ វិធានការជាក់ស្ដែងនៃកំណែទម្រង់ចិនដែលមានពាក់ព័ន្ធនឹង ១៥ វិស័យនិងវិធានការជាង ៣៣០ បាននិងកំពុងត្រូវបានកំណត់និងដាក់ចេញ ប្រជាជនចិនចំនួន ១ ៣០០ លាននាក់ខិតខំប្រឹងប្រែងយ៉ាងពេញទំហឹងដើម្បីសម្រេចសុបិនចិនដែលស្ដារប្រជាជាតិចិនឱ្យមានភាពរុងរឿងឡើងវិញ ។ ក្នុងអំឡុងពេល ៥ ឆ្នាំខាងមុខ ប្រទេសចិននឹងនាំចូលផលិតផលដែលមានតម្លៃស្មើនឹង ១០.០០០.០០០ លានដុល្លារអាមេរិក ដោយមានសហគ្រាសចិនកាន់តែច្រើននឹងដើរចេញទៅក្រៅប្រទេស ហើយទំហំវិនិយោគទុនរបស់ចិននៅក្រៅប្រទេសនឹងអាចកើនឡើងដល់ ៥០០.០០០ លានដុល្លារអាមេរិក ។ អនាគតរបស់ចិន គឺជាសម័យឧស្សាហាភាវូបនីយកម្មបែបថ្មី ព័ត៌មានវិទ្យានគរូបនីយកម្ម និងទំនើបកម្មកសិកម្ម ដែលប្រកបដោយកម្លាំង



រោងជាងដំឡើងយន្តហោះនៅរោងចក្រដំឡើងយន្តហោះ Airbus នៅក្រុងធានជីន
空中客车天津总装线的总装车间 新华社 图



ព្រលានយន្តហោះភូតុងក្នុងក្រុងសៀងហៃ
上海浦东机场 cnsphoto

ចលករខ្លាំងក្លានិងទិដ្ឋភាពរស់រវើក ។

ប្រទេសចិនខិតខំប្រឹងប្រែងដើម្បីកែលម្អនិងអភិវឌ្ឍន៍របបសង្គមនិយមដែលមានលក្ខណៈពិសេសចិន ពន្លឿនទំនើបកម្មនៃប្រព័ន្ធ និងសមត្ថភាពនៃការគ្រប់គ្រងធ្វើឱ្យពិភពលោកចាប់អារម្មណ៍ចំពោះទិសដៅនិងមាគ៌ាអភិវឌ្ឍន៍នៃប្រទេសចិន ។ នេះគឺជាកត្តាចាំបាច់ដ៏សំខាន់មួយដែលសមស្របនឹងផលប្រយោជន៍រៀងខ្លួននៃប្រទេសនីមួយៗ សម្រាប់គាំពារសន្តិភាពនិងជំរុញការអភិវឌ្ឍន៍នៃពិភពលោក ។ ការស្វែងរកមាគ៌ាអភិវឌ្ឍន៍របស់ចិនក៏បានផ្ដល់នូវបទពិសោធន៍និងការបំភ្លឺដល់បណ្ដាប្រទេសនិងតំបន់នានាផងដែរ ជាពិសេសគឺចំពោះប្រទេសកំពុងអភិវឌ្ឍន៍ ។

ការធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយកាន់តែស៊ីជម្រៅរបស់ចិន ក៏ជាកាលានុវត្តភាពរបស់ពិភពលោកទាំងមូល ។ “យុទ្ធសាស្ត្រកំណែទម្រង់ដែលកំណត់ដោយកិច្ចប្រជុំពេញអង្គនៃមជ្ឈិមបក្សនៃសមាជគណបក្សកុម្មុយនិស្តចិនលើកទី ១៨” បានបង្ហាញពីការផ្លាស់រូបភាពនៃការកែទម្រង់ ដើម្បីសម្រេចបាននូវសមិទ្ធផលដែលមានគុណភាពកាន់តែខ្ពស់ និងការអភិវឌ្ឍន៍ជានិរន្តរភាពដែលមានកម្រិតកាន់តែខ្ពស់ថែមទៀត ។ ទាំងនេះនឹងអាចមានសារៈសំខាន់និងមានផលវិជ្ជមានចំពោះសេដ្ឋកិច្ចពិភពលោក ដែលយើងទន្ទឹងរង់ចាំថា នឹងអាចមើលឃើញការប្រែប្រួលទាំងនេះ ។” នេះបើតាមប្រសាសន៍របស់លោកស្រីអគ្គនាយិកាអង្គការរូបិយវត្ថុពិភពលោកបានបង្ហាញឱ្យឃើញពីសារៈសំខាន់នៃការធ្វើឱ្យកំណែទម្រង់គ្រប់ជ្រុងជ្រោយកាន់តែស៊ីជម្រៅរបស់ចិនមានអំណោយផលដល់ពិភពលោកទាំងមូល ។



“ផ្លូវចិនដ៏ស្រស់ស្អាត”នៅលើទឹកដីអាហ្វ្រិក
非洲大陆上的“美丽中国路” 新华社 图

# ទេសចរចិនមានសារៈសំខាន់ចំពោះពិភពលោកទាំងមូល

## 中国游客 对全球都重要

2013年，中国出境旅游规模在2012年8300万人次的基础上上升到9819万人次，同比增长18%，2014年更是或达1.14亿人次；出境旅游消费增长26.8%，达到1287亿美元。中国已经稳居世界第一大出境旅游市场与第一大出境旅游消费国。（翟茜茜 译）




ប្រទេសអង់គ្លេសផ្សព្វផ្សាយពីពាក្យស្លោក“ទទួលបដិសណ្ឋារកិច្ចកក់ក្តៅពីអង់គ្លេស”ដើម្បីទទួលស្វាគមន៍ភ្ញៀវទេសចរចិន
英国推出“尽享英伦礼遇”标示 欢迎中国游客前往 cfp 图

ឆ្នាំ ២០១៣ ចំនួនទេសចរចិនដែលទៅធ្វើទេសចរណ៍នៅក្រៅដែនចិនបានកើនឡើងពី ៨៣ លាននាក់ក្នុងឆ្នាំ ២០១២ ដល់ ៩៨,១៩ លាននាក់ កើនឡើង ១៨ ％ បើប្រៀបធៀបនឹងដំណាក់កាលដូចគ្នានៃឆ្នាំ ២០១២ ហើយនៅឆ្នាំ ២០១៤ មានរហូតដល់ទៅ ១១៤ លាននាក់ ឯកំណើននៃការចំណាយលើការធ្វើទេសចរណ៍នៅក្រៅដែនបានកើនឡើង ២៦,៨ ％ ដែលត្រូវជាទឹកប្រាក់ចំនួន ១២៨.៧០០ លានដុល្លារអាមេរិក ។ ប្រទេសចិនបានក្លាយទៅជាទីផ្សារធំទីមួយក្នុងការធ្វើទេសចរណ៍នៅក្រៅដែន និងប្រទេសធំទីមួយដែលមានចំណាយច្រើនបំផុតខាងការធ្វើទេសចរណ៍លើសកលលោកផងដែរ ។

ការអភិវឌ្ឍន៍នៃការធ្វើទេសចរណ៍នៅក្រៅដែនរបស់ប្រទេសចិន បានធ្វើឱ្យការបំពេញបែបបទធ្វើទិដ្ឋាការមានភាពធូររលុង ហើយការបំពេញបែបបទធ្វើទិដ្ឋាការមានភាពធូររលុងក៏ជំរុញការធ្វើទេសចរណ៍នៅក្រៅដែនរបស់ប្រទេសចិនឱ្យរីកចម្រើនទៅមុខផងដែរ អ្វីទាំងនេះបានបង្ហាញយ៉ាងច្បាស់នៅក្នុងឆ្នាំ ២០១៣ ។ បច្ចុប្បន្ននេះ ប្រទេសចិនបានចុះកិច្ចព្រមព្រៀងស្តីពីការលើកលែងទិដ្ឋាការជាមួយប្រទេសចំនួន ៨១ ដែលក្នុងនោះកន្លែងអនុវត្តADS ជាផ្លូវការមាន ១១៦ កន្លែង ពោលគឺកន្លែងជាគោលដៅទេសចរណ៍ជាក្រុមរបស់ប្រជាពលរដ្ឋចិនគឺលើសពី ៥០％ នៃបរិមាណសរុបនៃប្រទេសនិងតំបន់លើទូទាំងពិភពលោក និងត្រូវជា ៦៧,៤％ នៃចំនួនប្រទេស ដែលបង្កើតទំនាក់ទំនងការទូតជាមួយប្រទេសចិន ។ ក្រៅពីនេះ ក្នុងឆ្នាំ ២០១៣ តម្លៃជាមធ្យមនៃអត្រាប្តូរប្រាក់យ៉ាន់ចិនបានបង្កើតឯតទគ្គកម្មថ្មី ៤១ លើកជាប់ៗ ទំហំឡើងថ្លៃត្រូវជា ៣ ដងនៃឆ្នាំ ២០១២ ការដែលប្រាក់យ៉ាន់ចិនឡើងថ្លៃបានជំរុញការចំណាយខាងការធ្វើទេស-ចរណ៍នៅក្រៅដែនក៏បានក្លាយជាមូលហេតុមួយដែលធ្វើឱ្យការធ្វើទេសចរណ៍នៅក្រៅដែនរីកចម្រើនទៅមុខដោយល្បឿនលឿនផងដែរ ។

តាមឯកសារស្ថិតិរបស់អង្គការទេសចរណ៍ពិភពលោកបានបង្ហាញថា ពីខែមករា ដល់ខែកញ្ញា ឆ្នាំ ២០១៣ ចំនួនទេសចរដែលស្នាក់នៅក្រៅដែនក្នុងពេលយប់លើពិភពលោកបានកើន



ទេសចរចិនសម្រាកនៅតំបន់ប្រាសាទអង្គរវត្ត
中国游客在柬埔寨吴哥窟休憩 cnsphoto



ទិដ្ឋភាពនៃប្រាសាទបាយ័នកម្ពុជា
柬埔寨巴戎寺旅游景象 cfp 图



ជនជាតិចិនទៅធ្វើដំណើរទេសចរណ៍នៅវៀតណាមតាមរយៈច្រកអន្តរជាតិតុងសៀង ក្វាងស៊ី
中国市民通过广西东兴口岸到越南旅游 cfp 图

ឡើង ៤១ លាននាក់ បើប្រៀបធៀបនឹងដំណាក់កាលដូចគ្នានៃឆ្នាំ ២០១២ រីឯទេសចរចិនដែលស្នាក់នៅក្រៅដែនក្នុងពេលយប់បានកើនឡើង ៨,០៤៥១ លាននាក់ ត្រូវជា ១៩,៦២% ។


ទេសចរណ៍ចិនពីរនាក់កំពុងលេងកម្សាន្តនៅមាត់សមុទ្រក្នុងក្រុងណានទីនៃប្រទេសហ្វីហ្ស៊ី
两名中国游客在斐济楠迪海边休闲 新华社 图

ទីផ្សារទេសចរណ៍នៅក្រៅដែនរបស់ប្រទេសចិនមានសារៈសំខាន់សម្រាប់ទីកន្លែងជាគោលដៅទេសចរណ៍ជាច្រើននៅតាមបណ្ដាប្រទេសនិងតំបន់ផ្សេងៗ ។

ឆ្នាំ ២០១៣ ទ្រង់ទ្រាយធ្វើដំណើរនៅក្រៅដែន តាមលក្ខណៈឯកជនរបស់ប្រជាជនចិនមានដល់ទៅ ៩១,៩៦៩ លាននាក់តម្រូវការផ្នែកធ្វើទេសចរណ៍របស់មហាជនកាន់តែខ្ពស់ឡើងៗ ។ ក្រៅពីនេះ ចំនួនទេសចរដែលទៅធ្វើទេសចរណ៍នៅក្រៅដែនច្រើនលើកគឺលើសពី ៦០% យុវជនដែលកើតនៅទសវត្សរ៍ឆ្នាំ ៨០ នៃសតវត្សរ៍មុនកំពុងក្លាយទៅជាកម្លាំងសំខាន់នៃការទៅធ្វើទេសចរណ៍នៅក្រៅដែន សណ្ឋាគារតម្លៃមធ្យមបានក្លាយទៅជាសណ្ឋាគារដែលមានប្រជាប្រិយភាពសម្រាប់ទេសចរចិនបំផុត អ្នកទេសចរដែលទៅធ្វើទេសចរណ៍នៅក្រៅដែនភាគច្រើនបានប្ដូរពីការទិញទំនិញប្រណីតនិងតម្លៃថ្លៃទៅជាការទិញទំនិញធម្មតាដែលប្រើប្រាស់ក្នុងការរស់នៅប្រចាំថ្ងៃ ។

លើផ្នែកបង់ប្រាក់វិញ អង្គការសហព័ន្ធកាតធនាគារចិនបានពង្រីកកិច្ចការទៅដល់នាយសមុទ្រក្នុងឆ្នាំ ២០១៣ ដែលបានគ្របដណ្ដប់នៅប្រទេសនិងតំបន់ចំនួន ១៤២ បន្ថែមទៀត បានផ្ដល់ភាពងាយស្រួលច្រើនដល់អ្នកប្រើប្រាស់កាតធនាគារសម្រាប់ការទៅធ្វើទេសចរណ៍នៅក្រៅដែន ។

លោកតៃ ពីន ប្រធានបណ្ឌិត្យសភាស្រាវជ្រាវពីវិស័យទេសចរណ៍ចិនបានចង្អុលបង្ហាញថា បច្ចុប្បន្ននេះ រូបភាពធ្វើទេសចរណ៍បានប្ដូរពីរូបភាពធ្វើទេសចរណ៍នៅ ១០ ប្រទេសក្នុងរយៈពេល ៩ ថ្ងៃ និងរូបភាពធ្វើទេសចរណ៍ដើម្បីទិញទំនិញនៅឯនាយសមុទ្រ ទៅជាការធ្វើទេសចរណ៍ដោយខ្លួនឯងនិងការធ្វើទេសចរណ៍ដើម្បីស្វែងយល់ពីកន្លែងទេសចរណ៍ឱ្យកាន់តែស៊ីជម្រៅ ។ ការប្រែប្រួលទាំងនេះបានសឱ្យឃើញថា ការធ្វើទេសចរណ៍នៅក្រៅដែនបាននិងកំពុងក្លាយទៅជារបៀបរស់នៅដ៏ធម្មតារបស់ក្រុមមនុស្សដែលមានចំណូលមធ្យម ។

ឆ្នាំ ២០១៤ ចំនួនទេសចរដែលទៅធ្វើទេសចរណ៍នៅក្រៅដែនរបស់ប្រទេសចិននឹងឡើងដល់ ១១៤ លាននាក់ កើនឡើង ១៦% បើប្រៀបធៀបនឹងដំណាក់កាលដូចគ្នានៃឆ្នាំ ២០១៣ ។ ទីផ្សារទេសចរណ៍នៅក្រៅដែនរបស់ប្រជាជនចិនក្នុងឆ្នាំ ២០១៤ ប្រហែលនឹងមានការប្រែប្រួលជាវិជ្ជមានកាន់តែច្រើនថែមទៀត ។

ម្យ៉ាងទៀត ទេសចរចិនដែលទៅធ្វើទេសចរណ៍នៅក្រៅដែនកាន់តែមានសីលធម៌ឡើង ម្យ៉ាងវិញទៀត មានប្រទេសកាន់តែច្រើននឹងផ្ដល់ភាពងាយស្រួលកាន់តែច្រើនដល់ទេសចរចិន ដូចជាធ្វើឱ្យការបំពេញបែបបទធ្វើទិដ្ឋាការកាន់តែងាយស្រួល បង្រួញពេលវេលាបំពេញបែបបទធ្វើទិដ្ឋាការនិងបញ្ចុះតម្លៃធ្វើទិដ្ឋាការជាដើមនិងកាន់តែយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវអំពីទីផ្សារនិងតម្រូវការខាងការចំណាយរបស់ទេសចរចិន ព្រមទាំងលើកកម្ពស់ការពេញចិត្តរបស់ទេសចរចិនចំពោះកន្លែងជាគោលដៅជាបន្តបន្ទាប់ ។


អ្នកដំណើរកំពុងឆ្លងដែននៅសាលត្រួតពិនិត្យក្នុងព្រលានយន្តហោះឈីងតាវនៃខេត្តសានតុង
旅客在山东青岛机场边检大厅过关 新华社 图

# ព្រែកជីកយក្សនិងផ្លូវសូត្ររបស់ប្រទេសចិនត្រូវបានចុះបេតិកភ័ណ្ឌពិភពលោក

## 中国大运河和丝绸之路同登世界遗产名录

中国在2014年世界遗产申报中点燃“双响炮”：大运河是现存世界最长的人工运河，丝绸之路是世界最长的文化遗产线路。对于有五千年历史文明的中国来说，“一河一路”申遗的成功既是传承历史、保护文化的新起点，跨国申遗更是现代国家间文化交流合作的新典范。（翟茜茜　译）

ក្នុងការស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោកឆ្នាំ ២០១៤ សម្បត្តិបេតិកភ័ណ្ឌពីរសម្រាប់ស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោករបស់ប្រទេសចិនបានទទួលជោគជ័យទាំងអស់ ពោលគឺព្រែកជីកយក្សដែលជាព្រែកជីកវែងបំផុតលើលោក និងផ្លូវសូត្រដែលជាខ្សែផ្លូវបេតិកភ័ណ្ឌវប្បធម៌វែងបំផុតលើលោក ។ និយាយចំពោះប្រទេសចិនដែលមានប្រវត្តិសាស្ត្រនិងអរិយធម៌ជាង ៥០០០ ឆ្នាំ ការស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិលោកដោយជោគជ័យនៃព្រែកជីកយក្សនិងផ្លូវសូត្រចិនជាទីចាប់ផ្ដើមថ្មីនៃការទទួលនិងបន្តផ្សព្វផ្សាយប្រវត្តិសាស្ត្រនិងអភិរក្សវប្បធម៌ ហើយការស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោកដោយឆ្លងប្រទេសក៏ជាគំរូថ្មីនៃការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការខាងវប្បធម៌រវាងប្រទេសសម័យទំនើបផងដែរ ។

ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៤ គម្រោងព្រែកជីកយក្សដែលស្នើសុំចុះបញ្ជីដោយប្រទេសចិននិងគម្រោងផ្លូវសូត្រដែលស្នើសុំដោយប្រទេសចិន ឃើគីស្ថាននិងកាហ្សាក់ស្ថានបានទទួលការអនុម័តក្នុងការពិនិត្យពិភាក្សារបស់គណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោកអាណត្តិទី ៣៨ និងត្រូវបានចុះបញ្ជីបេតិកភ័ណ្ឌពិភពលោកជាផ្លូវការ ។ នេះជាសម្បត្តិបេតិកភ័ណ្ឌវប្បធម៌ទី ៣២ និង ៣៣ របស់ប្រទេសចិន ដែលត្រូវបានចុះបញ្ជីបេតិកភ័ណ្ឌវប្បធម៌ពិភពលោករហូតដល់បច្ចុប្បន្ននេះ បរិមាណសរុបនៃសម្បត្តិបេតិកភ័ណ្ឌចិនដែលត្រូវបានចុះបញ្ជីបេតិកភ័ណ្ឌពិភព-លោកមានដល់ ៤៧ ជាប់ចំណាត់ថ្នាក់លេខ ២ លើពិភពលោ ។



ទេសភាពពេលរាត្រីនៅតំបន់តាថាងស៊ីស៊ឺ ក្រុងស៊ីអាន
西安大唐西市夜景　cfp 图



ប្រាង្គតាយានក្នុងក្រុងស៊ីអាន
西安大雁塔　新华社 图



ប្រាសាទតាហ្វូនៅក្រុងការឆាងគូនៃភូមិភាគស្វយ័តស៊ីនជាំង
新疆高昌故城大佛寺　新华社 图

ក្នុងការស្នើសុំចុះបញ្ជីឆ្នាំនេះ“គម្រោងផ្លូវសូត្រ ៖ បណ្ដាញផ្លូវពីឆាងអាន-ធានសានឡាង” ដែលសហការគ្នាស្នើសុំដោយប្រទេសចិន ឃើគីស្ថាននិងកាហ្សាក់ស្ថាន បានក្លាយជាគម្រោងទីមួយរបស់ប្រទេសចិនដែលចូលរួមកិច្ចសហប្រតិបត្តិការឆ្លងប្រទេសនិងទទួលបានភាពជោគជ័យ ។

### ផ្លូវសូត្រ ៖ ការស្នើសុំដោយឆ្លងប្រទេសជាលើកដំបូង

“ផ្លូវសូត្រ ៖ កំណាត់នៃទីចាប់ផ្ដើមនិងបណ្ដាញផ្លូវធានសានឡាង”ជាគម្រេងទីមួយរបស់ប្រទេសចិន ដែលស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោកដោយឆ្លងប្រទេស និងសហការគ្នា



តំបន់ទេសភាពក្នុងវាលខ្សាច់ធឹងគីលីនៅក្រុងជុងវ៉ៃនៃភូមិភាគស្វយ័តនីងស្យា
宁夏中卫市腾格里沙漠景区 新华社 图

ស្នើសុំដោយប្រទេសចិន យើគីស្ថាននិងកាហ្សាក់ស្ថាន ។ ខ្សែផ្លូវនៃគម្រោងនេះមានប្រវែងជិត ៥០០០ គីឡូម៉ែត្របានឆ្លងកាត់មហាដីគោកអឺរ៉ុបនិងអាស៊ី ហើយជាប់ពាក់ព័ន្ធនឹងបុរាណដ្ឋានចំនួន ៣៣ កន្លែងនៅប្រទេសចិន យើគីស្ថាននិងកាហ្សាក់ស្ថាន ។ ក្នុងប្រទេសចិនមានបុរាណដ្ឋាននិងសំណង់បុរាណចំនួន ២២ កន្លែង ដែលក្នុងនោះរួមមានបុរាណដ្ឋាន នៅខេត្តហឺណាន ៤ កន្លែង ខេត្តស្រានស៊ី ៧ កន្លែង ខេត្តកានស៊ូ ៥ កន្លែងនិងភូមិភាគស្វយ័តជនជាតិវ៉ីហ្គួរ ស៊ីនជាំង ៦ កន្លែង ។ គណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោកបានកត់សម្គាល់ថា ផ្លូវសូត្រជាផ្លូវមួយនៃការគួបផ្សំ ផ្លាស់ប្តូរនិងការសន្ទនារវាងបូព៌ាប្រទេសនិងបស្ចិមប្រទេស បានរួមវិភាគទានសំខាន់ចំពោះភាពរុងរឿងថ្កុំថ្កើង រួមរបស់មនុស្សលោកក្នុងរយៈពេលជិត ២០០០ ឆ្នាំ ។



កំណាត់ព្រែកជីកប៉េកាំង-ហាងចូវក្នុងភូមិថៃអឺ ក្រុងចាវជាំង ខេត្តសាតុង
京杭大运河山东枣庄台儿庄段 新华社 图

## ព្រែកជីកយក្ស ៖ បេតិកភ័ណ្ឌវប្បធម៌រស់

ក្នុងនាមជាព្រែកជីកដែលកសាងមុនគេបង្អស់ប្រើប្រាស់អស់ពេលយូរបំផុតលើសកលលោក គិតរហូតដល់បច្ចុប្បន្នព្រែកជីកយក្សនេះ មានប្រវត្តិសាស្ត្រជាង ១៦០០ ឆ្នាំហើយ ។ ព្រែកជីកយក្សជាបេតិកភ័ណ្ឌវប្បធម៌រស់ ដែលសព្វថ្ងៃនៅប្រើប្រាស់ដដែល ហើយបានផ្សារភ្ជាប់យ៉ាងស្អិតល្មួតជាមួយសេដ្ឋកិច្ចជាតិចិន ។ បេតិកភ័ណ្ឌរស់ជាលក្ខណៈពិសេសដ៏លេចធ្លោរបស់ព្រែកជីកយក្សនេះ ។ ការស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោកប្រភេទនេះជាលើកដំបូងរបស់ប្រទេសចិន ។ ព្រែកជីកយក្សដែលស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោក ប្រភេទនេះរួមមានព្រែកជីកយក្សស៊ុយថាង ព្រែកជីកយក្សជីងហាងនិងព្រែកជីកយក្សជឺតុង ដែលហូរកាត់តំបន់ភាគកណ្តាលនិងបូព៌ានៃប្រទេសចិន ។ បេតិកភ័ណ្ឌដែលស្នើសុំក្នុងគម្រោងនេះមានកំណាត់ព្រែកជីកជាគំរូនិងតំបន់បុរាណដ៏សំខាន់ដែលក្នុងនោះមានកំណាត់ព្រែកជីកបុរាណដ្ឋាន ២៧ កំណាត់ មានប្រវែងសរុប ១០១១ គីឡូម៉ែត្រនិងតំបន់បុរាណ ៥៨ កន្លែង ។

ការស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោក គឺដើម្បីទទួលនិងបន្តផ្សព្វផ្សាយកេរ្តិ៍ដំណែលវប្បធម៌ ។

អ្នកទទួលខុសត្រូវមានពាក់ព័ន្ធនៃនាយកដ្ឋានបុរាណវត្ថុជាតិចិនបាននិយាយដោយត្រង់ៗថា ការដែលព្រែកជីកយក្សនិងផ្លូវសូត្រស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោកជាដំណើរអភិរក្សបេតិកភ័ណ្ឌមិនដែលមានពីមុន ។ គម្រោងស្នើសុំទាំងពីរនេះបានទទួលជោគជ័យដែលបានបង្ហាញនូវតម្លៃទូទៅ លក្ខណៈពិតនិងលក្ខណៈពេញលេញដ៏លេចធ្លោរបស់ព្រែកជីកយក្សនិងផ្លូវសូត្រ ព្រមនិងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលចិនក្នុងការអភិរក្សបេតិកភ័ណ្ឌដ៏មានតម្លៃទាំងនេះ បានទទួលការទទួលស្គាល់ជាឯកច្ឆន្ទពីសំណាក់គណៈកម្មាធិការបេតិកភ័ណ្ឌពិភពលោកនិងអង្គការពិគ្រោះយោបល់ជំនាញអន្តរជាតិ ។

ព្រែកជីកយក្សនិងផ្លូវសូត្រ ស្នើសុំចុះបញ្ជីបេតិកភ័ណ្ឌពិភពលោកបានទទួលជោគជ័យ គ្រាន់តែជាទីចាប់ផ្តើមថ្មីក្នុងប្រវត្តិសាស្ត្រនិងវប្បធម៌ដ៏យូរលង់របស់ប្រទេសចិនតែប៉ុណ្ណោះ ។ រដ្ឋាភិបាលចិននឹងគោរពតាមកតិកាសញ្ញាបេតិកភ័ណ្ឌពិភពលោកនិងការទាមទារមានពាក់ព័ន្ធក្នុងសេចក្តីណែនាំនៃកតិកាសញ្ញានេះ បន្តធ្វើការអភិរក្សឱ្យបានល្អបំផុតនូវព្រែកជីកយក្សនិងផ្លូវសូត្រដែលជាសម្បត្តិបេតិកភ័ណ្ឌវប្បធម៌ដ៏មានតម្លៃ ព្រមនិងបន្សួមសាមគ្គីជាមួយភាគីពាក់ព័ន្ធនានាដែលមានផលប្រយោជន៍ដូចគ្នា ពង្រឹងយន្តការសម្រាប់សន្ទនាគ្នានិងសម្របសម្រួលដោយឆ្លងតំបន់និងឆ្លងមុខរបរថែមមួយកម្រិតទៀត ធ្វើការពិគ្រោះពិភាក្សាយ៉ាងជ្រាលជ្រៅអំពីសម្បត្តិបេតិកភ័ណ្ឌវប្បធម៌ធំៗ ជាពិសេសគឺការប្រើប្រាស់បេតិកភ័ណ្ឌវប្បធម៌រស់ដោយមានបទដ្ឋាន អភិរក្ស គ្រប់គ្រងនិងប្រើប្រាស់ដោយមានតុល្យភាព ធ្វើឱ្យព្រែកជីកយក្សដែលសម្បូរដោយខ្លឹមសារស្មារតីហូរចាក់ទៅអនាគតដែលប្រកបដោយការអភិវឌ្ឍន៍ជានិរន្តរភាពនិងធ្វើឱ្យផ្លូវសូត្រដ៏ចំណាស់បញ្ចេញពន្លឺដ៏ត្រចះត្រចង់ម្តងទៀត ។



ស្ពានកុងឆឺនដែលជាចំណុចបញ្ចប់នៃព្រែកជីកប៉េកាំង-ហាងចូវ
京杭大运河杭州终点标志——拱宸桥 新华社 图

# ណាននីង បើកទូលាយកាន់តែស៊ីជម្រៅ កាន់តែមានទំនុកចិត្តលើខ្លួនឯង

## 南宁 越开放越自信

一座中国面向东盟开放合作的南疆城市——南宁，经济总量已占广西的1/5，城市亮丽大气，南宁渠道越走越宽畅……“提高国际能见度，让世界感受南宁魅力！”拥有1600多年建城历史的南宁，从未像今天这样开放、自信，并以全球化视野，从容领跑壮乡。

ក្នុងនាមជាទីក្រុងតាមព្រំដែនខាងត្បូងមួយ ណាននីង បានទទួលសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងដំណើរបើកទូលាយចំពោះប្រទេសអាស៊ាន ។ បច្ចុប្បន្ន បរិមាណសេដ្ឋកិច្ចសរុបរបស់ណាននីងត្រូវជា ១ ភាគ ៥ នៃទំហំសេដ្ឋកិច្ចសរុបរបស់ភូមិភាគស្វយ័តក្វាងស៊ី ពិសេសគឺណាននីងមានសោភ័ណភាពស្រស់ត្រកាលដែលកាន់តែជាកម្លាំងទាក់ទាញនិងជាផ្លូវអភិវឌ្ឍន៍កាន់តែទូលំទូលាយ ។ “លើកកម្ពស់តួនាទីអន្តរជាតិ ដើម្បីធ្វើឱ្យពិភពលោកស្វែងយល់ពីក្រុងណាននីង !” និយាយជារួម ណាននីងដែលមានប្រវត្តិជាង ១៦០០ ឆ្នាំ មិនដែលបើកទូលាយនិងមានទំនុកចិត្តលើខ្លួនឯងដូចថ្ងៃនេះទេ ហើយបានឈរលើចក្ខុវិស័យអន្តរជាតូបនីយកម្ម នាំមុខគេក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចនៅភូមិភាគស្វយ័តជនជាតិជាំង ក្វាងស៊ី ។

ណាននីងមានឧត្តមភាពខាងទីតាំងភូមិសាស្ត្រ ក៏ប៉ុន្តែក្នុងនាមជាទីរួមខេត្តក្វាងស៊ី គេធ្លាប់មានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះតួនាទីរបស់ណាននីង ដោយសារណាននីងធ្លាប់មានសេដ្ឋកិច្ចអន់ខ្សោយ ដែលចាញ់ក្រុងលីវចូវលើវិស័យឧស្សាហកម្ម ចាញ់ក្រុងគួយលីនលើវិស័យទេសចរណ៍ ចាញ់ក្រុងយូលីនលើវិស័យកសិកម្ម និងចាញ់ក្រុងបៃស៊ឺនិងហ៊ឺឈឺលើវិស័យធនធានធម្មជាតិ ។ ដូច្នេះតើក្រុងណាននីងត្រូវធ្វើដូចម្ដេចដើម្បីដឹកនាំការរីកចម្រើនរបស់ក្វាងស៊ី និងសម្រេចការលោតផ្លោះឱ្យទាន់គេ ? ក្នុងស្មារតីនេះ ណាននីងបានពឹងផ្អែកលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិចិន ទៅកំណត់ចក្ខុវិស័យវែងឆ្ងាយ និងបានទទួលសមិទ្ធផលជាក់ស្ដែង ។ ណាននីងក្ដាប់បានឱកាសនៃកិច្ចសហប្រតិបត្តិការរវាងចិននិងអាស៊ាន លើកកម្ពស់តួនាទីរបស់ខ្លួនឱ្យទៅជាទីក្រុងអន្តរជាតិក្នុងកម្រិតតំបន់មួយ បានធ្វើឱ្យណាននីងមានអនាគតកាន់តែភ្លឺស្វាង !

នៅឆ្នាំ ២០០៤ ពិព័រណ៍ចិន-អាស៊ានត្រូវបានបង្កើតឡើងដោយស្របតាមនិន្នាការអភិវឌ្ឍន៍ទូទៅ ក្នុងនោះណាននីងត្រូវបានកំណត់ជាម្ចាស់ផ្ទះសម្រាប់រៀបចំពិព័រណ៍អចិន្ត្រៃយ៍ ។ ក្នុងរយៈពេល ១០ ឆ្នាំកន្លងទៅ ណាននីងបានរៀបចំពិព័រណ៍ដ៏អធិកអធមនេះក្រោមទិដ្ឋភាពថ្មីស្រឡាង និងគួរឱ្យទាក់ទាញជាប់រហូត ដែលបានបង្កើតជាវេទិកាណាននីងមួយដែលជំរុញដល់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ការផ្លាស់ប្ដូរនិងការពិគ្រោះពិភាក្សារវាងប្រទេសចិននិងអាស៊ាន ។ សព្វថ្ងៃប្រទេសអាស៊ានចំនួន ៥ ដែលរួមមានវៀតណាម ឡាវ មីយ៉ាន់ម៉ាថៃនិងកម្ពុជា បានបង្កើតស្ថានអគ្គកុងស៊ុលនៅឯក្រុងណាននីង ។

ធ្វើឱ្យពិភពលោកស្គាល់ណាននីង ! ក្រៅពីការបើកទូលាយ តើណាននីងនៅមានអ្វីខ្លះអាចបង្ហាញជូនពិភពលោក ? “ពណ៌បៃតង” ! តាមផែនទីបង្ហាញផ្លូវនៃការអភិវឌ្ឍន៍ ណាននីងនឹងខិតខំបង្កើត“ក្រុងបៃតង”ដោយមានអត្រាពាក់កណ្ដាលជាដើមឈើ ពាក់កណ្ដាលជាអគារ ។ ទស្សនៈពណ៌បៃតងក៏បានត្រូវច្របាច់បញ្ចូលក្នុងការអភិវឌ្ឍន៍មុខរបរផងដែរដោយប្រកាន់ខ្ជាប់នូវគោលការណ៍លុបចោលគម្រោងវិនិយោគដែលអាចនឹងប៉ះពាល់ខ្លាំងដល់បរិស្ថាន ឬចំណាយថាមពលច្រើន ។ មិនតែប៉ុណ្ណោះទេ សាលាក្រុងណាននីងក៏បានប្រកាសបិទទ្វារនៃសហគ្រាសចំនួនជាង ២០០ ក្នុងរយៈពេល ៨ ឆ្នាំដែលសុទ្ធតែជាសហគ្រាសប៉ះពាល់ខ្លាំងដល់បរិស្ថាន ចំណាយថាមពលច្រើននិងប្រើប្រាស់ទឹកច្រើន ។ គួរបញ្ជាក់ថា ដើម្បីពង្វាតទំហំនៃគម្រោងអភិវឌ្ឍន៍ទីក្រុងបៃតង ណាននីងបានបណ្ដាក់ទុកជាង ៣០ ០០០ លានយាន់ សម្រាប់កសាងបណ្ដាញធនធានទឹកដែលមានឈ្មោះថា “ទន្លេមួយ តំបន់ទឹកពីរ រង្វង់ប្រាំមួយនិងព្រែកដប់ប្រាំបី” ពោលគឺនៅឆ្នាំ ២០២០ ក្នុងក្រុងណាននីងនឹងអាចមើលឃើញទឹកទន្លេក្នុងគម្លាតគ្នាតែ ១ ០០០ ម៉ែត្រ និងមានបឹងបួក្នុងគម្លាតគ្នាតែ ២០០០ ម៉ែត្រ ។

បរិយាកាសដ៏ល្អប្រសើររបស់ណាននីងក៏បានទាក់ទាញអ្នកវិនិយោគច្រើនដែរ ។ បន្ទាប់ពីឆ្នាំ ២០១៣ សហគ្រាសធំៗរបស់ប្រទេសចិនបានដណ្ដើមគ្នាមកបោះទុនវិនិយោគនៅក្រុងណាននីង និងបានពង្រីកកិច្ចការរបស់ខ្លួនក្នុងទីក្រុងបៃតងនេះ។

ទោះជាបែបនេះក៏ដោយ ណាននីងមិនបានបញ្ឈប់ដំណើរអភិវឌ្ឍន៍របស់ខ្លួននោះទេ ។ នៅដើមឆ្នាំនេះ សាលាក្រុងណាននីងបានសម្រេចថា នឹងប្រើពេលពីរឆ្នាំសម្រាប់កសាងមូលដ្ឋានគ្រឹះ បីឆ្នាំសម្រាប់សម្រេចការអភិវឌ្ឍន៍ដោយលោតផ្លោះ និងប្រាំឆ្នាំសម្រាប់លើកកម្ពស់តួនាទីរបស់ខ្លួន សរុបទៅគឺធ្វើឱ្យក្រុងណាននីងក្លាយជាក្បាលម៉ាស៊ីននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ អ្នកនាំមុខក្នុងការធ្វើកិច្ចសហប្រតិបត្តិការនិងបើកទូលាយ និងជាគំរូដ៏ល្អប្រសើរដែលស័ក្តិសមនឹងការរស់នៅប្រកបដោយសុខដុមរមនា ។



ស្ពានអាកាសជូស៊ីក្នុងក្រុងណាននីង

南宁竹溪立交桥 新华社 图




ស្ថានីយរថភ្លើងក្វាងចូវ
广州火车东站

# ច្រកអន្តរជាតិផ្លូវដែក ធានហ៊ឺ ក្រុងក្វាងចូវ

## 广州天河铁路客运口岸

文/岚　筱　图/cfp

广州车站，是中国第一条准高速铁路——广深准高速铁路的起点站。新建的广州东站为京九线上重要的交通枢纽，是一座集客运、商贸、金融、旅游、饮食、娱乐、办公为一体的现代化大型综合客运站，建设规模仅次于全国最大的北京西客站。广州天河铁路客运口岸位于广州东站内，是东站的重要组成部分，是广州市一个重要的对外开放口岸。

ស្ថានីយរថភ្លើងក្វាងចូវ គឺជាចំណតចាប់ផ្តើមនៃខ្សែផ្លូវដែកល្បឿនលឿនទី ១ របស់ចិន គឺផ្លូវដែកក្វាងចូវ-សិនចិន ។ ស្ថានីយរថភ្លើងខាងកើតក្វាងចូវដែលទើបសាងសង់ថ្មី គឺជាចំណតដ៏សំខាន់មួយ តាមបណ្តោយផ្លូវដែកប៉េកាំង-ជីវឡុង ដែលជាស្ថានីយរថភ្លើងទំនើបកម្មខ្នាតធំនិងមានមុខងារចម្រុះ ដែលពាក់ព័ន្ធនឹងវិស័យដឹកអ្នកដំណើរ ពាណិជ្ជកម្ម ហិរញ្ញវត្ថុ ទេសចរណ៍ ការហូបចុក និងការលេងកម្សាន្ត ហើយក៏មានការិយាល័យធ្វើការនៅក្នុងនោះផងដែរ ។ ស្ថានីយរថភ្លើងនេះជាស្ថានីយរថភ្លើងធំជាងគេទី ២ របស់ចិន បន្ទាប់ពីស្ថានីយរថភ្លើងខាងលិចប៉េកាំង ។ ច្រកអន្តរជាតិផ្លូវដែកធានហ៊ឺ ក្រុងក្វាងចូវគឺស្ថិតនៅក្នុងស្ថានីយរថភ្លើងខាងកើតក្វាងចូវ ។ វាជាផ្នែកដ៏សំខាន់មួយរបស់ស្ថានីយរថភ្លើងខាងកើត និងជាច្រកអន្តរជាតិដ៏សំខាន់មួយសម្រាប់ការបើកទូលាយចំពោះបរទេស ។



សាលអ្នកដំណើរក្នុងច្រកអន្តរជាតិនេះ មានផ្ទៃក្រឡាជិតមួយម៉ឺនម៉ែត្រការ៉េ តែគ្មានសសរមួយដើមសោះ ដែលបានជាប់ចំណាត់ថ្នាក់លេខមួយក្នុងប្រទេសចិនទាំងលើវិស័យទំហំផ្ទៃដីនិងប្រវែង ។ ក្នុងស្ថានីយរថភ្លើងនេះនៅមានបំពាក់បរិក្ខារមួយចំនួនធំដូចជាជណ្តើរយន្តស្វ័យប្រវត្តិ ជណ្តើរយន្តសម្រាប់អ្នកដំណើរ (រួមមានជណ្តើរយន្តសម្រាប់ជនពិការ) ជណ្តើរយន្តដឹកទំនិញដែលសុទ្ធតែគ្រប់គ្រងដោយកុំព្យូទ័រនិងបានផ្តល់ភាពងាយស្រួលសម្រាប់អ្នកដំណើរឡើងចុះ ។ ទន្ទឹមនឹងនេះដែរ ក្នុងអគារស្ថានីយនៅមានប្រព័ន្ធម៉ាស៊ីនត្រជាក់ដែលបានផ្តល់ជូនអ្នកដំណើរនូវបរិស្ថានដ៏ត្រជាក់ស្រួល ។

ច្រកអន្តរជាតិផ្លូវដែក ធានហ៊ឺ ក្រុងក្វាងចូវ គឺជាច្រកអន្តរ-ជាតិទំនើបកម្មសម្រាប់ដឹកអ្នកដំណើរតាមផ្លូវដែកដែលមានទ្រង់ទ្រាយធំជាងគេ មានបរិក្ខារលឿនលឿននិងមានរចនាបថស្ថាបត្យកម្មថ្មីស្រឡាងក្នុងប្រទេសចិន ។ សាលពិនិត្យការឆ្លងដែនចែកជាសាលចូលដែននិងសាលចេញពីដែន ដែលរួមមានស្ថាប័នគយ ស្ថាប័នត្រួតពិនិត្យតាមព្រំដែន ស្ថាប័នពិនិត្យជំងឺសត្វ ស្ថាប័នផ្តល់ទិដ្ឋាការ ធនាគារ និងហាងលក់ទំនិញរួចពន្ធជាដើម ។ នៅក្រៅច្រកចូលព្រំដែន នៅមានកន្លែងផ្តល់សេវាកម្មស្នាក់នៅនិងទេសចរណ៍ជាដើម ។

ក្នុងគោលបំណងកសាងច្រកអន្តរជាតិផ្លូវដែក ធានហ៊ឺ ក្រុងក្វាងចូវឱ្យទៅជាច្រកអន្តរជាតិទំនើបកម្មថ្មីមួយដែលមានកម្រិតថ្នាក់លេខមួយនិងកម្រិតគ្រប់គ្រងលេខមួយ ស្ថាប័នត្រួតពិនិត្យនិងអង្គភាពផ្តល់សេវាកម្មផ្សេងៗ សុទ្ធតែបានបំពាក់នូវបរិក្ខារលឿនលឿន ព្រមនិងអនុវត្តការគ្រប់គ្រងតាមវិធីវិទ្យា-សាស្ត្រ ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធនិងបរិក្ខារត្រួតពិនិត្យដោយកុំព្យូទ័រលឿនលឿនបំផុត នឹងអាចផ្តល់ជូនអ្នកដំណើរនូវសេវាកម្មដែលប្រកបដោយលក្ខណៈសីលធម៌ គុណភាពខ្ពស់ សុវត្ថិភាពគួរឱ្យជឿទុកចិត្តនិងប្រសិទ្ធភាពខ្ពស់ ដើម្បីធ្វើឱ្យអ្នកដំណើរទាំងអស់អាចឆ្លងដែនដោយមានភាពងាយស្រួល នឹងមានទឹកចិត្តសប្បាយរីករាយ ។

ក្រោមការដឹកនាំនៃថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធនៃរដ្ឋាភិបាលចិន សាលាខេត្ត សាលាក្រុង និងអាជ្ញាធរនៅច្រកអន្តរជាតិផ្លូវដែក ធានហ៊ឺ ក្រុងក្វាងចូវ បានទទួលស្គាល់យ៉ាងច្បាស់នូវតួនាទី និងឋានៈខ្ពស់នៃការកសាងអរិយធម៌ខាងស្មារតីសង្គមនិយម ជំរុញឱ្យកាន់តែស៊ីជម្រៅនូវការងារ "រួមសហការគ្នា" ផ្សព្វផ្សាយពីប្រពៃណីដ៏ល្អប្រសើរ គ្រប់គ្រងដោយវិទ្យាសាស្ត្រ និងផ្តល់សេវាកម្មដ៏មានគុណភាពខ្ពស់ ដើម្បីទទួលស្វាគមន៍ភ្ញៀវទេសចរណ៍ ដែលមកពីគ្រប់ទិសទីដោយទឹកមុខញញឹមស្រស់ស្រាយ ។ ដោយឈរលើលក្ខណៈសម្បត្តិលេខមួយ អនុវត្តការគ្រប់គ្រងល្អលេខមួយ ដើម្បីបង្កើតច្រកអន្តរជាតិប្រកបដោយអរិយធម៌និងធានាឱ្យអ្នកដំណើរឬការជញ្ជូនទំនិញឆ្លងដែនដោយមានភាពងាយស្រួលឆាប់រហ័សនិងរលូន ។ យោងតាមលក្ខណៈពិសេស និងស្ថានភាពជាក់ស្តែងនៃច្រកអន្តរជាតិធានហ៊ឺទៅកែលម្អល័ក្ខខ័ណ្ឌការងារឱ្យមានភាពកាន់តែល្អប្រសើរ ផ្តោតសំខាន់ទៅលើការបង្កើតច្បាប់បញ្ញត្តិនិងការកំណត់ផ្សេងៗនៃច្រកអន្តរជាតិ ដើម្បីធ្វើឱ្យការងារគ្រប់ប្រភេទអនុវត្តទៅតាមច្បាប់ឬការកំណត់ដែលមានស្រេច មានបទដ្ឋាននិងមានលក្ខណៈវិទ្យាសាស្ត្រ សំដៅកសាងច្រកអន្តរជាតិផ្លូវដែក ធានហ៊ឺ ក្រុងក្វាងចូវ ឱ្យទៅជាច្រកអន្តរជាតិអរិយធម៌មួយដែលមានប្រសិទ្ធភាពការងារខ្ពស់ ។



# ច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទីង




ខ្លោងទ្វារប្រទេសនៅតាមច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទីង
孟定清水河口岸国门

## 孟定清水河口岸

文/岚 筱　图/刘江林

孟定清水河口岸位于云南省耿马傣族佤族自治县孟定镇人民政府所在地，与缅甸掸邦第一特区接壤，是耿马县连接南亚、东南亚最便捷的陆上通道，同时也是中国西南地区通往缅甸和东南亚的重要陆路通道，素有“黄金口岸”之称。（翟茜茜　译）

ច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទីង មានទីតាំងស្ថិតនៅទីរួមឃុំម៉ឹងទីងនៃស្រុកស្វយ័តជនជាតិតៃនិងជនជាតិវ៉ា ទីម៉ា ខេត្តយូណាន ដែលនៅជាប់ជាមួយតំបន់ពិសេសទី ១ នៃរដ្ឋសាន់ប្រទេសមីយ៉ាន់ម៉ា ដែលជាផ្លូវគោកមានលក្ខណៈងាយស្រួលបំផុតសម្រាប់ធ្វើដំណើរពីស្រុកទីម៉ាទៅកាន់ប្រទេសអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ ហើយក៏ជាផ្លូវគោកដ៏សំខាន់មួយសម្រាប់ធ្វើដំណើរពីភូមិភាគនិរតីចិនទៅកាន់ប្រទេសមីយ៉ាន់ម៉ា និងតំបន់អាស៊ីអាគ្នេយ៍ផងដែរ ដែលពីដើមមកក៏ត្រូវបានគេប្រសិទ្ធនាមថា“ច្រកសុវណ្ណ” ។

ច្រកអន្តរជាតិម៉ឹងទីង មិនគ្រាន់តែជាច្រកអន្តរជាតិលើគោកដ៏សំខាន់មួយប៉ុណ្ណោះទេ ហើយថែមទាំងក៏ជាកន្លែងដ៏សំខាន់មួយសម្រាប់ធ្វើពាណិជ្ជកម្ម និងការផ្លាស់ប្តូរវប្បធម៌រវាងតំបន់និរតីចិននិងប្រទេសមីយ៉ាន់ម៉ា ថៃនិងឥណ្ឌាជាដើម ព្រមទាំងក៏ជាមូលដ្ឋានស្មៀង តំបន់ដាំដុះកៅស៊ូ មូលដ្ឋានដាំដុះបន្លែនិងផ្លែឈើនារដូវរងាដែលមានតួនាទីសំខាន់នៅខេត្តយូណាន ។



មជ្ឈមណ្ឌលត្រួតពិនិត្យរួមនៅតាមច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទីង
孟定清水河口岸联检中心



ជាពិសេស ទីនេះក៏ជាស្រុកជនជាតិតៃ ដែលមានលក្ខណៈតំណាងជនជាតិតៃដ៏គួរឱ្យចាប់អារម្មណ៍ជាងគេនៅខេត្តយូណានទៀតផង ។ ច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទីងស្ថិតនៅផ្នែកកណ្តាលក្នុងចំណោមបណ្តាច្រកអន្តរជាតិនានានៃប្រទេសចិននិងមីយ៉ាន់ម៉ា ដែលមានអំណោយផលដល់ច្រកអន្តរជាតិផ្សេងទៀត ។ ច្រកអន្តរជាតិនេះគឺជាច្រកលើគោកដែលស្ថិតនៅជិតកំពង់ផែជីវភាវ និងកំពង់ផែរ៉ុងហ្គូននៃប្រទេសមីយ៉ាន់ម៉ាជាងគេ ហើយក៏ជាទីតាំងយុទ្ធសាស្ត្រសំខាន់សម្រាប់តភ្ជាប់ប្រទេសចិនជាមួយអាស៊ីខាងត្បូង អាស៊ីអាគ្នេយ៍ និងមហាសមុទ្រឥណ្ឌាផងដែរ ។ នាឆ្នាំ ១៩៥៧ ច្រកអន្តរជាតិម៉ឹងទីងចាប់ផ្តើមជាផ្លូវការនូវការធ្វើពាណិជ្ជកម្មខ្នាតតូចជាមួយបរទេស ហើយទទួលបានការអនុម័តពីសាលាខេត្តយូណានឱ្យក្លាយជាច្រកអន្តរជាតិលេខ ២ នៅខែសីហា ឆ្នាំ ១៩៩១ និងត្រូវបានដំឡើងជាច្រកអន្តរជាតិលេខ ១ ថ្នាក់ជាតិ នៅថ្ងៃទី ១៤ ខែតុលា ឆ្នាំ ២០០៤ ដោយមានការអនុម័តពីក្រុមប្រឹក្សាកិច្ចការរដ្ឋចិន ។ កាលពីថ្ងៃទី ៧ ខែវិច្ឆិកា ឆ្នាំ ២០០៧ ការងារត្រៀមរៀបចំនៃការបើកទូលាយរបស់ច្រកអន្តរជាតិម៉ឹងទីងបានឆ្លងកាត់ការត្រួតពិនិត្យពីរដ្ឋាភិបាលចិន ហើយបានបើកទូលាយជាផ្លូវការ ។ ដោយឈរលើទីតាំងភូមិសាស្ត្រដ៏មានឧត្តមភាព ទេសភាពធម្មជាតិតំបន់ត្រូពិចដ៏ស្រស់ស្អាត ទំនៀមទម្លាប់ប្រពៃណីដ៏ទាក់ទាញ ធនធានទេសចរណ៍ដ៏សម្បូរបែប ដំណាំសេដ្ឋកិច្ចតំបន់ត្រូពិចដ៏មានសក្តានុពល និងមុខងារច្រកអន្តរជាតិដែលមានល័ក្ខខ័ណ្ឌកាន់តែល្អប្រសើរពីមួយថ្ងៃទៅមួយថ្ងៃនោះ ច្រកអន្តរជាតិម៉ឹងទីងបាននិងកំពុងទាក់ទាញវិនិយោគិនក្នុងស្រុក និងមកពីបណ្តាប្រទេសអាស៊ីអាគ្នេយ៍ឱ្យមកបណ្តាក់ទុនធ្វើអាជីវកម្មដែលបានធ្វើឱ្យទីនេះមានភាពកាន់តែល្អប្រសើរឡើង ។



អ្នកដំណើរកំពុងទទួលការត្រួតពិនិត្យដើម្បីឆ្លងដែន
边民过境通关检查

បន្ទាប់ពីការដាក់ឱ្យដំណើរការជាផ្លូវការរៀងមក ច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទីង គឺជាច្រកដ៏សំខាន់មួយសម្រាប់ធ្វើពាណិជ្ជកម្មទាំងក្នុងនិងក្រៅប្រទេសចិន ដែលមានពាក់ព័ន្ធទៅនឹងរដ្ឋសាន់ ក្រុងឈីងស្វយ ឃុំណ្វងជិន ក្រុងហ្វ៉ាប៉ាន ក្រុងរ៉ង់ហ្គូន និងខេត្តក្រុងមួយចំនួនធំរបស់ប្រទេសមីយ៉ាន់ម៉ា ជាពិសេសរូបភាពធ្វើអាជីវកម្មក៏បានប្រែក្លាយពីការផ្លាស់ប្តូរទំនិញខ្នាតតូចទៅជាការធ្វើពាណិជ្ជកម្មខ្នាតធំតាមព្រំដែន ។ ជាច្រើនឆ្នាំកន្លងទៅនេះ ច្រកអន្តរជាតិនេះមានហេដ្ឋារចនាសម្ព័ន្ធនិងមុខងារសេវាកម្មចម្រុះកាន់តែល្អប្រសើរឡើង ជាហេតុនាំឱ្យការឆ្លងដែនមានភាពងាយស្រួល និងបាននាំមកនូវផលចំណេញកាន់តែច្រើនសម្រាប់ប្រជាជននៅតាមតំបន់នេះ ។ ទីតាំងភូមិសាស្ត្រដ៏ល្អប្រសើរ មូលដ្ឋានពាណិជ្ជកម្មនិងឧស្សាហកម្មដ៏រឹងមាំ ហេដ្ឋារចនាសម្ព័ន្ធពេញលក្ខណៈ និងទំនាក់ទំនងមិត្តភាពជាមួយមីយ៉ាន់ម៉ា នឹងអាចផ្តល់ផលប្រយោជន៍ដល់ការកសាង និងអភិវឌ្ឍន៍តំបន់សហប្រតិបត្តិការតាមព្រំដែនលីនឆាង-ឌីម៉ា(ម៉ឹងទីង) ព្រមនិងមានអំណោយផលដល់ការសម្រេចគោលដៅផ្តល់ផលប្រយោជន៍ដល់គ្នាទៅវិញទៅមកនិងការរួមគ្នាអភិវឌ្ឍរបស់ប្រទេសទាំងពីរចិននិងមីយ៉ាន់ម៉ាទៀតផង ។



អនុផលកសិកម្មមីយ៉ាន់ម៉ាត្រូវបាននាំចូលមកប្រទេសចិន
缅甸农副产品出口中国

# ច្រកអន្តរជាតិផ្លូវគោក ឆាងយាន់



ច្រកម៉ាងខា

芒卡通道　cfp 图

## 沧源口岸

文/岚　筱

沧源陆运（公路）口岸位于临沧市沧源县，与缅甸掸邦第二特区接壤，有芒卡和永和两个出境通道。口岸于1996年9月27日经云南省政府批准为二类口岸。

ច្រកអន្តរជាតិផ្លូវគោក ឆាងយាន់(ថ្នាល់ជាតិ)មានទីតាំងស្ថិតនៅស្រុកឆាងយាន់ ក្រុងលីនឆាង ដែលជាប់នឹងតំបន់ពិសេសទី ២ នៃរដ្ឋសាន់នៃប្រទេសមីយ៉ាន់ម៉ា ។ ច្រកអន្តរជាតិនេះមានច្រកឆ្លងដែនពីរ គឺច្រកម៉ាងខានិងច្រកយ៉ុងហ៊ី ។ នៅថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ១៩៩៦ ច្រកអន្តរជាតិផ្លូវគោក ឆាងយាន់ត្រូវបានសាលាខេត្តយូណានអនុម័តជាច្រកអន្តរជាតិលេខ ២ ថ្នាក់ជាតិ ។

ច្រកម៉ាងខាឋិតនៅភាគពាយ័ព្យនៃឃុំម៉ាងខាស្រុកឆាងយាន់ ត្រើយខាងត្បូងនៃទន្លេណានទឹង ដែលនៅជាប់បង្គោលព្រំដែនលេខ ១៤៦ រវាងប្រទេសចិននិងមីយ៉ាន់ម៉ា ។ ច្រកនេះមានចម្ងាយ ៤,៥ គីឡូម៉ែត្រពីសាលាឃុំម៉ាងខា ។ ខាងជើងនៃច្រកម៉ាងខាជាប់នឹងទន្លេឈីងស្វយ ខាងកើតជាប់នឹងឃុំម៉ឹងទឹងដែលជាមជ្ឈមណ្ឌលនៃតំបន់សហប្រតិបត្តិការសេដ្ឋកិច្ចតាមព្រំដែនទីម៉ា(ម៉ឹងទឹង) ឯខាងត្បូងជាប់នឹងតំបន់សេដ្ឋកិច្ចពិសេសនៃរដ្ឋវ៉ារបស់ប្រទេសមីយ៉ាន់ម៉ា ។ ច្រកនេះមានភាពងាយស្រួលក្នុងការធ្វើដំណើរ ដោយតភ្ជាប់ជាមួយខ្សែផ្លូវណានលី(ពីឃុំលីស៊ីនស្រុកឆាងយាន់ទៅឃុំណានសានស្រុកជីនខាង) ។ ច្រកនេះមានចម្ងាយ ១០៩ គីឡូម៉ែត្រពីទីរួមស្រុកឆាងយាន់ ចម្ងាយ ២៩ គីឡូម៉ែត្រពីច្រកអន្តរជាតិទន្លេឈីងស្វយ ម៉ឹងទឹង ចម្ងាយ ៨៧ គីឡូម៉ែត្រពីច្រកអន្តរជាតិណានសានរបស់ប្រទេសចិន និងមានចម្ងាយ ២ គីឡូម៉ែត្រពីរដ្ឋបាលតំបន់សេដ្ឋកិច្ចណានតឹង ចម្ងាយ ២៤ គីឡូម៉ែត្រពីហ្វូប៉ាន ចម្ងាយ ១៦០ គីឡូម៉ែត្រពីឡាស្វយរបស់ប្រទេសមីយ៉ាន់ម៉ា ។ និយាយរួម វាគឺជាច្រកដ៏សំខាន់មួយសម្រាប់ធ្វើដំណើរពីខេត្តយូណានប្រទេសចិនទៅកាន់ប្រទេសមីយ៉ាន់ម៉ា ។ ច្រកម៉ាងខាជាច្រកសំខាន់មួយរបស់ស្រុកឆាងយាន់ ក្នុងការអនុវត្តគោលនយោបាយបើកទូលាយនិងធ្វើពាណិជ្ជកម្មតាមព្រំដែនដោយមានល័ក្ខខ័ណ្ឌគមនាគមន៍និងទីតាំងភូមិសាស្ត្រដ៏មានឧត្តមានុភាព ។

ច្រកយ៉ុងហ៊ីមានចម្ងាយ ១៤ គីឡូម៉ែត្រពីទីរួមស្រុក និងមានចម្ងាយ ៣ គីឡូម៉ែត្រពីតំបន់សុផាតនៃរដ្ឋវ៉ានៃប្រទេសមីយ៉ាន់ម៉ា ។ នៅក្នុងតំបន់ពាណិជ្ជកម្មនៃច្រកម៉ាងខានិងច្រកយ៉ុងហ៊ី សុទ្ធតែមានផ្លូវតភ្ជាប់នឹងបរទេស ដែលបានបង្កើនភាពងាយស្រួលក្នុងការធ្វើដំណើរ និងជាច្រកអន្តរជាតិសំខាន់សម្រាប់ធ្វើដំណើរពីភូមិភាគនិរតីប្រទេសចិនទៅតំបន់អាស៊ីអាគ្នេយ៍ ។

នៅច្រកអន្តរជាតិឆាងយាន់មានទីលានមួយសម្រាប់ស្តុកទំនិញនាំចេញនាំចូល ហើយនៅមានផ្សារធ្វើពាណិជ្ជកម្មតាមព្រំដែនចំនួន ៦ ទៀត ។ កាលពីមុន ការធ្វើពាណិជ្ជកម្មតាមច្រកអន្តរជាតិនេះមានខ្នាតតូច ហើយគ្រាន់តែធ្វើពាណិជ្ជកម្មជាមួយតំបន់ពិសេសណានតឹងនិងតំបន់សុផាតនៃរដ្ឋវ៉ានៃប្រទេសមីយ៉ាន់ម៉ាប៉ុណ្ណោះ តែសព្វថ្ងៃបានរីកចម្រើនយ៉ាងខ្លាំង ដោយមានទំនាក់ទំនងជាមួយនឹងរដ្ឋបាលតំបន់ហ្វូប៉ាន នុងគួន ឡាស្វយ និងម៉ាន់ដាឡេជាដើមនៃប្រទេសមីយ៉ាន់ម៉ា ។





# កសាងទីក្រុងស្រែចំការទំនើបកម្ម លើកស្ទួយកម្រិតជីវភាពរស់នៅនិងសម្រេចសុបិនរបស់ប្រជាជន




តំបន់ស៊ីសៀនរបស់ខេត្តសាន់ស៊ីបង្កើតកិច្ចសហប្រតិបត្តិការយុទ្ធសាស្ត្រជាមួយក្រុមហ៊ុន Microsoft ដោយមានគម្រោងវិនិយោគធំចំនួន ៥ នៅក្រុងហ្វឹងស៊ីថ្មី
陕西西咸新区与微软达成战略合作 五大项目落户沣西新城 cfp 图

## 建现代田园城市　重民生圆百姓梦

2014年初，陕西省西咸新区获国务院批复成为国家级新区，其发展已经上升为国家战略层面。

西咸新区规划面积882平方公里，位于西安、咸阳两座历史文化名城之间。泾河新城是西咸新区五大组团之一，遵循“核心板块支撑、快捷交通连接、优美小镇点缀、都市农业衬托”的开发建设理念，着力打造现代田园城市，大西安北部中心。西咸新区泾河新城成立两年来，创新城市发展方式，改善民生、产业联动、产城一体，带动当地社会经济快速发展，成果显著。（翟茜茜　译）

នៅដើមឆ្នាំ ២០១៤ ក្រុមប្រឹក្សាកិច្ចការរដ្ឋចិនបានអនុម័តឱ្យតំបន់ស៊ីសៀនរបស់ខេត្តសាន់ស៊ីជាតំបន់ថ្មីថ្នាក់ជាតិ ដែលបានត្រូវដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ប្រទេសចិន ។

តាមផែនការអភិវឌ្ឍន៍តំបន់ស៊ីសៀនមានផ្ទៃក្រឡា ៨៨២ គីឡូម៉ែត្រការ៉េ ស្ថិតនៅចន្លោះរវាងក្រុងបុរាណល្បីឈ្មោះពីរ គឺក្រុងស៊ីអាននិងក្រុងសៀនយ៉ាង ។ ក្រុងថ្មីជីងហ៊ីគឺជាផ្នែកដ៏សំខាន់មួយក្នុងចំណោមផ្នែកទាំង ៥ នៃតំបន់ស៊ី សៀនខាងលិច ដោយបានគោរពតាមទស្សនៈអភិវឌ្ឍន៍“យកចំណុចអភិវឌ្ឍន៍ស្នូលធ្វើជាសសរទ្រូង តភ្ជាប់គ្នាដោយប្រព័ន្ធគមនាគមន៍ដែលមានលក្ខណៈងាយស្រួលកសាងឃុំសង្កាត់ស្រស់ស្អាតធ្វើជាការលម្អនិងអភិវឌ្ឍន៍វិស័យកសិកម្មក្នុងទីក្រុង”ខិតខំប្រឹងប្រែងដើម្បីកសាងទីក្រុងស្រែចំការទំនើបកម្មនិងបង្កើតមជ្ឈមណ្ឌលភាគខាងជើងក្រុងស៊ីអានធំ ។ ក្នុងរយៈពេល ២ ឆ្នាំបន្ទាប់ពីក្រុងថ្មីជីងហ៊ីនៃតំបន់ស៊ីសៀនត្រូវបានបង្កើតឡើងរៀងមក របៀបអភិវឌ្ឍន៍ក្រុងថ្មីដែលផ្តោតសំខាន់លើការកែលម្អជីវភាពរស់នៅរបស់ប្រជាជន អភិវឌ្ឍន៍មុខរបរផ្សេងៗដោយរួមគ្នានិងដាក់បញ្ចូលការអភិវឌ្ឍន៍មុខរបរទៅក្នុងទីក្រុងបាននាំមកនូវការអភិវឌ្ឍន៍សេដ្ឋកិច្ចយ៉ាងឆាប់រហ័សដល់តំបន់និងបានទទួលនូវសមិទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ។

ក្នុងនាមជាក្រុងថ្មីមួយ ក្រុងថ្មីជីងហ៊ីនៃតំបន់ស៊ីសៀនបានប្រកាន់ខ្ជាប់នូវ“ការចាត់ទុកមនុស្សជាមូលដ្ឋាន”ជាចំណុចស្នូលក្នុងការអភិវឌ្ឍន៍ទីក្រុង ព្រមនិងរៀបចំឱ្យបានល្អប្រសើរនូវទំនាក់ទំនង ៣ ផ្នែក គឺទំនាក់ទំនងរវាងមនុស្សនិងធម្មជាតិ ទំនាក់ទំនងរវាងមនុស្សនិងសង្គមនិងទំនាក់ទំនងរវាងមនុស្សនិងមនុស្ស ។

មុខរបរគឺជាមូលដ្ឋាននៃការអភិវឌ្ឍន៍ទីក្រុង នៅពេលដំបូងដែលបង្កើតក្រុងជីងហ៊ីថ្មីនៃតំបន់ស៊ីសៀន គេបានលើកឡើងនូវទស្សនៈអភិវឌ្ឍន៍ដែលមានខ្លឹមសារៈសំខាន់ថា“បង្កើតតំបន់ឧស្សាហកម្ម លើកកម្ពស់ទំនើបកម្មកសិកម្ម ប្រើប្រាស់ដីដោយវិទ្យាសាស្ត្រ ជំរុញដំណើរនគរូបនីយកម្មនិងកសាងទីក្រុងស្រែចំការ” ។ ការលើកឡើងនិងអនុវត្តទស្សនៈអភិវឌ្ឍន៍ទាំង ៦ ចំណុចខាងលើ បាននិងកំពុងដើរតួនាទីគន្លឹះ ក្នុងការដោះស្រាយបញ្ហាជនបទ កសិកម្មនិងកសិករ ព្រមនិងបញ្ហារក្សាតុល្យភាពរវាងទីក្រុងនិងជនបទ ។ ប៉ុន្តែចំពោះទីក្រុងថ្មីមួយដែលកំពុងធ្វើនគរូបនីយកម្មនោះ បញ្ហាប្រជាកសិករគឺជាបញ្ហាធំនិងសំខាន់បំផុតក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។ សព្វថ្ងៃនេះ ក្រោមការគាំទ្រយ៉ាងពេញទំហឹងពីក្រុងសៀនយ៉ាងនិងស្រុកជីងយ៉ាង ប្រជាកសិករជាច្រើនដែលរស់នៅក្នុងភូមិដ្ឋាននានានៅក្រុងថ្មីជីងយ៉ាងនៃតំបន់ស៊ីសៀនកំពុងប្រែអត្តសញ្ញាណពីកសិករទៅជាអ្នកក្រុង និងប្រកបរបរជាកម្មករ ឬជាអ្នកធ្វើការលើវិស័យសេវាកម្ម ។ ការប្រែប្រួលនៃអត្តសញ្ញាណនិងការងាររបស់ខ្លួន នឹងអាចជួយពន្លឿនដំណើរនគរូបនីយកម្មក្នុងរយៈពេលយូរអង្វែង ។

ផ្តោតសំខាន់លើការអភិវឌ្ឍន៍វិស័យកសិកម្ម ជំរុញការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មដោយព្រមពេលជាមួយគ្នា និងកសាងទីក្រុងថ្មីមួយដែលស័ក្តិសមនឹងការរស់នៅរបស់ប្រជាជន ។ ក្រុងជីងយ៉ាងថ្មីនៃតំបន់ស៊ីសៀនចាត់ទុកការអភិវឌ្ឍន៍ថាមពលថ្មី និងការប្រើប្រាស់សម្ភារៈថ្មីជាគោលប្រមូលផ្តុំនូវផលិតកម្មកម្រិតខ្ពស់ ព័ត៌មានភូមិសាស្ត្រ ចរាចរណ៍ទំនិញទំនើប និងមុខរបរផ្សេងៗទៀត ឆ្លងតាមរយៈការអភវិឌ្ឍន៍ដោយរួមគ្នា បង្កើតឡើងនូវតំបន់គំរូផ្នែកសេវាកម្មទំនើប តំបន់គំរូផ្នែកកសិកម្មទំនើប និងតំបន់គំរូនៃការអភិវឌ្ឍន៍ទីក្រុងនិងជនបទដោយមានតុល្យភាព ។ និយាយចំពោះការអភិវឌ្ឍន៍ ក្រុងជីងយ៉ាងថ្មីនៃតំបន់ស៊ីសៀនមិនមែនផ្តោតលើការអភិវឌ្ឍន៍វិស័យតែមួយទេ ពោលគឺអភិវឌ្ឍន៍វិស័យសំខាន់ទាំង ៣ (ឧស្សាហកម្ម កសិកម្ម និងសេវាកម្ម)ដោយរួមគ្នា ។ ទាំងនេះ គឺជាលក្ខណៈពិសេសមួយរបស់ក្រុងជីងហ៊ីថ្មីនៃតំបន់ស៊ីសៀនដែលនឹងអាចបង្កើតឡើងនូវមុខរបរគ្រប់គ្រាន់សម្រាប់ការទ្រទ្រង់យ៉ាងរឹងមាំ និងផ្តល់សេវាកម្មយ៉ាងល្អប្រសើរដល់ការអភិវឌ្ឍន៍ទីក្រុង ។



រថភ្លើងចេញពីផ្លូវក្រោមដីកំណាត់ស៊ីសៀននៃខ្សែផ្លូវរថភ្លើងក្រោមដីលេខ ១ របស់ក្រុងស៊ីអាន កម្មករសាងសង់គ្រវីទង់អបអរសាទរ
轨道车驶出西安地铁一号线西咸车辆段隧道出口，施工人员挥旗庆祝　新华社 图

# សហគមន៍ចិននិងអាស៊ានជំរុញដល់ការអភិវឌ្ឍន៍និងស្ថិរភាពក្នុងតំបន់




ថ្នាក់ដឹកនាំនៃប្រទេសនានាកំពុងពិគ្រោះពិភាក្សាអំពីការកសាងសហគមន៍អាស៊ានក្នុងសន្និសីទថ្នាក់ដឹកនាំអាស៊ានលើកទី ២៤

第24届东盟领导人会议讨论共同体建设　新华社 图

## 中国东盟共同体促进地区稳定发展

中国—东盟商务理事会主编的2014年第一季度《中国—东盟自贸区季度报告》显示，中国与东盟今年经贸合作形势总体良好，双方打造升级版自贸区工作正在有序推进。《报告》显示，2014年第一季度，中国和东盟贸易总额达到1052.2亿美元，同比增长4.9%，显示了中国与东盟经贸合作的旺盛生命力。

យោងតាម“របាយការណ៍ប្រចាំត្រីមាសទី ១ នៃឆ្នាំ ២០១៤ ស្ដីពីតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន”របស់ក្រុមប្រឹក្សាពាណិជ្ជកម្មចិន-អាស៊ានបានឱ្យដឹងថា និន្នាការសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មមានភាពល្អប្រសើរ ហើយការលើកកម្ពស់កម្រិតថ្នាក់នៃតំបន់ពាណិជ្ជកម្មសេរីរបស់ភាគីទាំងពីរកំពុងតែឈានទៅមុខជាលំដាប់លំដោយ ។ តាមរបាយការណ៍នេះបានបង្ហាញថា នៅត្រីមាសទី ១ នៃឆ្នាំ ២០១៤ ទំហំពាណិជ្ជកម្មរវាងចិននិងអាស៊ានមានដល់ទៅ ១០៥ ២២០ លានដុល្លារអាមេរិក ដែលកើនឡើង ៤,៩% បើប្រៀបធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ដែលបានបង្ហាញពីកម្លាំងរស់រវើកនៃកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងប្រទេសចិននិងអាស៊ាន ។

អ្នកជំនាញការគ្រប់មជ្ឈដ្ឋានក្នុងសង្គមអាស៊ានបានលើកមតិថា ការអភិវឌ្ឍន៍ដោយសន្តិភាពនិងកំណើនសេដ្ឋកិច្ចដោយមានស្ថិរភាពរបស់ប្រទេសចិនបានបង្កើតជាកាលានុវត្តភាពដ៏សំខាន់សម្រាប់ការអភិវឌ្ឍន៍នៃតំបន់ទាំងមូល ។ ទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រចិន-អាស៊ានមិនគ្រាន់តែនឹងអាចនាំមកនូវផលប្រយោជន៍ដល់ភាគីទាំងពីរប៉ុណ្ណោះទេ ហើយថែមទាំងនឹងអាចចូលរួមចំណែកក្នុងការពង្រឹងនិងពង្រីកសន្តិភាព ស្ថិរភាពនិងការអភិវឌ្ឍន៍ក្នុងតំបន់ ។ ភាគីទាំងពីរមិនគ្រាន់តែមានកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ដែលមានកម្រិតកាន់តែខ្ពស់ប៉ុណ្ណោះទេ ហើយការជឿទុកចិត្តគ្នាផ្នែកនយោបាយនិងសន្តិសុខក៏ត្រូវបានពង្រឹងនិងពង្រីកឥតឈប់ឈរដែរ ។ កិច្ចសហប្រតិបត្តិការមេត្រីភាពរវាងចិននិងអាស៊ាននឹងអាចធ្វើឱ្យប្រជាជនដែលមានចំនួនប្រហែល ២០០០ លាននាក់ស្មើនឹងជិត ១ ភាគ ៣ នៃចំនួនសរុបនៃប្រជាជនទូទាំងពិភពលោក ទទួលបានផលប្រយោជន៍យ៉ាងច្រើនសន្ធឹកសន្ធាប់ ។

ខណៈពេលទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រចិន-អាស៊ានបានឈានដល់ដំណាក់កាលទសវត្សរ៍ទី ២ ប្រទេសចិននិងអាស៊ានចាំបាច់ត្រូវតែបង្កើនទំនាក់ទំនងជាយុទ្ធសាស្ត្រពង្រីកឱ្យស៊ីជម្រៅនូវកិច្ចសហប្រតិបត្តិការផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមក បង្កើតជាសហគមន៍វាសនាតែមួយចិន-អាស៊ានសហគមន៍ផលប្រយោជន៍រួមនិងសហគមន៍ភារកិច្ចរួម ។

ក្នុងសន្និសីទឧត្តមមន្ត្រីចិន-អាស៊ានលើកទី ២០ ដែល




ពិធីចុះហត្ថលេខាលើគម្រោងពិព័រណ៍ចិន-អាស៊ានលើកទី ៨ ប្រារព្ធធ្វើយ៉ាងអធិកអធមនៅក្រុងណាននីង ក្វាងស៊ី

广西南宁市举行的第八届中国—东盟博览会项目签约仪式规模庞大　新华社 图




វេទិកាពាណិជ្ជកម្មគ្រឿងសមុទ្រចិន-អាស៊ានបើកស្លាកនៅស្រុកម៉ាវៃ ក្រុងហ្វូចូវ
中国—东盟海产品交易平台在福州马尾揭牌　cnsphoto

ប្រារព្ធនៅក្រុងប៉ាតាយ៉ាប្រទេសថៃនាខែមេសា ឆ្នាំនេះ អង្គប្រជុំបានពិភាក្សាជាសំខាន់ចំពោះការធ្វើពាណិជ្ជកម្មនិងសេដ្ឋកិច្ច ការកសាងហេដ្ឋារចនាសម្ព័ន្ធ កិច្ចសហប្រតិបត្តិការលើសមុទ្រ និងការផ្លាស់ប្តូរវប្បធម៌ជាដើម ក្នុងនោះមានការលើកកម្ពស់កម្រិតថ្នាក់នៃតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ហើយខិតខំប្រឹងប្រែងដើម្បីសម្រេចតាមគោលដៅដែលមានទំហំពាណិជ្ជកម្មទ្វេភាគី ១.០០០.០០០ លានដុល្លារអាមេរិកនៅឆ្នាំ ២០២០ ។

លោកលី ជៀនស្យុង ប្រធានផ្នែកកិច្ចការសាធារណៈនៃលេខាធិការដ្ឋានអាស៊ាន បានថ្លែងថា ការលើកកម្ពស់កម្រិតថ្នាក់នៃតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ប្រាកដជានឹងអាចក្លាយទៅជាពលានុភាពកាន់តែខ្លាំងសម្រាប់ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងតំបន់ ហើយក៏នឹងអាចនាំមកនូវផលប្រយោជន៍ថ្មីដល់ប្រជាជនអាស៊ាន ក៏ដូចជាប្រជាជននៃប្រទេសនានាក្នុងតំបន់ផងដែរ ។ លោកសៀ នីងនីង នាយកប្រតិបត្តិនៃក្រុមប្រឹក្សាពាណិជ្ជកម្មចិន-អាស៊ានបានបញ្ចេញយោបល់ថា ការច្នៃប្រឌិតថ្មី និងការធ្វើកិច្ចសហប្រតិបត្តិការជាក់ស្តែងគឺជាកិច្ចការប្រឈមសម្រាប់លើកកម្ពស់កម្រិតថ្នាក់នៃតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ត្រូវតែពិគ្រោះពិភាក្សាអំពីការបង្កើតខ្សែសង្វាក់ឧស្សាហកម្មតាមរយៈការតភ្ជាប់ឧស្សាហកម្មប្រភេទផ្សេងៗ ដើម្បីសម្រេចបានគោលដៅឈ្នះ-ឈ្នះទាំងសងខាង ។

លោកនៅបានបញ្ជាក់ទៀតថា ការកសាងផ្លូវសូត្រលើសមុទ្រនឹងអាចជំរុញការយោគយល់និងទំនាក់ទំនងមិត្តភាពរវាងប្រជាជនទ្វេភាគី ព្រមនិងផ្តល់ផលប្រយោជន៍ដល់ការអនុវត្តតាមគោលនយោបាយការទូតដែលគោរពរាប់អានជាមួយប្រទេសជិតខាង ។ ការកសាងតំបន់សេដ្ឋកិច្ចផ្លូវសូត្រនិងផ្លូវសូត្រលើសមុទ្រ មិនត្រឹមតែនឹងអាចពង្រីកទ្រង់ទ្រាយបើកទូលាយរបស់ចិនចំពោះបរទេសប៉ុណ្ណោះទេ ថែមទាំងនឹងអាចជំរុញការកែសម្រួលរចនាសម្ព័ន្ធឧស្សាហកម្មចិនឱ្យមានក្របខ័ណ្ឌកាន់តែទូលំទូលាយទៀតផង ។ ទាំងនេះនឹងអាចនាំមកនូវផលប្រយោជន៍ខាងសេដ្ឋកិច្ចដល់ប្រទេសតាមផ្លូវសូត្រលើសមុទ្រ និងប្រទេសនានាដែលនៅក្រៅតំបន់សេដ្ឋកិច្ចផ្លូវសូត្រ ដូចជាប្រទេសអាមេរិកនិងសហភាពអឺរ៉ុប ដែលសុទ្ធតែជាប្រទេសឬតំបន់ដែលមានទំនាក់ទំនងសេដ្ឋកិច្ចស្អិតល្មួតជាមួយប្រទេសអាស៊ាន ។

ទំនាក់ទំនងភាពជាដៃគូយុទ្ធសាស្ត្រចិន-អាស៊ានបានក្លាយជាសសរទ្រូងសម្រាប់គាំពារសន្តិភាព និងស្ថិរភាពក្នុងតំបន់ ហើយនិងអាចមានតួនាទីកាន់តែលេចធ្លោទៀតនាពេលអនាគត ។



ការសាងសង់“ច្រកផ្លូវណាននីង-សឹង្ហបុរី”បើកទំព័រថ្មីនៃការអភិវឌ្ឍន៍តំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន
“南新通道”建设勾勒中国—东盟自贸区发展新篇章　新华社 图



កិច្ចសហប្រតិបត្តិការរវាងទីក្រុងកំពង់ផែចិន-អាស៊ានផ្តល់កម្លាំងចលករដល់ការកសាងកំពង់ផែពាណិជ្ជកម្មសេរីនៅក្រុងឈីនចូវ ក្វាងស៊ី
中国—东盟港口城市合作助力广西钦州开启自由贸易港区梦想　新华社 图



តំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ានបានធ្វើឱ្យផ្លែឈើរបស់ប្រទេសអាស៊ានចូលមកដល់ទីផ្សារតូចធំក្នុងក្រុងណាននីង
自贸区让东盟各国水果走进南宁大街小巷　新华社 图



អាស៊ានក្លាយជាដៃគូពាណិជ្ជកម្មថ្មីសម្រាប់ជំរុញការនាំចេញផលិតផលវាយនភ័ណ្ឌចិន
东盟成中国纺织服装外贸增长新亮点　新华社 图

# តំបន់ពាណិជ្ជកម្មសេរីជំរុញការអភិវឌ្ឍន៍វិស័យចរាចរណ៍ទំនិញឆ្លងដែនរវាងប្រទេសចិននិងអាស៊ាន

## 自贸区催热中国—东盟跨国物流

装有山竹、火龙果、荔枝等东南亚水果的越南大货车一辆接着一辆进入贸易市场，训练有素的中越工人迅速卸货，然后装上早已经在等待的挂有中国各地牌照的货车，运往中国各地……在位于中越边境线上的广西凭祥市浦寨边境贸易区，繁忙的水果贸易物流场景每天都在上演。

រថយន្តវៀតណាមដែលដឹកមង្ឃុត ស្រកានាគ គូលែន និងផ្លែឈើមកពីអាស៊ីអាគ្នេយ៍បានចូលក្នុងទីផ្សារពាណិជ្ជកម្មជាបន្តបន្ទាប់ រួចមានកម្មករដ៏ប៉ិនប្រសប់បានយកផ្លែឈើទាំងនោះដាក់ចូលក្នុងរថយន្តចិនដែលមកពីគ្រប់ខេត្តក្រុង និងចេញដំណើរទៅកាន់តំបន់នានានៃប្រទេសចិនភ្លាមៗ...ទិដ្ឋភាពចរាចរណ៍ទំនិញដ៏មមាញឹកនេះគេអាចមើលឃើញជាញឹកញាប់នៅតំបន់ពាណិជ្ជកម្មតាមព្រំដែនភូចាយ ក្នុងក្រុងភីងសៀង ខេត្តក្វាងស៊ី ប្រទេសចិន ដែលមានទីតាំងស្ថិតនៅតាមព្រំដែនចិន-វៀតណាម ។

មុននឹងបង្កើតឡើងជាផ្លូវការនូវតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ាន ការធ្វើពាណិជ្ជកម្មផ្លែឈើក៏បានទទួលនូវការអនុគ្រោះពន្ធដោយបានត្រូវគេចាត់ទុកជា“ផែនការអនុវត្តមុនគេ” ។ តំបន់ពាណិជ្ជកម្មតាមព្រំដែនភូចាយ បានរីកចម្រើនយ៉ាងឆាប់រហ័សហើយក្លាយទៅជាទីផ្សារពាណិជ្ជកម្មរវាងចិននិងអាស៊ានដែលមានទ្រង់ទ្រាយធំបំផុតមួយដោយបាននាំចេញនាំចូលទំនិញផ្លែឈើចំនួនសរុប ៨៧ ម៉ឺនតោននៅឆ្នាំទៅ ដែលមានតម្លៃស្មើនឹងជាង ៣ ៣០០ លានយ៉ាន់ ។



រថយន្តកាម៉ុងដឹកទំនិញរបស់វៀតណាមចូលមកដល់តំបន់ពាណិជ្ជកម្មតាមព្រំដែនភូចាយក្នុងក្រុងភីងសៀង
装满货物的越南卡车进入凭祥浦寨 cnsphoto

មិនតែប៉ុណ្ណោះទេ ក្រុងភីងសៀងក៏ជាទីផ្សារលក់ដូរឈើទាលធំជាងគេបំផុតមួយក្នុងប្រទេសចិន ដែលមានឈើទាលនាំចូលមកពីប្រទេសឡាវ កម្ពុជា និងវៀតណាមជាដើមត្រូវបានគេដឹកជញ្ជូនមកដល់ទីនេះ រួចនឹងលក់ដូរទៅគ្រប់ខេត្តក្រុងនៃប្រទេសចិន ។ តាមស្ថិតិនៅឆ្នាំ ២០១៣ ឈើទាលនាំចេញនាំចូលតាមច្រកអន្តរជាតិភីងសៀង មានបរិមាណ ១,១ ម៉ឺនតោន ។

ការរីកចម្រើនយ៉ាងឆាប់រហ័សលើវិស័យពាណិជ្ជកម្មតាមព្រំដែនបានជំរុញការអភិវឌ្ឍន៍ចរាចរណ៍ទំនិញ ។ តាមការឧទ្ទេសនាមពីបុគ្គលិកការងារនៃក្រុមហ៊ុនចរាចរណ៍ទំនិញ ភឹងថៃ ក្រុងភីងសៀងបានឱ្យដឹងថា សព្វថ្ងៃនេះ ក្នុងក្រុងភីងសៀងមានក្រុមហ៊ុនចរាចរណ៍ទំនិញប្រហែល ៧០-៨០ ក្រុមហ៊ុន តែនៅ ៥-៦ ឆ្នាំមុន មានត្រឹមតែ ៤-៥ ក្រុមហ៊ុនប៉ុណ្ណោះ ។ បុគ្គលិកការងាររូបនេះបញ្ជាក់ទៀតថា រថយន្តដឹកជញ្ជូនដែលចុះបញ្ជីនៅក្រុមហ៊ុនគាត់មានជាង ៧០០ គ្រឿង ដែលសុទ្ធតែជាកម្មសិទ្ធិឯកជន ។ ក្រុមហ៊ុនចរាចរណ៍ទំនិញមានទម្រង់ដូចអន្តរការី នៅពេលអតិថិជនមានតម្រូវការ គេនឹងទាក់ទងជាមួយក្រុមហ៊ុនចរាចរណ៍ទំនិញ ឯក្រុមហ៊ុនចរាចរណ៍ទំនិញនឹងជួយសម្របសម្រួលតែកុងរថយន្តដឹកទំនិញឱ្យទទួលបន្ទុកការងារដឹកជញ្ជូនទំនិញ ។


កម្មករកំពុងលើកដាក់ទំនិញផ្លែឈើនៅទីលានស្តុកទំនិញក្នុងតំបន់ពាណិជ្ជកម្មតាមព្រំដែនភូចាយ
工人在浦寨边贸点天源货场装卸水果 cnsphoto

ការរីកចម្រើនលើវិស័យចរាចរណ៍ទំនិញនៅក្រុងភីងសៀង បានបង្ហាញឱ្យឃើញពីការអភិវឌ្ឍន៍វិស័យចរាចរណ៍ទំនិញរវាងប្រទេសចិននិងអាស៊ាន ។ ទន្ទឹមនឹងការជំរុញការអភិវឌ្ឍន៍តំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ានឱ្យកាន់តែស៊ីជម្រៅ ប្រព័ន្ធផ្លូវគោកសម្រាប់ដឹកជញ្ជូនទំនិញក៏មានស្ថានភាពកាន់តែល្អប្រសើរឡើង ។ បច្ចុប្បន្ន ផ្លូវថ្នល់សំខាន់ៗចំនួនជិត ១០ ខ្សែសម្រាប់ដឹកជញ្ជូនទំនិញត្រូវបានបញ្ចប់ការសាងសង់ជាស្ថាពរ ដែលបានតភ្ជាប់ប្រទេសចិននិងអាស៊ាននិងបានជំរុញយ៉ាងខ្លាំងដល់កិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសចិននិងបណ្តាប្រទេសអាស៊ាននានា ។



រថយន្តវៀតណាមដឹកគូលែនចូលមកដែនប្រទេសចិន
满载荔枝的越南货车入境 cnsphoto


ទេសចរកំពុងទិញទំនិញនៅ“អគារខ្លោងទ្វារប្រទេស”នៅតំបន់ពាណិជ្ជកម្មតាមព្រំដែនភូចាយ
游客在浦寨边贸点“国门大厦”购物 cnsphoto

# ប្រទេសចិននិងកម្ពុជាមាននិស្ស័យជ្រាលជ្រៅ ផ្លាស់ប្តូរនិងរៀនសូត្រពីគ្នាទៅវិញទៅមកច្រើនអនេក

## 中柬因缘深 交流互鉴多

对于多数中国人来说，柬埔寨既神秘又陌生，但踏入柬埔寨，随处可见的中国“缘”，让这个近邻变得熟悉而亲切。

និយាយចំពោះជនជាតិចិនមួយចំនួនធំ កម្ពុជាគឺជាប្រទេសមួយដែលប្រកបដោយភាពអាថ៌កំបាំង ឬជាប្រទេសមួយដែលមិនធ្លាប់ស្គាល់ច្បាស់ ប៉ុន្តែបើចូលមកដល់ទឹកដីអច្ឆរិយៈនេះ បែរជាអាចមើលឃើញនូវកត្តាចិននៅគ្រប់ទីកន្លែង ធ្វើឱ្យពួកគេកាន់តែស្និទ្ធទៅនឹងប្រទេសកម្ពុជាដែលជាអ្នកជិតខាងរបស់ចិន ។

-ទេសចរណ៍ៈ មនោសញ្ចេតនាចិន

ប្រាសាទអង្គរវត្តគឺជាអច្ឆរិយវត្ថុដ៏ត្រចះត្រចង់របស់កម្ពុជា ហើយក៏ធ្លាប់ធ្វើឱ្យគេមានអារម្មណ៍សោកស្តាយផងដែរ ។

នៅឆ្នាំ គ.ស ១២៩៦ លោកជីវ តាក្វាន់ បានទៅបំពេញបេសកកម្មនៅចេនឡា បន្ទាប់ពីលោកទៅដល់អង្គរវត្ត លោកបាននិពន្ធសៀវភៅ“កំណត់ហេតុប្រពៃណីអ្នកស្រុកចេនឡា” ដែលបានកត់ត្រានូវភាពសម្បូរបែប និងភាពត្រចះត្រចង់របស់នគរចេនឡា ។ សៀវភៅមួយក្បាលនេះបានក្លាយជាឯកសារប្រវត្តិសាស្ត្រដ៏កម្រសម្រាប់សិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រកម្ពុជា ។



ស្ពានជ្រោយចង្វាថ្មីដែលជាស្ពានមិត្តភាពចិននិងកម្ពុជាទី ៥ និងជាជំនួយរបស់ប្រទេសចិន បានតភ្ជាប់តួស្ពាន
中国援柬第五座友谊大桥金边水净华新桥合龙 cnsphoto

នៅប្រាសាទបាយ័នដែលឋិតនៅជិតប្រាសាទអង្គរវត្ត មានរូបចម្លាក់ទាហានចិន ដែលហាក់ដូចជាកំពុងបកស្រាយពីទំនាក់ទំនងដ៏ជិតស្និទ្ធរវាងប្រទេសទាំងពីរចិននិងកម្ពុជា ។

ជនជាតិចិនស្ទើរគ្រប់គ្នាសុទ្ធតែស្គាល់ព្រះករុណា ព្រះវររាជបិតាជាតិខ្មែរ នរោត្តម សីហនុ អតីតព្រះមហាក្សត្រកម្ពុជា ជាពិសេសប្រទេសកម្ពុជាគឺជាប្រទេសមួយដែលមានប្រជាជន ៩០% កាន់ព្រះពុទ្ធសាសនា ដូច្នេះការមានឧបនិស្ស័យជាមួយគ្នា និងវប្បធម៌ពិសេសរបស់កម្ពុជាបានទាក់ទាញភ្ញៀវទេសចរណ៍ចិនកាន់តែច្រើនឱ្យទៅទស្សនានៅប្រទេសកម្ពុជា ។ តាមស្ថិតិនៃក្រសួងទេសចរណ៍កម្ពុជាបានឱ្យដឹងថា ទេសចរចិនដែលទៅទស្សនាប្រទេសកម្ពុជានៅឆ្នាំ ២០១៣ មានជាង ៤៦ ម៉ឺននាក់ កើនឡើង ៤០% ធៀបនឹងឆ្នាំ ២០១២ ដែលបានធ្វើឱ្យប្រទេសចិនក្លាយជាប្រភពទេសចរធំទី ២ របស់ប្រទេសកម្ពុជា ។

-ទ្រព្យសម្បត្តិៈ និស្ស័យចិន

នៅឆ្នាំ ២០១០ ប្រទេសចិននិងកម្ពុជាបានបង្កើតកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ ជាហេតុនាំឱ្យទំនាក់ទំនងចិន-កម្ពុជាឈានដល់ដំណាក់កាលល្អប្រសើរក្នុងប្រវត្តិសាស្ត្រ ជាពិសេសសហគ្រាសចិនដែលទៅធ្វើអាជីវកម្មនៅប្រទេសកម្ពុជាក៏មានចំនួនកាន់តែច្រើន ។

ប្រទេសកម្ពុជាមានអាណិកជនចិនចំនួនមួយលាននាក់ រីឯជនជាតិចិនដែលចូលទៅប្រកបរបរនៅប្រទេសកម្ពុជាក្នុងអំឡុងពេលជាង ១០ ឆ្នាំកន្លងទៅមានចំនួនដល់ទៅ ៦ សែននាក់ ។ នៅតាមផ្លូវក្នុងរាជធានីភ្នំពេញ យីហោជាភាសាចិនរបស់សណ្ឋាគារ ហាងលក់ទំនិញ ឬគ្លីនិកជាដើមមាននៅគ្រប់ទីកន្លែង ។ សព្វថ្ងៃ ប្រទេសចិនបានក្លាយជាប្រភពវិនិយោគធំជាងគេរបស់ប្រទេសកម្ពុជា ដែលមានសហគ្រាសចិនបណ្តាក់ទុនលើវិស័យវារីអគ្គិសនី ធនធានរ៉ែ កសិកម្ម តំបន់អភិវឌ្ឍន៍វាយនភ័ណ្ឌ និងភោជនីយដ្ឋានជាដើម ក្នុងនោះមានចំនួន ២ ភាគ ៣ គឺជាសហគ្រាសឯកជនរបស់ចិន ។

-ភាសាចិនៈ ចរន្តក្តៅរបស់ចិន

មិនថាជនជាតិបារាំងចូលចិត្តទឹកដីខ្មែរដល់កម្រិតណាក៏ដោយ ក៏ប៉ុន្តែអ្នកចេះនិយាយភាសាបារាំងនៅប្រទេសកម្ពុជាច្រើនតែជាមនុស្សចាស់ហើយមានចំនួនតិចតួចតែប៉ុណ្ណោះ ។ ភាសាចិនដែលធ្លាប់ត្រូវបានផ្អាកឱ្យសិក្សាជាបណ្តោះអាសន្ននៅកម្ពុជា បច្ចុប្បន្នបែរជាក្លាយជាយានដ៏វិសេសវិសាលមួយសម្រាប់រកការងារធ្វើ ។




ការប្រកួតភាសាចិនមគ្គុទ្ទេសក៍“ពានរង្វាន់មិត្តភាពចិននិងកម្ពុជា”លើកដំបូង
首届“中柬友谊杯”柬埔寨中文导游演讲比赛 新华社 图

នៅសាលារៀនទួន ហ្វា ដែលបង្កើតឡើងវិញដោយលោកឧកញ៉ា ឌួង ឈីវ ប្រធានសមាគមខ្មែរចិននៅកម្ពុជាសព្វថ្ងៃគឺមានសិស្សចំនួន ១៥០០០ នាក់កំពុងសិក្សាភាសាចិនដែលត្រូវបានគេសន្មតជាសាលាភាសាចិនធំជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ ។

និយាយចំពោះគ្រួសារអាណិកជនចិននីមួយៗនៅស្រុកខ្មែរ ពួកគេសង្ឃឹមថា កូនចៅគេនឹងអាចចេះប្រើភាសាចិនដែលជាភាសារបស់ដូនតា ហើយនេះប្រហែលជាមូលហេតុសំខាន់ជាងគេដែលបានធ្វើឱ្យឪពុកម្តាយជូនកូនទៅសិក្សាភាសាចិន ។ ឯចំណែកយុវជនយុវនារីខ្មែរ បើសិនជាពួកគេរៀនចេះភាសាចិនក៏អាចចូលទៅធ្វើការក្នុងក្រុមហ៊ុនចិនបាន ដូចជាធ្វើការនៅឯតំបន់សេដ្ឋកិច្ចពិសេសនៅកំពង់ផែព្រះសីហនុ ដែលនឹងអាចធ្វើឱ្យពួកគេទទួលបានប្រាក់បៀវត្សរ៍ច្រើន ។

នៅក្នុងបណ្តាទីក្រុងនានានៅស្រុកខ្មែរ ភាសាចិនបានទទួលនូវការពេញនិយមពីមួយឆ្នាំទៅមួយឆ្នាំ ។ ទោះជាទៅផ្សារទិញទំនិញនៅភ្នំពេញក្តី ឬក៏ទៅដើរលេងនៅប្រាសាទអង្គរវត្តក្តី សុទ្ធតែនឹងអាចជួបយុវជនខ្មែរដែលចេះនិយាយភាសាចិន ។

# យូស៊ីដ៏ស្រស់ស្អាតបង្ហាញពីជីវិតដ៏សុភមង្គល

## 美丽玉溪，幸福人生

哀牢山奇峰苍翠，抚仙湖清波荡漾。美丽玉溪犹如一块温润翡翠，令人魂牵梦萦。良好的生态正成为玉溪城市发展的第一竞争力，成为人才、资金的聚宝盆，成为市民安居乐业的“幸福生产力”。

ភ្នំអៃឡាវដ៏ខៀវស្រងាត់និងបឹងហ្វូសៀនដ៏ស្រស់ត្រកាលបានធ្វើឱ្យក្រុងយូស៊ីក្លាយជាគ្រាប់ត្បូងដ៏ភ្លឺចិញ្ចាចមួយដុំ បាននិងកំពុងទាក់ទាញភ្ញៀវទេសចរណ៍ទាំងក្នុងនិងក្រៅប្រទេសចិន ។ បច្ចុប្បន្ន ប្រព័ន្ធអេកូ-ធម្មជាតិដ៏ល្អប្រសើរបានក្លាយទៅជាកម្លាំងប្រកួតប្រជែងទី ១ របស់ក្រុងយូស៊ី និងបានប្រមូលផ្តុំនូវធនធានមនុស្សនិងមូលធនដ៏ច្រើនកុះករ ហើយត្រូវបានគេប្រសិទ្ធនាមជា“កម្លាំងផលិតកម្មដ៏មានសុភមង្គល”ដែលបាននាំមកនូវសេចក្តីសុខដុមរមនាជូនប្រជាពលរដ្ឋនៅទីនោះ ។

តើក្នុងក្រុងយូស៊ីនេះមានអ្វីខ្លះ ? បឹងហ្វូសៀន បឹងស៊ីងយូន និងបឹងឈីលូនៅជាប់គ្នា ពិសេសគឺបឹងហ្វូសៀនដែលជាបឹងទឹកសាបធំជាងគេលើខ្ពង់រាបរបស់ប្រទេសចិន មានគុណភាពទឹកលំដាប់លេខ ១ ព្រមនិងភ្នំអៃឡាវ ដែលជាតំបន់អភិរក្សធម្មជាតិថ្នាក់ជាតិចិន និងជាទីតាំងសម្រាប់សង្កេតពី “រង្វង់មនុស្សជាតិនិងសត្វលោក”របស់អង្គការសហប្រជាជាតិ ។



ទេសភាពពេលរាត្រីនៃទីលានវប្បធម៌នាអឺ

聂耳文化广场夜景 cfp 图

ដើម្បីថែរក្សាបរិស្ថាននៃបឹងហ្វូសៀន យូស៊ីបានដាក់ចេញគោលនយោបាយយ៉ាងមុតមាំថា តាមរយៈការបំពេញបន្ថែមនូវគោលនយោបាយរក្សាការពារបរិស្ថាន ចាត់វិធានការដ៏មានប្រសិទ្ធភាព ដូចជាដកមនុស្សចេញ រើផ្ទះចោល ឈប់ធ្វើស្រែចំការនិងមិនប្រើប្រាស់ទឹកត្រពាំង ហើយងាកទៅរកការស្តារបឹង ស្តារទឹក និងស្តារដីសើម ដែលហៅរួមថា “គោលនយោបាយបោះបង់ចោល ៤ និងស្តារ ៣” ហើយទប់ស្កាត់នឹងការបង្ហូរទឹកស្អុយក្នុងបឹង និងកែសម្រួលរចនាសម្ព័ន្ធឧស្សាហកម្ម បំផុសឱ្យប្រជាជនទូទាំងក្រុង រួមសហការគ្នាបង្កើនការរក្សាការពារបរិស្ថាននៅបឹងហ្វូសៀន ។

ក្នុងរយៈពេល ២ ឆ្នាំខាងមុខ យូស៊ីនឹងចាត់ទុកការកសាងអរិយធម៌ធម្មជាតិជាគោលដៅសំខាន់ ដើម្បីកសាងក្រុងយូស៊ីធម្មជាតិនិងក្រុងយូស៊ីដ៏ស្រស់ស្អាត ព្រមទាំងចាត់ទុកការងារថែរក្សាបរិស្ថានលើភ្នំ តាមបណ្តោយផ្លូវសំខាន់ៗនៅជុំវិញបឹងទាំងបី និងការដាំដុះរុក្ខជាតិជាចំណុចការងារសំខាន់ ហើយសាងសង់វិស្វកម្មធំទាំង ៥ ដើម្បីបង្កើតប្រព័ន្ធអេកូឡូស៊ីបៃតង ។ ផ្តោតសំខាន់លើការដាំដុះរុក្ខជាតិនៅតាមកំណាត់ផ្លូវយូស៊ីដែលជាផ្នែកមួយនៃផ្លូវល្បឿនលឿនគុនមីង-ម៉កហាន និងផ្លូវឈឹងជាំង-ជាំងឈួន បង្កើតប្រព័ន្ធព្រៃឈើអេកូឡូស៊ីដែលរួមមានព្រៃឈើការពារក្រុង ឧទ្យានព្រៃឈើនៅជាយក្រុងនិងតំបន់ព្រៃឈើក្នុងទីក្រុង ។ ផ្តោតសំខាន់លើការកសាងអរិយធម៌អេកូឡូស៊ីនៅតាមភូមិនីមួយៗ អនុវត្តសកម្មភាព “ស្រុកកំណើតបៃតងដ៏ស្រស់ស្អាត” របស់ក្រុមគ្រួសាររាប់ម៉ឺនគ្រួសារនៃភូមិរាប់ពាន់ ដែលមានខ្លឹមសារសំខាន់ ដូចជាខិតខំដាំដុះព្រៃឈើ សម្អាតបរិស្ថានជនបទនិងផ្ទះប្រជាកសិករ ។ អនុវត្តវិស្វកម្មដាំដុះកូនឈើនៅតាមបឹងធំទាំងបី ខិតខំស្តារឡើង



តំបន់ឧស្សាហកម្មហុងថានៅក្រុងយូស៊ី

玉溪红塔工业园区 cfp 图

វិញនូវប្រព័ន្ធអេកូឡូស៊ីនៅតំបន់ដីសើម ។ បន្តអនុវត្តវិស្វកម្មដាំដុះព្រៃឈើគ្រប់ប្រភេទ ដូចជាកែប្រែដីស្រែឱ្យទៅជាដីព្រៃឡើងវិញ ដាំដុះកូនឈើលើភ្នំនិងលើកកម្ពស់គុណភាពដីព្រៃជាដើម ។

បើដើរចូលក្នុងសហគមន៍ផ្លូវតាអ៊ីងនៃខណ្ឌហុងថា លោកអ្នកនឹងអាចមើលឃើញផ្ទះដែលមានដំបូលស្អាត ក្បឿងពណ៌ប្រផេះ ជញ្ជាំងពណ៌ចម្រុះ ហាក់បីដូចជាផ្ទាំងគំនូរដ៏ស្រស់ស្អាតមួយ ពិសេសគឺផ្ទះទាំងនោះត្រូវបានព័ទ្ធព័ទ្ធដោយសួនច្បារនិងវាលស្មៅ ដែលនឹងអាចធ្វើឱ្យលោកអ្នកចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះភាពសុខដុមរមនានៃភូមិដ្ឋានទំនើបភាវូបនីយកម្មនៅទីនោះ ។ បច្ចុប្បន្ន សហគមន៍វិថីតាអ៊ីងបានក្លាយជា“គំរូនៃការរួមគ្នាស្វែងរកជីវភាពធូរធារនៅតាមជនបទចិន” និងជា“ភូមិដ្ឋានលេខ ១ របស់យូណាន”ដោយបានត្រួសត្រាយដោយជោគជ័យនូវផ្លូវមួយខ្សែដែលយកឧស្សាហកម្មមកជួយដល់ការអភិវឌ្ឍនីវិស័យកសិកម្ម និងយកសេដ្ឋកិច្ចសម្ូហភាពមកគាំទ្រការកសាងជនបទស្រស់ស្អាត ។



ទេសចរកំពុងលេងកម្សាន្តនៅឆ្នេរខ្សាច់តាម“ត្រើយសុរិយា”នៃបឹងហ្វូសៀន

游客在抚仙湖阳光海岸沙滩戏水玩耍 新华社 图



សព្វថ្ងៃនេះ នៅទូទាំងក្រុងយូស៊ីមានឃុំសង្កាត់ចំនួន ៤០ ត្រូវបានដាក់ឈ្មោះជាឃុំសង្កាត់ធម្មជាតិរបស់យូណាន ក្នុងចំណោមឃុំសង្កាត់ចំនួន ៧៥ ក្នុងក្រុងទាំងមូល ត្រូវជា ៥៣,៣% ក្នុងនោះមានឃុំសង្កាត់ចំនួន ៤ ត្រូវបានជាប់ឈ្មោះជាឃុំសង្កាត់ធម្មជាតិថ្នាក់ជាតិ ។ មិនតែប៉ុណ្ណោះទេ បន្ទាប់ពីការអនុវត្តផែនការអភិវឌ្ឍន៍ជាតិ ៥ ឆ្នាំទី ១២ រៀងមក ស្រុកធុងហៃ ខណ្ឌហុងថា និងស្រុកឈឹងជាំងបានបង្កើតឡើងនូវតំបន់គំរូនៃតំបន់អេកូឡូស៊ីថ្នាក់ជាតិ ហើយស្រុកជាំងឈួន ស្រុកហួនីងនិងស្រុកអ៊ីមិនក៏បានចាប់ផ្ដើមកសាងនូវតំបន់គំរូនៃតំបន់អេកូឡូស៊ីថ្នាក់ជាតិដែរ ដោយបានទទួលការអនុញ្ញាតពីក្រសួងបរិស្ថានចិននៅឆ្នាំ ២០១១ ។



ទេសចរកំពុងដើរកម្សាន្តនៅតំបន់ទេសភាពធម្មជាតិនៅក្រុងយូស៊ី

游人在玉溪生态景观带漫步 新华社 图

# លោហធាតុមានពណ៌នាំមុខផ្នែក “យុគសម័យលោហធាតុមិនមែនដែក”

## 有色金属引领“非铁时代”

文、图/沈 燕

尖端科技改变着一个时代，也改变着人类的生活和生存的世界，它总能够将理想变成现实。在这个科学运用迅速扩张，技术快速更新的时代，有色金属正占有着重要的地位和作用，引领人类社会进入“非铁时代”。



ផ្សារលោហធាតុមានពណ៌ផាន-អាស៊ីនៅក្រុងគុនមីង

昆明泛亚有色金属交易所

បច្ចេកវិទ្យាកំពូលកំពុងតែកែប្រែយុគសម័យរបស់យើង ហើយក៏បានកែប្រែពិភពមនុស្សជាតិផងដែរ ។ វាតែងតែអាចធ្វើឱ្យការគិតស្រមៃរបស់យើងក្លាយជាការពិត ។ ក្នុងយុគសម័យដែលបច្ចេកទេសត្រូវបានប្រើប្រាស់កាន់តែទូលំទូលាយ និងរីកចម្រើនកាន់តែឆាប់រហ័ស លោហធាតុមានពណ៌កំពុងដើរតួនាទីកាន់តែសំខាន់ និងនាំមុខផ្នែកអភិវឌ្ឍន៍សង្គមមនុស្សជាតិឱ្យឈានចូល“យុគសម័យលោហធាតុមិនមែនដែក” ។

តាំងពីដើមរៀងមក យូណានក៏ត្រូវបានគេប្រសិទ្ធនាមថា “អាណាចក្រនៃលោហធាតុមានពណ៌” ដោយសារទីនេះសម្បូរធនធានរ៉ែ ជាពិសេសគឺរ៉ែលោហៈមានពណ៌គ្រប់ប្រភេទដែលមានបង្កប់នៅតាមទីកន្លែងជាច្រើននិងមានបរិមាណច្រើនបង្គួរ ។ ក្នុងនាមជាខេត្តមួយដែលសម្បូរទៅដោយរ៉ែលោហៈមានពណ៌ យូណានមានរ៉ែសំណបាហាំង សំណ ស័ង្កសី ទង់ដែង នីកែល កូបាល់ អង់ទីម៉ូន តង់ស្តែន អាលុយមីញ៉ូមដែក ប្រាក់និងប្លាទីនជាដើម ។ ក្នុងចំណោមនោះ រ៉ែសំណមានបរិមាណ ៥៣១,៩៤ ម៉ឺនតោន រ៉ែស័ង្កសីមានបរិមាណ ១៨៩៩,៤៩ ម៉ឺនតោន ដែលបង្កប់នៅតាមតំបន់ចំនួន ១១៨ ដែលសុទ្ធតែជាប់ចំណាត់ថ្នាក់លេខ ១ ក្នុងប្រទេសចិន ។ ចំណែកឯរ៉ែទង់ដែងនៅយូណានក៏មានចំនួនច្រើនដែរ ហើយមានស្ទើរតែនៅក្នុងខេត្តទាំងមូល មានបរិមាណ ៦៩៥,០៥ ម៉ឺនតោន ដែលបង្កប់នៅតាមតំបន់ចំនួន ១៥៦ ។ រ៉ែបុកស៊ីតនៅខេត្តយូណានមានបរិមាណ ៣២ លានតោន ជាប់ចំណាត់ថ្នាក់ទី ៧ ក្នុងប្រទេសចិន ។ រ៉ែអង់ទីម៉ូនរបស់យូណានមានគុណភាពខ្ពស់ងាយស្រួលក្នុងការចម្រាញ់ ហើយមានល័ក្ខខ័ណ្ឌជីកយកល្អប្រសើរ សរុបមានបរិមាណ ២៧,០៩ ម៉ឺនតោន ជាប់ចំណាត់ថ្នាក់លេខ ៤ ក្នុងប្រទេសចិន ។ ក្រៅពីនេះ ខេត្តយូណាននៅមានរ៉ែលោហៈមានពណ៌ដែលកម្រ និងមានតម្លៃមួយចំនួនដូចជាអាំងដ្យូង ហ្សេម៉ាញ៉ូម ។ល។ មិនថាឈរលើជំហរទូទាំងប្រទេសចិន ឬក៏លើជំហរពិភពលោកទាំងមូល ខេត្តយូណានគឺមានរ៉ែលោហៈមានពណ៌ច្រើនប្រភេទគួរឱ្យកត់សម្គាល់ ។

ក្នុងនាមជាអនុផលមូលដ្ឋាននៃរ៉ែលោហៈ លោហធាតុតូចមានអត្រាមិនដល់ ៥% ទេ ក្នុងចំណោមរ៉ែលោហៈមានពណ៌ទាំងឡាយ ។ ប៉ុន្តែវាជាសម្ភារៈមូលដ្ឋាន និងសម្ភារៈយុទ្ធសាស្ត្រសំខាន់ដែលមិនអាចខ្វះបានក្នុងកិច្ចការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន ក៏ដូចជាក្នុងឧស្សាហកម្មការពារជាតិនិងបច្ចេកទេសវិទ្យាសាស្ត្រជាដើម ។ ការធ្វើទំនើបភាវូបនីយកម្មខាងកសិកម្ម ឧស្សាហកម្មនិងបច្ចេកវិទ្យា សុទ្ធតែមិនអាចខ្វះរ៉ែលោហៈមានពណ៌នេះឯងទេ ។ ម៉្យាងទៀតផលិតកម្មដែកថែបសមាសធាតុចម្រុះក៏ត្រូវពឹងផ្អែកលើរ៉ែលោហៈមានពណ៌ដែរ ដូច្នេះរ៉ែលោហៈមានពណ៌បានក្លាយជាធនធានយុទ្ធសាស្ត្រប្រភេទថ្មី និងជាធនធានរ៉ែដែលមិនអាចខ្វះបាននាពេលបច្ចុប្បន្ន ។ ប្រទេសជាច្រើនលើលោកពិសេសគឺប្រទេសអភិវឌ្ឍន៍ កំពុងខិតខំអភិវឌ្ឍន៍ឧស្សាហកម្មរ៉ែលោហៈមានពណ៌ ដើម្បីបង្កើនបរិមាណស្តុកទុកជាយុទ្ធសាស្ត្រនៃរ៉ែលោហៈមានពណ៌ ។ បច្ចុប្បន្ន រ៉ែលោហៈមានពណ៌បានក្លាយជាមូលដ្ឋានគ្រឹះខាងសម្ភារៈមួយសម្រាប់ជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ច បច្ចេកវិទ្យានិងប្រព័ន្ធការពារជាតិ ហើយក៏ជាធនធានយុទ្ធសាស្ត្រជាគន្លឹះសម្រាប់លើកកម្ពស់សមត្ថភាពចម្រុះរបស់ជាតិនិងធានាសន្តិសុខជាតិផងដែរ ។

ទន្ទឹមនឹងការពន្លឿនដំណើរសកលភាវូបនីយកម្ម និងសមាហរណកម្មសេដ្ឋកិច្ចពិភពលោក ការប្រកួតប្រជែងកម្លាំងជាតិរវាងប្រទេសនីមួយៗបានក្លាយជាការប្រកួតប្រជែងលើវិស័យបច្ចេកវិទ្យា ធនធានមនុស្ស និងធនធានធម្មជាតិ ។ ក្នុងនាមជាប្រទេសដែលមានផលិតកម្មរ៉ែលោហៈមានពណ៌ធំជាងគេ ប្រទេសចិនបានទទួលស្នាដៃជាច្រើនក្នុងការសិក្សាស្រាវជ្រាវអំពីរ៉ែលោហៈមានពណ៌ ជាពិសេសគឺលើវិស័យអភិវឌ្ឍន៍និងប្រើប្រាស់ថ្មរ៉ែលោហៈមានពណ៌ដែលមានសមាសធាតុចម្រុះនិងគុណភាពមិនសូវខ្ពស់ ។ ឯចំណែកខេត្តយូណាន ក្នុងនាមជាខេត្តមួយដែលសម្បូរដោយរ៉ែលោហៈមានពណ៌ និងមានទីតាំងភូមិសាស្ត្រយុទ្ធសាស្ត្រដ៏ល្អប្រសើរសម្រាប់បើកទូលាយចំពោះតំបន់អាស៊ីអាគ្នេយ៍នោះ ការអភិវឌ្ឍន៍ ចម្រាញ់ ប្រើប្រាស់និងអភិរក្សធនធានរ៉ែលោហៈមានពណ៌ក៏បានក្លាយជាចំណុចការងារដ៏សំខាន់មួយ ។ និយាយជារួមទៅ ខេត្តយូណានកំពុងដើរតួនាទីសំខាន់ក្នុង“យុគសម័យលោហធាតុមិនមែនដែក”មួយនេះ ដោយបានធ្វើការអភិវឌ្ឍន៍រ៉ែលោហៈមានពណ៌នាំមុខគេ ដើម្បីសម្រេចបាននូវគោលដៅស្វែងរកភាពរុងរឿងនៃប្រជាជាតិ និងធ្វើឱ្យយូណានក្លាយជាខេត្តមួយដែលមានភាពសម្បូរសប្បាយនិងចម្រុះពណ៌ ។



cfp 图

# ខេត្តយូណានលើចុងអណ្ដាត សុរាស្ដេចបុរាណយូណាន

## 舌尖上的云南：滇王老窖

有着“世界最大自然天成花园”美誉的云南罗平，属典型的亚热带季风气候，湿润温和，雨量充沛，非常适宜微生物的发酵生长及高粱种植。在这片神奇的土地上，秉承古滇国的传统酿造技艺，自然而然孕育出了源远流长、色彩斑斓的酒文化。

ស្រុកឡូភីងខេត្តយូណាន ដែលត្រូវបានគេសន្មតជា“សួនធម្មជាតិធំជាងគេបំផុតលើលោក” មានអាកាសធាតុខ្យល់មូសុងតំបន់ស៊ុបត្រូពិច ដោយមានភាពកក់ក្ដៅនិងភ្លៀងធ្លាក់គ្រប់គ្រាន់ សក្ដិសមនឹងការលូតលាស់នៃមីក្រុប និងការដាំដុះស្រូវការលាង ។ នៅលើទឹកដីដ៏អាថ៌កំបាំងនេះ ជនជាតិចិននៅខេត្តយូណានបានទទួលនិងបន្តផ្សព្វផ្សាយវិធីបិតស្រាប្រពៃណីយុគសម័យបុរាណ និងបានបង្កើតឡើងនូវវប្បធម៌សុរាដែលមានប្រវត្តិសាស្ត្រដ៏យូរអង្វែងនិងមានភាពចម្រុះពណ៌ ។

ក្រុមហ៊ុនផលិតស្រា ជូនហ៊ី ខេត្តយូណាន បានទទួលនិងប្រើប្រាស់វិធីបិតស្រារបស់ស្ដេចត្រាញ់យូណាននៅរជ្ជកាលហាននា ២០០០ ឆ្នាំមុន ដោយផ្អែកលើទឹក ខ្យល់អាកាសអាកាសធាតុ វត្ថុធាតុដើម និងល័ក្ខខ័ណ្ឌធម្មជាតិដ៏ល្អដាច់មួយចំនួនទៀតសម្រាប់បិតស្រាផលិតបាន“សុរាស្ដេចបុរាណយូណាន”ដែលជាស្រាល្បីឈ្មោះនិងមានតម្លៃខ្ពស់ ហើយទទួលបានការពេញនិយម និងការកោតសរសើរពីសំណាក់អតិថិជនតាមទីផ្សារ ។

តាមប្រភពព័ត៌មានបានឱ្យដឹងថា វិធីផលិត“សុរាស្ដេចបុរាណយូណាន”មានប្រភពពីរាជដំណាក់ស្ដេចត្រាញ់យូណាននៅរជ្ជកាលហាន ពេលនោះស្ដេចត្រាញ់យូណានព្រះនាម“ឆាងឈាំង” ធ្លាប់យកស្រាប្រភេទនេះថ្វាយស្ដេចហានវូទី ក្រោយពេលស្ដេចហានវូទីសោយសុរាប្រភេទនេះហើយ ទ្រង់ពេញព្រះទ័យយ៉ាងខ្លាំង និងបានឡាយព្រះហស្តលេខាឱ្យស្រាប្រភេទនេះថា“សុរាស្ដេចត្រាញ់យូណាន ឈ្ងុយប្រហើរ” ។

ក្រុមហ៊ុនផលិតស្រា ជូនហ៊ី ខេត្តយូណាន ត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៩៧ ដែលជាក្រុមហ៊ុនមុខងារចម្រុះមួយដែលប្រមូលផ្ដុំនូវការផលិត រក្សាទុក កែច្នៃ និងដាំដុះ ។ ក្រុមហ៊ុននេះមានដើមទុនចុះបញ្ជីចំនួន ៣០០ លានយាន់ប្រាក់ចិន ដែលអាចផលិតបានផលិតផលគ្រប់ប្រភេទសរុប ៣ ម៉ឺនតោនក្នុងមួយឆ្នាំ ។ ជារៀងរាល់ឆ្នាំក្រុមហ៊ុនអាចផលិតបានស្រាសចំនួន ៧០០០ តោន ជាប់ចំណាត់ថ្នាក់លេខ ១ ក្នុងខេត្តយូណាន ។ សព្វថ្ងៃ ក្នុងបន្ទប់ក្រោមដីសម្រាប់ស្ដុកស្រារបស់ក្រុមហ៊ុន មានស្ដុកស្រា-សចំនួន ៥០០០ តោន ជាពិសេសដោយគួបផ្សំនឹងការអភិវឌ្ឍន៍វិស័យទេសចរណ៍ និងបុព្វហេតុវប្បធម៌ស្រុកឡូភីង ក្រុមហ៊ុននេះបានបង្កើតឡើងនូវមូលដ្ឋានវប្បធម៌សុរាមួយដែលប្រមូលផ្ដុំនូវការផលិតស្រា រក្សាទុកស្រា ការចែករំលែកនិងផ្សព្វផ្សាយពីវប្បធម៌ស្រា និងការលេងកម្សាន្តជាដើម ។

បើដើរចូលក្នុងមូលដ្ឋានវប្បធម៌សុរារបស់ក្រុមហ៊ុនជូនហ៊ី បន្ទប់ក្រោមដីសម្រាប់ស្ដុកស្រាទាំង ៣៤ ដែលតភ្ជាប់គ្នានោះនឹងអាចធ្វើឱ្យលោកអ្នកមានភាពស្ញប់ស្ញែងយ៉ាងខ្លាំង ។ បន្ទប់នីមួយៗនៅជាប់គ្នា ក្នុងបន្ទប់មានសីតុណ្ហភាពល្មម គឺនៅរដូវក្ដៅវាត្រជាក់ ឯនៅរដូវរងាវាក្ដៅ ដូច្នេះដោយស្ថិតនៅក្រោមបរិស្ថានដែលមានសីតុណ្ហភាពនឹងនរ ភាពសើមល្មម និងគ្មានពន្លឺ នឹងអាចធ្វើឱ្យស្រា-សមានរសជាតិកាន់តែឈ្ងុយឆ្ងាញ់និងក្លិនកាន់តែប្រហើរ ។

សុរាស្ដេចបុរាណយូណាន គឺជាប្រភេទស្រា-សដែលមានក្លិនឈ្ងុយប្រហើរ ដោយប្រើប្រាស់ទឹកអណ្ដូងទំពាំងបាយជូរនៅជើងភ្នំប៉ៃឡាស្រុកឡូភីង ហើយបានបង្កប់នូវវប្បធម៌យ៉ាងក្រាស់ក្រែលនិងមានឈ្មោះល្បីល្បាញ ។ សុរាប្រភេទនេះបានបង្ហាញឱ្យឃើញពីទស្សនៈភេសជ្ជៈ ដែលមានប្រយោជន៍ដល់សុខភាពនាយុគសម័យថ្មីថា ផលិតដោយប្រើប្រាស់ស្បៀងសុទ្ធមានក្លិនជ្រះប្រហើរ រសជាតិឈ្ងុយឆ្ងាញ់និងមានអារម្មណ៍មិនអាចបំភ្លេចបាន ។



បន្ទប់ក្រោមដីសម្រាប់ស្ដុកស្រា

藏酒窖洞

# ក្រុងគុនមីងបោះជំហានយ៉ាងក្លៀវក្លាទៅកាន់តំបន់អាស៊ីខាងត្បូង

## 昆明大步走向南亚

资源共享、优势互补、渠道互通、相得益彰，提升国际参与性和影响力是昆明走向南亚的终极目标。区位优势、历史脉络、现实机遇同样是云南提升沿边开放型经济水平的3个优势。

ការចែករំលែកធនធានជាមួយគ្នា បង្ហាញពីឧត្តមភាពរៀងៗខ្លួន តភ្ជាប់គ្នា ផ្តល់ផលប្រយោជន៍គ្នាទៅវិញទៅមកលើកកម្ពស់ឥទ្ធិពលអន្តរជាតិគឺជាគោលដៅរួមសម្រាប់ជំរុញក្រុងគុនមីងឱ្យបោះជំហានយ៉ាងក្លៀវក្លាទៅកាន់តំបន់អាស៊ីខាងត្បូង ។ ទីតាំងភូមិសាស្ត្រ មូលហេតុប្រវត្តិសាស្ត្រនិងកាលានុវត្តភាពប្រឈម គឺជាឧត្តមភាព ៣ ចំណុចរបស់យូណានក្នុងការលើកកម្ពស់កម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចបើកទូលាយនៅតាមតំបន់ព្រំដែន ។

តាំងពីដើមឆ្នាំនេះ ទន្ទឹមនឹងការពន្លឿននូវការចូលរួមផែនការយុទ្ធសាស្ត្រ“តំបន់មួយនិងផ្លូវមួយ”របស់យូណានឆ្លងតាមរយៈក្រុងគុនមីងដែលជាសមរភូមិនៃគោលនយោ-បាយបើកទូលាយ ក្រោមប្រធានបទ“ពង្រីកទំហំពាណិជ្ជកម្មសេវាកម្ម ជំរុញការវិនិយោគនិងកិច្ចសហប្រតិបត្តិការ ពន្លឿនការតភ្ជាប់គ្នា រួមគ្នាកសាងរបៀងសេដ្ឋកិច្ច” ស្របពេលជាមួយការពង្រីកទំនាក់ទំនងរវាងតំបន់អាស៊ីខាងត្បូងនិងក្រុងគុនមីងក៏ដូចជាជាមួយខេត្តយូណានទាំងមូល បង្កើនកិច្ចសហប្រតិបត្តិ-ការនិងលើកកម្ពស់កម្រិតនៃការអភិវឌ្ឍន៍របស់ប្រទេសចិននិងបណ្តាប្រទេសអាស៊ីខាងត្បូងនានា ។

នៅឆ្នាំ ២០១៣ ទំហំពាណិជ្ជកម្មអាហារ៍ណនីហារ៍ណរវាងក្រុងគុនមីងនិងប្រទេសអាស៊ីខាងត្បូងមានចំនួន ៧២ ៧៣០ ម៉ឺនដុល្លារអាមេរិក ដែលបានកើនឡើង ៣៩,៥១% បើប្រៀបធៀបនឹងឆ្នាំ ២០១២ ។ ក្នុងនោះ ទំហំពាណិជ្ជកម្មនីហារ៍ណមានចំនួន ៦៨ ៣៣៨ ម៉ឺនដុល្លារអាមេរិក កើនឡើង ៤១,៩៧% ចំណែកទំហំពាណិជ្ជកម្មអាហារ៍ណមានចំនួន ៤ ៣៩២ ម៉ឺនដុល្លារអាមេរិក កើនឡើង ៩,៩% ។

ឆ្នាំនេះ មន្ទីរពាណិជ្ជកម្មគុនមីងបានចាត់ទុកការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចជាមួយបរទេសជាចំណុចការងារសំខាន់ ដើម្បីពង្រីកឱ្យកាន់តែស៊ីជម្រៅនូវការអនុវត្តគោលនយោបាយ “ដើរចេញទៅក្រៅ” នៅក្រុងគុនមីងទាំងមូល ។ ដោយឈរលើគោលនយោបាយ “កសាងប៉មក្បាលស្ពាន” “របៀងសេដ្ឋកិច្ចបង់ក្លាដែស ចិន ឥណ្ឌា និងមីយ៉ាន់ម៉ា”និង “កសាងតំបន់មួយនិងផ្លូវមួយ” ព្រមទាំងការកសាងតំបន់សេដ្ឋកិច្ចបើកទូលាយគុនមីង-តាលី-ប៉ាវសាន ម៉ាងស៊ី និងយូយលីតាមផែនការអភិវឌ្ឍន៍ខេត្តយូណាន ហើយជំរុញការតភ្ជាប់គ្នារវាងខេត្តយូណាននិងបណ្តាប្រទេសផ្សេងៗ បង្កើតការផ្លាស់ប្តូរនិងកិច្ចសហប្រតិបត្តិការគ្រប់ជ្រុងជ្រោយក្នុងតំបន់ ចូលរួមយ៉ាងសកម្មក្នុងកិច្ចការតំបន់ពាណិជ្ជកម្មសេរីចិន-អាស៊ានរបៀងសេដ្ឋកិច្ចបង់ក្លាដែស ចិន ឥណ្ឌា និងមីយ៉ាន់ម៉ា និងរង្វង់សេដ្ឋកិច្ចទីក្រុងនៅភាគកណ្តាលខេត្តយូណាន ។ ខិតខំប្រឹងប្រែងដើម្បីទទួលបានការគាំទ្រ ខាងនយោបាយពីរដ្ឋាភិបាលចិននិងសាលាខេត្តយូណាន លើកទឹកចិត្តសហគ្រាសរដ្ឋនិងឯកជនឱ្យ“ដើរចេញទៅក្រៅ” ធ្វើការវិនិយោគដោយប្រមូលទិញភាគហ៊ុនពីក្រុមហ៊ុនបរទេស ឬសហការគ្នាជាមួយក្រុមហ៊ុនបរទេសសិក្សាស្រាវជ្រាវអំពីគោលនយោបាយ សម្រាប់លើកកម្ពស់កម្រិតថ្នាក់នៃការដើរចេញទៅក្រៅ កែសម្រួលយន្តការសម្របសម្រួលនៃការអនុវត្តគោលនយោបាយ“ដើរចេញទៅក្រៅ” ព្រមនិងជំរុញការកសាងច្រក ដែលមានលក្ខណៈងាយស្រួលសម្រាប់ជំរុញការផ្លាស់ប្តូរធនធានមនុស្ស និងការដឹកជញ្ជូនសម្ភារៈក្នុងការធ្វើវិនិយោគនៅបរទេស ។

ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ទន្ទឹមនឹងការរីកចម្រើនកាន់តែស៊ីជម្រៅនៃកិច្ចសហប្រតិបត្តិការផ្នែកសេដ្ឋកិច្ចរវាងក្រុងគុនមីងនិងបណ្តាប្រទេសអាស៊ីអាគ្នេយ៍ និងអាស៊ីខាងត្បូង ការវិនិយោគនៅក្រុងគុនមីងរបស់ប្រទេសអាស៊ីអាគ្នេយ៍និងអាស៊ីខាងត្បូង បានគ្របដណ្តប់លើវិស័យដាំដុះបន្លែនិងផ្កាឧស្សាហកម្មផលិតកម្ម ពាណិជ្ជកម្មសេវាកម្ម ពាណិជ្ជកម្មលក់ដូរ ភោជនីយដ្ឋាន កន្លែងលេងកម្សាន្ត ឱសថសាស្ត្រ និងការគ្រប់គ្រងផ្នែកសាធារណការជាដើម ជាហេតុនាំឱ្យការអភិវឌ្ឍន៍សេដ្ឋកិច្ចបើកទូលាយរបស់គុនមីងទទួលបានសមិទ្ធផលមួយចំនួន ក៏ប៉ុន្តែនៅមិនទាន់បញ្ចេញយ៉ាងពេញលេញនូវឧត្តមភាពខាងទីតាំងភូមិសាស្ត្រនិងធនធាននោះទេ ។ បច្ចុប្បន្ន ក្រុងគុនមីងកំពុងប្រើប្រាស់ទីផ្សារនិងធនធានទាំងក្នុងនិងក្រៅប្រទេសចិន ដើម្បីផ្តោតសំខាន់ទៅលើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសអាស៊ីខាងត្បូង ។

ជាងនេះទៅទៀត សាលាក្រុងគុនមីងកំពុងពន្លឿនដំណើរដើរចេញទៅក្រៅរបស់សហគ្រាសនានាផងដែរ ។ ថ្នាក់ដឹកនាំនៃសាលាក្រុង បានដឹកនាំគណៈប្រតិភូពាណិជ្ជកម្មទៅបំពេញទស្សនកិច្ចនៅប្រទេសអាស៊ីខាងត្បូង ដោយជួបពិភាក្សាការងារដោយផ្ទាល់ជាមួយសហគ្រាសប្រទេសអាស៊ីខាងត្បូង ដើម្បីបង្កើនការទាក់ទងគ្នាផ្នែកសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ។ សាលាក្រុង ក៏បានផ្តល់ការគាំទ្រដល់សហគ្រាសនានាក្នុងការ“ដើរចេញទៅក្រៅ”និងផ្តល់ឱកាសដល់ពួកគេឱ្យចូលរួមក្នុងពិព័រណ៍អាស៊ីខាងត្បូង ។ មិនតែប៉ុណ្ណោះទេ ក៏បានលើកទឹកចិត្តឱ្យចូលរួមពិព័រណ៍ឥណ្ឌា ដើម្បីពង្រីកកិច្ចការនៅទីផ្សារប្រទេសឥណ្ឌាទៀតផង ។ គួរបញ្ជាក់ថា សាលាក្រុងគុនមីងបានផ្តោតសំខាន់លើការតភ្ជាប់ជាមួយស្ថានកុងស៊ុលនៃប្រទេសផ្សេងៗប្រចាំគុនមីង ដើម្បីឱ្យសហគ្រាសគុនមីងស្វែងយល់ជាជំហានដំបូងអំពីស្ថានភាពនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្មនិងវប្បធម៌របស់បណ្តាប្រទេសអាស៊ីខាងត្បូង ព្រមនិងឆ្លងតាមរយៈពិព័រណ៍អាស៊ីខាងត្បូង និងពិព័រណ៍បញ្ចាទិញផលិតផលអាស៊ីខាងត្បូង ដើម្បីសេពគប់មិត្តឱ្យបានច្រើន និងជំរុញការតភ្ជាប់គ្នានិងផ្តល់ផលប្រយោជន៍ទៅវិញទៅមក ។




ពន្លាសំខាន់នៃប្រទេសអាស៊ីខាងត្បូងក្នុងពិព័រណ៍អាស៊ីខាងត្បូង

南博会南亚国家主题馆　李秋菊 图

# ផ្សារលក់ផ្កា តូវណាន នៅក្រុងគុនមីង



ពាណិជ្ជករដែលមកពីគ្រប់ទិសទីកំពុងធ្វើពាណិជ្ជកម្មផ្កាស្រស់ក្នុងមជ្ឈមណ្ឌលដេញថ្លៃផលិតផលផ្កាអន្តរជាតិគុនមីង
各地客商在昆明国际花卉拍卖交易中心内进行鲜花交易 新华社 图

## 昆明斗南花市

文/沈 燕

昆明斗南花卉市场位于云南省昆明市呈贡县斗南镇迎宾大道，拥有种植鲜切花基地6000余亩，占地面积8000多平方米，是集产、供、销为一体的花卉交易批发市场，每天有2000—3000多人上市进行交易，日上市鲜花66个大类，300多个品种，日成交额350—550万元，每天有280余吨鲜切花通过航空、铁路、公路运往全国60多个大中城市，部分出口东南亚等周边国家和地区。

ផ្សារលក់ផ្កា តូវណាន ក្រុងគុនមីង ស្ថិតនៅតាមបណ្តោយមហាវិថីទទួលភ្ញៀវក្នុងឃុំតូវណាន ស្រុកឈឹងកុង ក្រុងគុនមីងខេត្តយូណាន ដែលមានទំហំសរុបជាង ៨០០០ ម៉ែត្រការ៉េ និងមានមូលដ្ឋានដាំដុះនិងកែច្នៃផលិតផលផ្កាស្រស់ទំហំជាង ៤០០ ហិកតា ។ ផ្សារនេះគឺជាផ្សារលក់ដុំផលិតផលផ្កាស្រស់មួយដែលច្របាច់បញ្ចូលនូវការដាំដុះ កែច្នៃ ផ្គត់ផ្គង់ និងលក់ដូរផលិតផលផ្កាស្រស់ ។ ជារៀងរាល់ថ្ងៃ មានពាណិជ្ជករចំនួន ២០០០-៣០០០ ចូលធ្វើពាណិជ្ជកម្មនៅទីនេះ ហើយមានទំនិញផ្កាស្រស់ ៦៦ ជំពូក សរុបជាង ៣០០ ប្រភេទ ដែលមានទំហំពាណិជ្ជកម្មប្រមាណ ៣,៥-៥,៥ លានយាន់ប្រាក់ចិនក្នុងមួយថ្ងៃៗ ។ អ្វីដែលគួរឱ្យបញ្ញាក់នោះ គឺជារៀងរាល់ថ្ងៃមានផលិតផលផ្កាស្រស់ជាង ២៨០ តោន ត្រូវបានដឹកជញ្ជូនពីផ្សារនេះទៅកាន់ទីក្រុងធំនិងមធ្យមចំនួនជាង ៦០ ក្នុងប្រទេសចិនតាមផ្លូវអាកាស ផ្លូវដែក ឬផ្លូវថ្នល់ ហើយក៏មានផលិតផលផ្កាស្រស់មួយចំនួនត្រូវបាននាំចេញទៅប្រទេសអាស៊ីអាគ្នេយ៍ផងដែរ ។

ខេត្តយូណានមានល័ក្ខខ័ណ្ឌធម្មជាតិដ៏ល្អដែលស័ក្តិសមនឹងការដាំផ្កាស្រស់ល្អៗ ដែលមានផលិតផលផ្កាស្រស់ជាប់លំដាប់ទី ១ ក្នុងរយៈពេល ១៦ ឆ្នាំជាប់នៅទូទាំងប្រទេសចិន ។ ផ្សារលក់ផ្កាតូវណាននៅក្រុងគុនមីងមិនគ្រាន់តែជាមជ្ឈមណ្ឌលលក់ដូរ និងចែកចាយផលិតផលផ្កាស្រស់សំខាន់ជាងគេរបស់យូណានប៉ុណ្ណោះទេ ហើយថែមទាំងក៏ជាមូលដ្ឋានដាំដុះ និងលក់ដូរផ្កាដ៏សំខាន់នៅទូទាំងប្រទេសចិនទៀតផង ។ សព្វថ្ងៃផ្សារលក់ផ្កា តូវណាន ចែកជាពីរផ្នែក គឺផ្សារដេញថ្លៃផលិតផលផ្កាស្រស់ខ្នាតធំ(ក៏ហៅថា“មជ្ឈមណ្ឌលដេញថ្លៃផលិតផលផ្កាអន្តរជាតិគុនមីង”) និងផ្សារលក់រាយផលិតផលផ្កាដែលរួមមានសាលពាណិជ្ជកម្មចម្រុះ សាលពាណិជ្ជកម្មផ្កាកុលាប សាលពាណិជ្ជកម្មផ្កាសម្រាប់តុបតែង និងតំបន់ពាណិជ្ជកម្មផ្កាប្រណីតជាដើម ។ ផ្សារលក់ផ្កាតូវណាននេះបានក្លាយជាគំរូមួយក្នុងការកែសម្រួលរចនាសម្ព័ន្ធកសិកម្ម ដោយមិនត្រឹមតែបានផ្តល់ឱកាសការងារជាច្រើនដល់ប្រជាពលរដ្ឋនៅយូណានប៉ុណ្ណោះទេ ហើយក៏បានលើកកម្ពស់ប្រាក់ចំណូលរបស់ប្រជាកសិករដាំដុះផ្កាទៀតផង ។ ជាពិសេស ការរីកចម្រើននៃទីផ្សារលក់ដូរផ្កាស្រស់បាននាំមកនូវការអភិវឌ្ឍន៍នៃវិស័យពាក់ព័ន្ធនិងបានធ្វើឱ្យឃុំតូចៗនៅតាមតំបន់ជនបទមានភាពរីកចម្រើនគួរឱ្យកត់សម្គាល ។

ក្នុងនាមជាមជ្ឈមណ្ឌលដេញថ្លៃផលិតផលផ្កាខ្នាតធំដែលមានទ្រង់ទ្រាយធំជាងគេនៅក្រុងគុនមីង និងជាទីផ្សារដេញថ្លៃផលិតផលផ្កាដាំដុះក្នុងបន្ទប់ដែលធំជាងគេនៅប្រទេសចិន មជ្ឈមណ្ឌលដេញថ្លៃផលិតផលផ្កាអន្តរជាតិគុនមីងមានបរិមាណផលិតផលផ្កាលក់ដេញថ្លៃដែលជាប់ចំណាត់ថ្នាក់លេខ ២ ក្នុងទ្វីបអាស៊ី។ សព្វថ្ងៃ មានប្រជាកសិករដាំដុះផ្កាចំនួន ២,៣ ម៉ឺននាក់ បានចូលរួមជាសមាជិកនៃមជ្ឈមណ្ឌលនេះ ហើយមានពាណិជ្ជករដេញថ្លៃចំនួនជាង ២១០០ នាក់ដែលមកពីគ្រប់ទិសទីក្នុងប្រទេសចិន ដោយអាចទិញលក់ផលិតផលផ្កាស្រស់ជាង ២ លានទងក្នុងមួយថ្ងៃ នៅពេលខ្លះក៏អាចកើនដល់ ៥ លានទងទៀតផង ។ ផ្កាស្រស់ដែលដាក់លក់នៅមជ្ឈមណ្ឌលនេះមានជាង ១០០ ប្រភេទ ដែលមានទំហំពាណិជ្ជកម្មនាំចេញជាង ២០០ លានយាន់ប្រាក់ចិន ។ របៀបធ្វើអាជីវកម្មនៃការលក់ដេញថ្លៃផលិតផលផ្កាស្រស់របស់មជ្ឈមណ្ឌលនេះ បានក្លាយទៅជារបៀបសំខាន់មួយសម្រាប់ខេត្តយូណានដើរឆ្ពោះទៅកាន់ទូទាំងប្រទេសចិន ក៏ដូចជាទៅកាន់ពិភពលោកទាំងមូល ហើយក៏បានជំរុញដល់ការអភិវឌ្ឍន៍នៃមុខរបរផ្កាស្រស់ និងបានជួយបង្កើនប្រាក់ចំណូលរបស់ប្រជាកសិករនៅខេត្តយូណានផងដែរ ។

ផ្សារលក់ផ្កាតូវណានមានលក្ខណៈពិសេសមួយចំនួនដូចជាផ្កាមានគុណភាពខ្ពស់ ប្រភេទច្រើន ការផ្គត់ផ្គង់គ្រប់គ្រាន់ និងមានតម្លៃថោក ។ ដូច្នេះ វាអាចបំពេញតម្រូវការរបស់អតិថិជនគ្រប់ប្រភេទ ដូចជាពាណិជ្ជករតូចធំនិងភ្ញៀវគយគន់ផ្កាដែលមកពីតំបន់នានាជាដើម ។



ផ្សារលក់ផ្កា តូវណាន ក្រុងគុនមីង
昆明斗南花卉交易市场 cfp 图



ផែនទីបង្ហាញផ្លូវនៃ“បុរីផ្កាទ្វីបអាស៊ី”តូវណាន ក្រុងគុនមីង
昆明斗南“亚洲花都”发展蓝图 cfp 图

# មនោសញ្ចេតនាចំពោះស្វាយរបស់ប្រជាជនកម្ពុជា

## 柬埔寨人的芒果情怀

文、图/沈 燕

芒果富含糖、蛋白质、粗纤维、胡萝卜素等丰富的营养成分，是著名的热带水果之一。因其果肉细腻，口味独特，深受人们喜爱，素有“热带果王”的美誉。柬埔寨地处热带，属典型的热带气候，全年湿热多雨，为芒果提供了优越的生长环境。柬埔寨人善于种植芒果、懂得品尝芒果，因此对芒果也有着特别的情感。（SOPHAT 译）

ស្វាយមានជីវជាតិសម្បូរបែប ដូចជាជាតិស្ករ ជាតិប្រូតេអ៊ីន និងជាតិការ៉ុត គឺជាផ្លែឈើល្បីឈ្មោះមួយក្នុងចំណោមផ្លែឈើតំបន់ត្រូពិច ដោយសារសាច់របស់វាម៉ត់ល្អ មានរសជាតិប្លែកខុសពីគេ ទទួលបានការចូលចិត្តយ៉ាងខ្លាំង ហើយតាំងពីដើមមកក៏ត្រូវបានគេសន្មតជា“ស្តេចផ្លែឈើត្រូពិច”។ កម្ពុជាស្ថិតនៅក្នុងតំបន់ត្រូពិច គឺជាតំបន់ដែលមានអាកាសធាតុក្តៅ ជាលក្ខណៈពិសេស មានអាកាសធាតុក្តៅហើយសើមហើយមានភ្លៀងធ្លាក់ច្រើនពេញមួយឆ្នាំ មានអំណោយផលល្អប្រសើរដល់ការលូតលាស់របស់ដំណាំស្វាយ ។ ប្រជាជនកម្ពុជាមានជំនាញក្នុងការដាំដុះដំណាំស្វាយ ស្គាល់ពីរសជាតិស្វាយ ដូច្នេះ ពួកគេក៏មានមនោសញ្ចេតនាពិសេសចំពោះដំណាំស្វាយដែរ ។

នៅប្រទេសកម្ពុជា ស្ទើរតែគ្រប់ក្រុមគ្រួសារសុទ្ធតែមានដំណាំស្វាយឱ្យតែមានធ្លាតូចមួយ ទោះបីមានទំហំត្រឹមតែប៉ុន្មានម៉ែត្រការ៉េក្តី ក៏យើងអាចឃើញដើមស្វាយដ៏ខៀវស្រងាត់ដែរ នេះមិនអាចនិយាយថាជាទំនៀមទម្លាប់មួយនោះទេ គ្រាន់តែនៅក្នុងប្រទេសដ៏អាថ៌កំបាំងនិងរាក់ទាក់មួយនេះ មនុស្សគ្រប់រូបសុទ្ធតែចូលចិត្តម្លប់ដើមស្វាយនិងផ្លែស្វាយដ៏ផ្អែមឆ្ងាញ់ ។

ដំណាំស្វាយនៅកម្ពុជាមានច្រើនប្រភេទ រូបរាងខាងក្រៅក៏មានច្រើនបែបច្រើនយ៉ាងដែរ ។ ផ្លែដែលតូចជាងគេមានទំហំប្រហែលប៉ុនមេដៃប៉ុណ្ណោះ ផ្លែធំបំផុតអាចមានទម្ងន់រហូតដល់១ គីឡូ មានពណ៌បៃតង លឿង និងពណ៌ក្រហម ។ ស្វាយមានពេញមួយឆ្នាំនៅក្នុងទីផ្សារកម្ពុជា ជារៀងរាល់ខែគេអាចបរិភោគផ្លែស្វាយដែលមានរសជាតិប្លែកពីគ្នានិងឆ្លងកាត់ដំណាក់កាលលូតលាស់ខុសគ្នា ។ ជនជាតិចិនភាគច្រើនចូលចិត្តបរិភោគផ្លែស្វាយទុំ បរិភោគផ្ទាល់ឬកិនជាទឹកផ្លែស្វាយ ។ ស្វាយទុំទូទៅ មានសាច់ម៉ត់ និងមានរសជាតិផ្អែម ។ ចំណែកនៅប្រទេសកម្ពុជា របៀបបរិភោគផ្លែស្វាយមានច្រើនបែបច្រើនយ៉ាង អាចនិយាយបានថាមានការប្រែប្រួលច្រើន បើនិយាយចំពោះស្វាយទុំវិញ ប្រជាជនកម្ពុជាហាក់បីដូចជាចូលចិត្តបរិភោគស្វាយខ្ចីជាង ចិតសម្បកខៀវចោល ដោយប្រើកាំបិតចិតជាចំណិតៗនិងឆ្អឹះចេញមក ហើយយកដុំតូចៗរបស់អំពៅខ្ចាស់ចេញជារាងផ្កាឈូករួមជាមួយអំបិល ដែលធ្វើឡើងដោយខ្លួនឯងមួយកញ្ចប់តូចៗ សាច់ស្វាយស្រួយ ជូរផងហិរផង ក្រោយពេលបរិភោគមានរសជាតិផ្អែមជាប់មាត់ រសជាតិយ៉ាងចម្លែកពិសេស ។

ដោយឡែកប្រជាជនកម្ពុជាចូលចិត្តយកស្វាយចិតជាសរសៃតូចៗលាយជាមួយបន្លែឆៅ នេះគឺជាមុខម្ហូបពិសេសមួយទៀត ។ យកស្វាយខ្ចីស្លសម្ល ទឹកសម្លជូរហិរៗ មានខ្លះដាក់ជាមួយបន្លែ មានខ្លះដាក់ជាមួយគ្រឿងសមុទ្រ រួមនឹងប្រហុកដ៏ពិសេសរបស់កម្ពុជាមួយចានតូច រសជាតិឆ្ងាញ់បែបនេះប្រហែលមានតែប្រជាជនកម្ពុជាដែលឧស្សាហ៍និងសាមញ្ញទេចេះបរិភោគ ។ ស្វាយទុំជាទូទៅគឺបរិភោគដោយផ្ទាល់ ឬលាយជាមួយពងមាន់ឆៅនិងផ្លែឈើផ្សេងទៀត កិនទៅជាចំណីដ៏ពិសេសមួយទៀតគឺទឹកក្រឡុក បង្កើតបានជារសជាតិផ្អែមឆ្ងាញ់ខុសប្លែកពីគ្នា ឬក៏យកស្វាយទុំចិតជាចំណិតៗ ហាលឱ្យស្ងួតធ្វើជាតំណាប់ស្វាយ ។ រសជាតិឆ្ងាញ់របស់ផ្លែស្វាយទាំងនេះធ្វើឱ្យប្រជាជនកម្ពុជាមានមនោសញ្ចេតនាយ៉ាងជ្រាលជ្រៅចំពោះដំណាំស្វាយ ក៏ដូចជាចំពោះទឹកដីខ្មែរដែលសម្បូរទៅដោយដំណាំស្វាយនេះ ។



# ក្រុមហ៊ុន សីហនុវីល ស្ពេសល អ៊ីខននើមី ហ្សូន

西 哈 努 克 港 经 济 特 区 有 限 公 司

Sihanoukville Special Economy Zone Co.,Ltd.



តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម ដែលរួមគ្នាអភិវឌ្ឍន៍ដោយក្រុមហ៊ុនហុងដូ គ្រុប និងក្រុមហ៊ុនវិនិយោគទុនអន្តរជាតិគ្រុប កម្ពុជា គឺជាតំបន់សហប្រតិបត្តិការខាងសេដ្ឋកិច្ចនិងពាណិជ្ជកម្មមួយ ក្នុងចំណោមតំបន់សហប្រតិបត្តិការខាងសេដ្ឋកិច្ចនិងពាណិជ្ជកម្មក្រៅប្រទេសជើងទីមួយរបស់ប្រទេសចិន ដែលត្រូវបានអនុម័តនិងទទួលស្គាល់ដោយក្រសួងពាណិជ្ជកម្ម និងក្រសួងហិរញ្ញវត្ថុប្រទេសចិន ហើយក៏ជាតំបន់សេដ្ឋកិច្ចពិសេសធំជាងគេបំផុតក្នុងព្រះរាជាណាចក្រកម្ពុជាផងដែរ ។ តំបន់សេដ្ឋកិច្ចពិសេសនេះមានផ្ទៃក្រឡាតាមការគូរប្លង់សរុប ១១,១៣ គីឡូម៉ែត្រក្រឡា និងចាត់ទុកឧស្សាហកម្មអំពីវាយនភណ្ឌ គ្រឿងបន្លាស់និងគ្រឿងចក្រ គ្រឿងអគ្គិសនីផុនស្រាដែលប្រើប្រាស់នៅក្នុងផ្ទះជាគោលណែនាំ ។ សព្វថ្ងៃ សហគ្រាសដែលចូលដំណើរការក្នុងតំបន់សេដ្ឋកិច្ចពិសេសនេះមានចំនួនរាប់សិបសហគ្រាសហើយ ។

គម្រោងតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោមបានទទួលនូវការយកចិត្តទុកដាក់កម្រិតខ្ពស់ពីអ្នកដឹកនាំនិងស្ថាប័នរដ្ឋ គ្រប់ជាន់ថ្នាក់នៃប្រទេសទាំងពីរចិន-កម្ពុជា ។ កាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០១០ ប្រទេសចិននិងកម្ពុជាបានចុះហត្ថលេខាជាផ្លូវការនូវ "កិច្ចព្រមព្រៀងស្ដីពីតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោមរវាងសាធារណរដ្ឋប្រជាមានិតចិននិងព្រះរាជាណាចក្រកម្ពុជា" ។ កិច្ចព្រមព្រៀងនេះ បានកំណត់ច្បាស់នូវតួនាទីខាងច្បាប់នៃតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោមនិងបានកំណត់ឱ្យច្បាស់ថា ភាគីទាំងពីរដែលបានចុះហត្ថលេខារួមគ្នា ផ្ដល់ការគាំទ្រនិងការសម្រួលដល់ការស្ថាបនា គ្រប់គ្រងនិងដំណើរការនៃតំបន់សេដ្ឋកិច្ចនេះ ហើយក៏បានកំណត់ច្បាស់នូវការបង្កើតគណៈកម្មការសម្របសម្រួល ថ្នាក់ក្រសួងទ្វេភាគីនៃតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម នៅក្រោមក្របខ័ណ្ឌកិច្ចព្រមព្រៀង ដើម្បីសិក្សាស្រាវជ្រាវអំពីបញ្ហាសំខាន់ៗដែលជួបប្រទះក្នុងការស្ថាបនា និងដំណើរការជាដើមនៃតំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម ។ កិច្ចព្រមព្រៀងទ្វេភាគីនេះបានបើកទំព័រថ្មីសម្រាប់តំបន់សេដ្ឋកិច្ចពិសេសកំពង់ផែកំពង់សោម !

សូមស្វាគមន៍ដោយក្ដីស្មោះសរចំពោះបណ្ដាអ្នកវិនិយោគទាំងអស់អញ្ជើញមកធ្វើការវិនិយោគ !

ទន្ទឹងរង់ចាំការចូលរួមពីសំណាក់លោកអ្នក !






1、坐拥优越的地理位置，交通便利

2、享受优惠的税收政策，低价运营

3、提供优质的配套服务，贴心周到

**期待您的加盟！**



**招商热线：** 00855-88-5678892、00855-16-391335

**地址：** 西哈努克市波雷诺区毕德朗分区布腾村和云壤分区斯马奇登村 **网址：** www.ssez.com

图/cfp



ទេសភាពជ្រលងភ្នំហុងនីនៃភ្នំថៃហាង

太行山虹霓大峡谷风光

# ភ្នំថៃហាង

## 太行山

太行山又名五行山、王母山、女娲山，是中国东部地区的重要山脉和地理分界线。耸于北京、河北、山西、河南四省、市间。北起北京西山，南达豫北黄河北崖，西接山西高原，东临华北平原，绵延400余公里，是山西东部、东南部与河北、河南两省的天然界山，是中国地形第二阶梯的东缘，也是黄土高原的东部界线。（SOPHAT 译）

ភ្នំថៃហាង ក៏ត្រូវបានគេហៅថាភ្នំអ៊ូស៊ីង ឬភ្នំវ៉ាំងមូ ឬភ្នំនីវ៉ា ដែលជាជងភ្នំសំខាន់នៅភូមិភាគខាងកើត និងជាបន្ទាត់បែងចែកព្រំដែនភូមិសាស្ត្រនៃប្រទេសចិន ។ វាស្ថិតនៅក្នុងបួនខេត្តក្រុង រួមមានក្រុងប៉េកាំង ខេត្តហឺប៉ី សានស៊ី និងហឺណាន ។ ខាងជើងផ្តើមពីភ្នំខាងលិចក្រុងប៉េកាំង ខាងត្បូង លាតសន្ធឹងដល់ត្រើយខាងជើងនៃទន្លេលឿងនៅភាគខាងជើងខេត្តហឺណាន ខាងលិចជាប់នឹងខ្ពង់រាបសានស៊ី ខាងកើតជាប់នឹងវាលទំនាបហួប៉ី លាតសន្ធឹងចម្ងាយជាង ៤០០ គីឡូម៉ែត្រ គឺជាភ្នំព្រំដែនរវាងភូមិភាគខាងកើត និងភូមិភាគអាគ្នេយ៍នៃខេត្តសានស៊ីជាមួយនឹងខេត្តហឺប៉ីនិងខេត្តហឺណាន ។ ភ្នំនេះគឺជាបន្ទាត់ព្រំដែន ផ្នែកខាងកើតនៃខ្ពង់រាបដីលឿង ។

ផ្នែកខាងលិចនៃជងភ្នំថៃហាងជាប់ជាមួយខ្ពង់រាបសានស៊ី ផ្នែកខាងកើតលាតសន្ធឹងដល់វាលទំនាបដោយមានភ្នំតូចធំនៅកណ្តាល ។ ទន្លេខ្ពង់រាបសានស៊ីហូរកាត់ភ្នំថៃហាងចូលទៅក្នុងវាលទំនាបហួប៉ី ទឹកហូរខ្វាត់ខ្វែងជ្រៅ ហើយថ្លាមានជ្រលងភ្នំជាប់គ្នាជាបន្តបន្ទាប់ ហើយមានទឹកជ្រោះដែលមានសន្ទុះយ៉ាងខ្លាំងជាច្រើន ។ នៅស្រុកចាន់ហួងខេត្តហឺប៉ីក្នុងតំបន់ភ្នំជ្រៅនៃភ្នំថៃហាងនេះ មានជញ្ជាំងខ្មរសំឡេងធម្មជាតិធំបំផុតលើពិភពលោក ។

លើភ្នំវ៉ាងអ៊ូដែលស្ថិតនៅប៉ែកខាងត្បូងនៃភ្នំថៃហាង មានព្រៃឈើដែលត្រូវបានថែរក្សាយ៉ាងល្អប្រសើរ នៅតំបន់ភ្នំផ្នែកកណ្តាលនៅមានព្រៃឈើពីដើមមួយចំនួន ធនធានសត្វព្រៃក្នុងតំបន់ភ្នំនេះសម្បូរបែប ។ ភ្នំវ៉ាងអ៊ូខ្ពស់ទាបមិនស្មើគ្នាទេ មានដើមឈើស្អេកស្កះ ភ្នំមានរាងដូចដាវបញ្ឈរ ទឹកមានរាងដូចដំណើរសត្វនាគ ចាប់តាំងពីសម័យថាងមក ទីនេះក៏ជាមជ្ឈមណ្ឌលនៃសកម្មភាពសាសនាតាវដ៏ល្បីឈ្មោះនៅភូមិភាគកណ្តាលប្រទេសចិន ។ មានមនុស្សជាច្រើនមកពីគ្រប់ទិសទីបានជួបជុំនៅទីនេះដើម្បីសុំសីលនិងហាត់រៀន អ្នកសិក្សាក៏មកទស្សនានិងស្រាវជ្រាវនៅទីនេះដែរ ហើយបាននិពន្ធកំណាព្យយ៉ាងច្រើនដើម្បីកោតសរសើរនូវទេសភាពស្អាតត្រកាលនៅទីនេះ ។

នៅក្នុងតំបន់រមណីយដ្ឋានទេសភាពធម្មជាតិនៃជ្រលងភ្នំធំនៃភ្នំថៃហាង មានភ្នំរាប់ពាន់ឈរបង្អួតសម្រស់គ្នាដែលមានសណ្ឋានដីល្អឯក ព្រមនិងធនធានព្រៃប្រឹក្សានិងបក្សាបក្សីដែលបានធ្វើឱ្យជ្រលងភ្នំធំនៃភ្នំថៃហាងក្លាយជាទិដ្ឋភាពធម្មជាតិដ៏ល្អឯកមិនអាចប្រៀបផ្ទឹមបាន ។ ស្ថានភាពភ្នំនៅជ្រលងភ្នំធំនៃភ្នំថៃហាងមានលក្ខណៈធំរឹងមាំអស្ចារ្យ ខ្ពស់សន្ធឹម សណ្ឋានដីដែលរដិបរដុបធ្វើឱ្យខាងមុខភ្នំថៃហាងមានលក្ខណៈដាច់ៗ បង្កើតបានជាភ្នំថៃហាង និងជ្រលងភ្នំមានលក្ខណៈបែងចែកយ៉ាងស្មុគស្មាញ ។ ជ្រលងភ្នំធំគឺជាសមុទ្រនៃភ្នំ ជាប្រទេសនៃថ្ម ជាពិភពនៃរូង ជាភូមិទិព្វនៃទឹក ជាឧទ្យានសម្រាប់រុក្ខជាតិលូតលាស់ ជាឋានសួគ៌សម្រាប់សត្វរស់នៅ ។ ទេសភាពក្នុងតំបន់រមណីយដ្ឋានស្រស់ត្រកាល មានលក្ខណៈប្លែក បានប្រមូលផ្តុំនូវទិដ្ឋភាពថៃហាងនៅ ក្នុងជងភ្នំដែលមានរូបរាងចម្លែកៗទាំងនេះ មានព្រៃឈើទូលំទូលាយ ថ្មភ្នំប្លែកៗ ទឹកជ្រោះថ្លាឆ្វង់ រូងភ្នំដ៏អាថ៌កំបាំង ព្រះវិហារស្អាតអស្ចារ្យ និងរឿងនិទានដ៏មានកម្លាំងទាក់ទាញ មានពិតមានមិនពិត មានភ្លឺមានងងឹត មានពន្លឺមានពណ៌ មានប្លែកមានគ្រោះថ្នាក់ ក្បួនក្បាច់រចនាពិតជាអស្ចារ្យ ។ ជ្រលងភ្នំធំនៃភ្នំថៃហាងមិនត្រឹមតែមានទេសភាពធម្មជាតិគួរឱ្យជក់ចិត្តនោះទេ ចំណែកឯទស្សនីយភាពមនុស្សសាស្ត្រ និងវប្បធម៌ក៏ធ្វើឱ្យអ្នកទស្សនាចាប់ចិត្តផងដែរ ។ ខ្លឹមសារនៃវប្បធម៌នៅទីនេះជ្រាលជ្រៅណាស់

រឿងនិទានខុងជឺ និងរឿងគ្រូសាសនាតាវពីររូបមានប្រវត្តិជាយូរលង់ណាស់មកហើយ ជាពិសេសគឺព្រះវិហារជិនជឺ ដែលជាកន្លែងការពារវត្ថុបុរាណថ្នាក់ខេត្តដែលស្ថិតនៅប៉ែកនិរតីនៃភ្នំជីធន់ និងជាសំណង់សាសនាតាវដែលត្រូវបានរក្សាយ៉ាងល្អប្រសើរ ចាប់ផ្តើមសាងសង់ក្នុងសម័យថាង លើផ្ទៃដី ៦៩០០ ម៉ែត្រការ៉េ មានក្លោងទ្វារ ប៉មស្គរ វិមានគយគន់ទេសភាព ទន្លេនិងសំណង់ជាច្រើនទៀត ដែលមានរចនាសម្ព័ន្ធសព្វគ្រប់ រៀបចំបានមានរបៀបរៀបរយ រចនាបានស្អាត និងមានរូបគំនូរតាមជញ្ជាំង ចំណែកអត្ថន័យគំនូរមានភាពជាក់ស្តែង ឬមានលក្ខណៈជារឿងនិទាន ម្យ៉ាងទៀតចម្លាក់និងគំនូរទាំងនោះមានលក្ខណៈល្អប្រណីត ហើយក៏មានតម្លៃគយគន់ផ្នែកប្រវត្តិសាស្ត្រនិងសិល្បៈដ៏មានតម្លៃផងដែរ ។



ផ្លូវលើចង្កេះភ្នំនៃភ្នំថៃហាងដ៏ខ្ពស់ត្រដែត

太行山百丈峭壁上的“挂壁路”



ទេសភាពជ្រលងភ្នំថៃហាង

太行山大峡谷风光

# វិហារវិញ្ញូកខុងជឺនៅក្រុងអានស៊ុន ខេត្តគុយចូវ



cnsphoto 图

## 贵州安顺文庙

安顺文庙位于贵州省安顺市东北之黉学坝。始建于明代洪武初年，现存建筑22处，占地约8000平方米，是一座规模宏大、布局严谨、庄严典雅的古建筑群。1982年，贵州省人民政府将其核定公布为省级文物保护单位，是现今中国保存下来的建筑最完整、艺术性最高的文庙之一。（SOPHAT 译）

វិហារវិញ្ញូកខុងជឺ អានស៊ុន ស្ថិតនៅផ្លូវហុងស៊ាប៉ាដែលមានទីតាំងឋិតនៅទិសឦសានក្រុងអានស៊ុននៃខេត្តគុយចូវ ។ វិហារនេះចាប់ផ្តើមសាងសង់នៅដើមឆ្នាំសម័យហុងអ៊្វូរជ្ជកាលម៉េង មកដល់ពេលនេះមានសំណង់ចំនួន ២២ នៅលើផ្ទៃដីចំនួន ៨០០០ ម៉ែត្រការ៉េ មានសណ្ឋានពីទាបទៅខ្ពស់តាមលំដាប់លំដោយត្រឹមត្រូវ គឺជាអគារបុរាណដែលមានទ្រង់ទ្រាយធំញឹកជាប់គ្នា និងមានសភាពស្ងប់ស្ងាត់ ។ នាឆ្នាំ ១៩៨២ សាលាខេត្តគុយចូវសម្រេចប្រកាសចាត់ទុកវិហារនេះជាតំបន់អភិរក្សវប្បធម៌ថ្នាក់ខេត្ត វាគឺជាវិហារវិញ្ញូកខុងជឺមួយក្នុងចំណោមវិហារដែលនៅមានលក្ខណៈពេញលេញ និងពោរពេញទៅដោយរចនាបថសិល្បៈខ្ពស់បំផុតដែលប្រទេសចិនបានថែរក្សារហូតមកដល់បច្ចុប្បន្ន ។


cfp 图

វិហារវិញ្ញូកខុងជឺ ដើមឡើយគឺជាកន្លែងដ៏ឧត្តមក្នុងការអប់រំក្នុងក្រុងអានស៊ុន ។ សំណង់ទាំងមូលគឺជាវិហារ និងជាអគារបុរាណដែលសាងសង់ឡើងដោយយកក្បាច់រចនាចម្លាក់ថ្មជាគោល និងរំលេចនូវភាពគួរឱ្យគោរពនៃវិហារខុងជឺ ។ វត្ថុដែលមានឈ្មោះល្បីនោះគឺសសរនាគទាំងពីរដើមដែលស្ថិតនៅខាងមុខដំណាក់ លក្ខណៈពិសេស និងខុសប្លែកពីគេរបស់វាគឺធ្វើឡើងដោយឆ្លាក់ថ្មទាំងមូលតែម្តង ក្បាច់ចម្លាក់ថ្មជាច្រើនដូចជារាងផុសជ្រៅនិងរាក់ ចម្លាក់រាងមូលជាដើម អាចនិយាយបានថា លើលោកគ្មានពីរហើយមានតម្លៃក្នុងការទស្សនា ។

វិហារវិញ្ញូកខុងជឺនៅក្រុងអានស៊ុនសរុបមាន ៤ ផ្នែក ។ ខ្ទងទី ១ ចែកជាដំណាក់ខាងមុខនិងដំណាក់ខាងក្រោយ ។ ក្រៅពីផ្នែកទី ៤ ដែលបាត់បង់សភាពដើមនោះ ផ្នែកទាំងបីជាទូទៅនៅល្អទាំងអស់ ។ ដោយសារសាងសង់ទៅតាមទីទួលផ្នែកទាំង ៤ នោះក៏មានរាងឡើងខ្ពស់ទៅតាមនោះដែរ ។ ចូលតាមក្លោងទ្វារធំនៃវិហារវិញ្ញូកខុងជឺ ដល់ដំណាក់ទី ១ ទីនោះ មានអាងទឹកដែលមានរាងព្រះចន្ទពាក់កណ្តាល ហៅថាអាងទឹកមុខដំណាក់សិក្សា ។ នៅលើអាងទឹកនេះមានកូនស្ពានប្រហោងបីចំនួនមួយ លើប្រហោងមានរូបក្បាលនាគ ឬក្បាលគោថ្មមួយ ហាក់បីដូចជាកំពុងឱនមើលទៅទឹកទាំងអស់ ។

នៅភាគខាងកើតនិងខាងលិចនៃផ្នែកទី ២ បានសាងសង់ពន្លាលើភ្នំដែលមានបន្ទប់តែមួយដូចគ្នា ដែលដាក់ឈ្មោះថា“ពន្លាគុយស៊ាង”និង“ពន្លាជុនជឹង” ។ ពន្លាទាំងពីរនោះគឺជាទីកន្លែងរាយនាមមន្ត្រីដែលសែនវិញ្ញូកដល់ខុងជឺ ។ ពន្លាគុយស៊ាងនៅបន្សល់ទុករហូតដល់បច្ចុប្បន្ននេះ ។ ដើរតាមជណ្តើរថ្ម ៩ ថ្នាក់ មានសំណង់លើភ្នំមួយដែលមានមាត់ច្រកធំ និងមាន ៥ បន្ទប់ ឈ្មោះថា“ក្លោងទ្វារតាឈឹង”ឬ“ក្លោងទ្វារជី” ។

ផ្នែកទី ៣ គឺជាដំណាក់រួមមុខ ៤ ដែលបង្កើតឡើងដោយដំណាក់ធំ(ដំណាក់តាឈឹង) រានដើរ ២ និងក្លោងទ្វារតាឈឹង ។ ដំណាក់តាឈឹងមានប្រវែង ២០ ម៉ែត្រ ជាដំណាក់ដែលមានរចនាសម្ព័ន្ធពីឈើសាងសង់លើភ្នំ ដោយសង់នៅពីលើគ្រឹះថ្មដែលមានកម្ពស់ ២ ម៉ែត្រ ។ រានដើរខាងមុខនៃដំណាក់តាឈឹងមានទ្វារបង្អួចដែលមានចម្លាក់ស្រស់ស្អាតនិងអស្ចារ្យ ។ នៅពីមុខដំណាក់មានសសរពីរ គឺជាសសរនាគធំដែលឆ្លាក់ពីថ្មពីរដុំធំៗ ឯនៅផ្នែកខាងក្រោមលើសសរនៅមានចម្លាក់គោថ្ម ។ សសរមានកម្ពស់ជិត ៥ ម៉ែត្រ ផ្ចិតប្រមាណ ៨០ សង្ទីម៉ែត្រ ហើយមានក្បាច់រចនាល្អឯក ។ ចម្លាក់គោថ្មនៅលើសសរគឺជាគោញីនិងគោឈ្មោល គោឈ្មោលប្រលែងលេងជាមួយបាល់ ឯគោញីបំបៅកូនគោក្នុងមាត់មានពាំកណ្តឹង ។ សសរទាំងពីរនេះ រួមនឹងសសរនាគទាំងពីរ ហើយមានកណ្តឹងស្ពាន់មួយក្នុងមាត់របស់វា ។ គោថ្មទាំងពីរនិងសសរនាគនៅខាងក្រៅក្លោងទ្វារតាឈឹងត្រូវបានគេដាក់រហស្សនាមថា“វត្ថុទិព្វចម្លាក់ថ្មទាំងបួននៃវិហារវិញ្ញូកខុងជឺ” ។


រូបចម្លាក់លើសសរទ្វារ
门柱上的石雕 cfp 图

នៅខែមិថុនា ឆ្នាំ ២០០១ វិហារវិញ្ញូកខុងជឺ អានស៊ុនដែលជាសំណង់បុរាណសម័យម៉េង ត្រូវបានក្រុមប្រឹក្សាភិបាលកិច្ចការរដ្ឋចិនអនុញ្ញាតដាក់ញ្ចូលក្នុងបញ្ជីតំបន់អភិរក្សវប្បធម៌សំខាន់ទូទាំងប្រទេសជើងទី ៥ ។

# ពិធីបុណ្យចម្រៀងរបស់ជនជាតិប៉ៃនៅភ្នំសឺប៉ាវ




## 白族石宝山歌会

文/李秋菊　图/蔡 梦

大理剑川白族石宝山歌会是一个以对歌赛歌为特色的民族传统节会,于每年农历七月二十七日至八月初一在大理剑川县沙溪镇石宝山举行。被誉为“白族歌城”的石宝山万人对歌会，是白族风情的集中展现。

（KONG CHANTARA 译）

ពិធីបុណ្យចម្រៀងជនជាតិប៉ៃភ្នំសឺប៉ាវនៅស្រុកជានឈួន ក្រុងតាលី គឺជាកម្មវិធីប្រពៃណីច្រៀងឆ្លងឆ្លើយគ្នាដែលមានលក្ខណៈពិសេសតាមតំបន់ ។ ជារៀងរាល់ឆ្នាំ ថ្ងៃទី ២៧ នៃខែ ៧ ដល់ថ្ងៃទី ១ ខែ ៨ តាមចន្ទគតិចិន គេប្រារព្ធពិធីនេះនៅតំបន់ភ្នំសឺប៉ាវឯស្រុកជានឈួនក្រុងតាលីខេត្តយូណាន ភ្នំសឺប៉ាវដែលត្រូវគេប្រសិទ្ធនាមថា“ក្រុងប្រជុំចម្រៀងជនជាតិប៉ៃ”នោះ គឺជាកន្លែងសំខាន់មួយសម្រាប់ប្រមូលផ្តុំ និងបង្ហាញពីវប្បធម៌របស់ជនជាតិប៉ៃ ។

ទាក់ទងនឹងប្រវត្តិពិធីបុណ្យចម្រៀងបានបន្សល់ទុកនូវរឿងព្រេងដ៏អស្ចារ្យជាច្រើន ដូចជាលើភ្នំសឺប៉ាវមានថ្មធំមួយដុំដែលមានរាងដូចផ្លូង ពីដើមគឺជាផ្លូងមាសមួយ ។ រាល់ពេលដែលផ្លូងមាសបន្លឺឡើង ទីវាលលើខ្ពង់រាបសាស៊ីនៅក្រោមភ្នំមានខ្យល់មានភ្លៀងដែលអំណោយផលដល់កសិកម្ម ។ ក្រោយមកមាននាគក្បាល ៩ មួយក្បាលបានព្រួសអណ្តាតភ្លើង ធ្វើឱ្យផ្លូងមាសក្លាយជាផ្លូងថ្ម ថែមទាំងដាក់បណ្តាសាបិសាច ធ្វើឱ្យទីវាលលើខ្ពង់រាបនោះតែងតែជួបនឹងគ្រោះមហន្តរាយជាប់មិនដាច់ ។ ទីវាលលើខ្ពង់រាបសាស៊ីមានគូស្នេហ៍មួយគូឈ្មោះអាសឺប៉ និងអាគួយនាវ បានទទួលមហិទ្ធិឫទ្ធិពីទេវតា អាចយកសំនៀងមកបំបែកមន្តអាគមរបស់នាគ ថែមទាំងអញ្ជើញបងប្អូនស្រី ២០ នាក់ទៅច្រៀងឆ្លងឆ្លើយលើភ្នំជារៀងរាល់ថ្ងៃ លុះទីបំផុតក៏យកឈ្នះលើនាគបិសាចនោះតែម្តង ។ តែអាសឺប៉និងអាគួយនាវក៏បានស្លាប់នៅពេលប្រយុទ្ធជាមួយនាគនោះ ដូច្នេះដើម្បីរំលឹកគុណដល់គូស្នេហ៍មួយគូនេះ អ្នកភូមិនាំគ្នាទៅច្រៀងឆ្លើយឆ្លងលើភ្នំជារៀងរាល់ឆ្នាំ ហើយក្រោយមកក៏បានក្លាយជាពិធីបុណ្យចម្រៀងបន្តពីជំនាន់មួយទៅជំនាន់មួយរហូតដល់សព្វថ្ងៃ ។

ពិធីបុណ្យចម្រៀងភ្នំសឺប៉ាវត្រូវបានរៀបចំនៅវិហារប៉ាវសៀងដែលត្រូវបានគេហៅថា “វិហារសៀនខូងនៅខេត្តយូណាន” ក្នុងវិហារដ៏សំខាន់នេះមានទីធ្លានិងវេទិកាច្រៀងចម្រៀង ។ ក្នុងអំឡុងពេលអបអរបុណ្យចម្រៀង វិហារប៉ាវសៀងក៏បានក្លាយជាទីប្រជុំសេវាចម្រៀង អីវ៉ាន់ដាក់លក់ពាសពេញ ជាពិសេសមានអ្នកលក់នំចំណីនិងអាហារពិសេសតាមតំបន់ជាច្រើន ដែលបានផ្តល់ភាពងាយស្រួលដល់អ្នកទៅទស្សនាកម្សាន្ត និងជំរុញឱ្យបរិយាកាសកាន់តែអ៊ូរអរថែមទៀត ។

ក្នុងអំឡុងពេលកម្មវិធី បងប្អូនជនជាតិប៉ៃមកពីតំបន់ជានឈួន អឺយាន តាលី លីជាំង ឡានភីង និងស្រុកឬក្រុងមួយចំនួនទៀត បានជួបជុំគ្នានៅទីនេះ ច្រៀងបណ្តើរ ទស្សនាព្រៃភ្នំនិងវត្តបុរាណបណ្តើរ ។ នៅតាមដងផ្លូវលើភ្នំ មានអ្នកទេសចរណ៍ច្រើនកុះករនិងសំឡេងចម្រៀងដ៏ពីរោះរណ្តំ ។ មិនតែប៉ុណ្ណោះទេ ការដេញពិណនិងច្រៀងចម្រៀងក៏ជាវិធីមួយសម្រាប់ស្វែងរកគូស្រកររបស់យុវវ័យជនជាតិប៉ៃដែរ ។ បទចម្រៀងបានក្លាយជាទំនាក់ទំនងរបស់យុវវ័យយ៉ាងទូលំទូលាយ ហើយឆ្លងកាត់ការច្រៀងចម្រៀងឆ្លងឆ្លើយធ្វើឱ្យពួកគេយល់ចិត្តគ្នា ប្រកួតចំណេះដឹងគ្នា ដូច្នេះអត្ថន័យចម្រៀងមួយឃ្លាៗសុទ្ធតែប្រកបដោយភាពស្មោះសក្រៃលែង ។ រាល់ពេលដែលមានដៃគូណាច្រៀងឆ្លើយឆ្លងម្តងៗ អ្នកទស្សនាទាំងអស់តែងតែចោមរោមជិតភ្លាម មនុស្សម្នាទទួលបានការសោយសុខពីសិល្បៈដ៏អស្ចារ្យ ហើយតាមរយៈការច្រៀងឆ្លើយឆ្លងគ្នានេះ ក៏មានយុវជនយុវនារីខ្លះបង្កើតបានជាសេចក្តីស្នេហា និងក្លាយជាប្តីប្រពន្ធរួមរស់នៅជាមួយគ្នារហូតដល់ចាស់សក់ស្កូវផងដែរ ។



文/杨晓梅　蓝 天

# ចំណេះដឹងមូលដ្ឋាន(៣៥)　基础知识（35）

## 一、日常用语

### ១-ពាក្យប្រើប្រាស់ប្រចាំថ្ងៃ

情景会话：聊聊《红楼梦》的作者曹雪芹

ការសន្ទនា : និយាយអំពីលោកឆាវ ស៊ាឈីនអ្នកនិពន្ធប្រលោមលោក “សុបិនវិមានក្រហម”

shuō dào zhōng guó de xiǎo shuō wén xué　wǒ jué dé　hóng lóu mèng
A. 说 到 中 国的小 说 文 学，我觉得《红 楼 梦》
shì yí gè dǐng fēng　méi yǒu nǎ bù xiǎo shuō néng dá dào tā de yì shù gāo dù
是一个顶 峰，没 有哪部小 说 能 达到它的艺术 高度。

ក-និយាយដល់អក្សរសាស្ត្រប្រលោមលោករបស់ប្រទេសចិន ខ្ញុំយល់ថា រឿង“សុបិនវិមានក្រហម”គឺជារឿងមានលំដាប់កំពូល ហើយគ្មានរឿងណាអាចមានកម្រិតសិល្បៈដល់រឿងនេះទេ ។

wǒ tóng yì　hóng lóu mèng　rén wù shēng dòng　yǔ yán yōu měi　chú
B. 我同意。《红 楼 梦》人物生 动，语言优美。除
le tā fēi fán de yì shù chéng jiù　gèng zhòng yào de shì tā de sī xiǎng jià zhí
了它非凡的艺术 成 就，更 重 要的是它的思想 价值。

ខ-ខ្ញុំយល់ស្រប តួអង្គក្នុងរឿងសុបិនវិមានក្រហមមានភាពរស់រវើកនិងមានពាក្យពេចន៍ល្អឥតខ្ចោះ ។ ក្រៅពីសមិទ្ធផលសិល្បៈដ៏ពិសេសរបស់វា ជាងនេះទៅទៀតគឺតម្លៃនៃផ្នត់គំនិតរបស់វាផងដែរ ។

shì de　hóng lóu mèng　shì zuò zhě cáo xuě qín zhēn shí shēng huó de
A. 是的。《红 楼 梦》是 作者曹雪芹真 实 生 活的
xiě zhào　tā pī lù le zhōng guó fēng jiàn mò shì de nèi mù　shì yí bù
写 照，它披露了中 国封 建末世的内幕，是一部
zhōng guó fēng jiàn shè huì mò qī de bǎi kē quán shū
中 国封 建 社会末期的百科 全 书。

ក-ពិតណាស់“រឿងសុបិនវិមានក្រហម” គឺជាស្នាដៃរបស់អ្នកនិពន្ធឆាវ ស៊ាឈីន ដែលរៀបរាប់ពីជីវភាពជីវិតពិតៗនិងឆ្លុះបង្ហាញពីស្ថានភាពជាក់ស្តែងនៃចុងសម័យសក្តិភូមិរបស់ប្រទេសចិន ហើយវាក៏ជាវចនានុក្រមធំមួយក្បាលដែលសរសេរអំពីចុងសម័យសង្គមសក្តិភូមិរបស់ចិនទៀតផង ។

rú guǒ shuō hǎo de zuò pǐn yuán yú shēng huó　hóng lóu mèng　jiù shì
B. 如果 说 好的作品 源 于 生 活，《红 楼 梦》就是
diǎn fàn　cáo xuě qín shēng huó zài yí gè　bǎi nián wàng zú　de dà guān liáo
典 范。曹雪芹 生 活在一个“百 年 望 族”的大官 僚
dì zhǔ jiā tíng　shào nián shí dài shì háo mén gōng zi　jǐn yī wán kù　de
地主家庭，少 年时代是豪门公子“锦衣纨绔”的
shē chǐ shēng huó
奢侈 生 活。

ខ-បើថាស្នាដៃល្អមានប្រភពពីជីវិតពិតៗ រឿងសុបិនវិមានក្រហមគឺជារឿងគំរូ ។ លោកឆាវ ស៊ាឈីន រស់នៅក្នុងត្រកូលមន្ត្រីជាន់ខ្ពស់និងជាកូនប្រុសអ្នកមានដែលស្លៀកសម្លៀកបំពាក់ប្រណីតៗ និងមានជីវភាពរស់នៅថ្លូរថារ ។

kě xī hǎo jǐng bù cháng　dào tā zhè yí dài kāi shǐ mò luò　zài yōng zhèng
A. 可惜好 景 不 长，到他这一代开 始没落。在 雍 正
wǔ nián　tā fù qīn yīn shì shòu dào zhū lián　bèi gé zhí chāo jiā
五 年（1727），他父亲因事 受 到 株 连，被革职 抄 家。
cóng cǐ　jiā zú de quán shì hé cái chǎn dōu sàng shī dài jìn　tā bù dé bù
从 此，家族的权 势和财 产 都 丧 失殆 尽，他不得不
tóu qīn kào yǒu　yǐ wéi chí shēng huó　hái cháng chang shòu dào qí shì hé líng rǔ
投亲靠友，以维持 生 活，还 常 常 受到歧视和凌辱。
jīng lì le yóu jǐn yī yù shí de guì zú dào　jǔ jiā shí zhōu　de pín mín
经 历了由锦衣玉食的贵族到“举家食 粥”的贫 民
bǎi xìng de cāng sāng zhī biàn　shǐ tā duì fēng jiàn tǒng zhì jiē jí de mò luò
百姓的沧 桑 之 变，使他对封 建 统 治 阶级的没落
mìng yùn yǒu le qiè shēn gǎn shòu　duì shè huì shàng de hēi àn hé zuì è
命 运有了切 身 感 受，对社会 上 的黑暗和罪恶
yǒu le quán miàn ér shēn kè de rèn shí
有了全 面 而 深 刻的认识。

ក-គួរឱ្យស្តាយថា ដល់ជំនាន់គាត់ក៏ចាប់ផ្តើមដុនដាបតែម្តង ។ នៅសម័យស្តេចយ៉ុងចឹងឆ្នាំ ១៧២៧ ដោយសារឪពុករបស់គាត់ជាប់ទាក់ទងរឿងខ្លះ ក៏ត្រូវបានដកហូតតំណែងនិងត្រូវបានបណ្តេញចេញពីផ្ទះរបស់ខ្លួន ។ ចាប់តាំងពីពេលនោះមក សិទ្ធិអំណាចនិងទ្រព្យសម្បត្តិគ្រួសារត្រូវបានបាត់បង់អស់រលីង ដូច្នេះគាត់គ្មានជម្រើសក្រៅពីពឹងពាក់សាច់ញាតិនិងមិត្តភក្តិដើម្បីទ្រទ្រង់ជីវភាពរស់នៅ ហើយទទួលរងការមើលងាយរើសអើងនិងត្រូវគេធ្វើបាបជារើយៗនោះឡើយ ។ ដោយសារធ្លាប់តែរស់នៅស្រណុកមានសម្លៀកបំពាក់ស្អាតនិងមានអាហារញុំាស្រាប់ៗ រហូតធ្លាក់ខ្លួនមានជីវភាពក្រីក្រញុំាតែបបរទាំងគ្រួសារបែបនេះ ក៏ធ្វើឱ្យគាត់មានអារម្មណ៍បាក់ទឹកចិត្ត ចំពោះរបបសក្តិភូមិនិយមដែលសម្រេចជោគវាសនាគាត់ដ៏មានភាពដុនដាបខ្វះមុខខ្វះក្រោយ ក៏កាន់តែធ្វើឱ្យគាត់យល់ច្បាស់ពីភាពខ្មៅងងឹតនិងអំពើបាបនៅក្នុងសង្គមទាំងមូល ។

cáo xuě qín zài　hóng lóu mèng　de dì yī huí yǒu jǐ jù zì wǒ píng
B. 曹雪芹在《红 楼 梦》的第一回有几句自我评
jià　mǎn zhǐ huāng táng yán　yì bǎ xīn suān lèi　dōu yún zuò zhě chī
价：“满纸 荒 唐 言，一把辛 酸 泪。都云作者痴，
shuí jiě qí zhōng wèi　cóng gǔ dào jīn yǒu xǔ duō rén yán jiū
谁 解其中 味？”从古到今有许多人研 究
hóng lóu mèng　zhè qí zhōng de lì shǐ cāng sāng hé gè rén de suān tián
《红 楼 梦》，这其中 的历史 沧 桑 和个人的酸 甜
kǔ là　zhí dé màn man pǐn wèi
苦辣，值得慢慢品味。

ខ-លោកឆាវ ស៊ាឈីន បានធ្វើការវាយតម្លៃប៉ុន្មានម៉ាត់នៅក្នុងជំពូកទី ១ នៃរឿងសុបិនវិមានក្រហមថា“បើមើលតាមអត្ថបទដូចជារឿងដែលមិនគួរឱ្យជឿ តើអ្នកណាដឹងថាការពិតទាំងនេះ គឺជាការលំបាកពិតៗរបស់ខ្ញុំ ។ បើថាអ្នកនិពន្ធល្ងង់ តើអ្នកណាយល់ពីរសជាតិបែបនេះ ?” តាំងពីសម័យបុរាណរហូតមកដល់ឥឡូវនេះ មានអ្នកស្រាវជ្រាវពីរឿងសុបិនវិមានក្រហមជាច្រើន ហើយក្នុងនោះមានទាំងប្រវត្តិសាស្ត្រនិងជីវិតល្វីងជូរចត់ សក្តិសមនឹងការឱ្យតម្លៃខ្ពស់ ។

## 二、汉语知识

### ២-ចំណេះដឹងអំពីភាសាចិន

中国古典名著《红楼梦》

作者：曹雪芹（公元1715年—1763年）

ស្នាដៃអក្សរសាស្ត្របុរាណដ៏ល្បីឈ្មោះរបស់ប្រទេសចិន : “សុបិនវិមានក្រហម”

អ្នកនិពន្ធ : លោក ឆាវ ស៊ាឈីន (១៧១៥-១៧៦៣)

សេចក្តីសង្ខេប(ភាគទី ១) :

នៅក្រុងគូសូមាននិស្សិតក្រីក្រម្នាក់ឈ្មោះ ចាកអ៊ុឈុនគាត់បានទទួលការជ្រោមជ្រែងពីឆិនសឺអ៊ីងដែលធ្លាប់ធ្វើមន្ត្រីក្នុងរាជការ ហើយទៅរាជធានីប្រឡងធ្វើមន្ត្រីនិងបានសម្រេចដូចបំណង ។ ដោយសារគាត់ពុករលួយមិនដល់មួយឆ្នាំផងក៏ត្រូវបានធ្លាក់ពីតំណែងតែម្តង ។ គាត់បានទៅដល់យ៉ាងចូវ ធ្វើជាភ្ញៀវរបស់លីងយូហាយដែលជាមន្ត្រីគ្រប់គ្រងអំបិល រួចធ្វើជាគ្រូរបស់លីងតាយអ៊ីដែលជាកូនស្រីរបស់លីងយូហាយ ។ កន្លងទៅបានមួយឆ្នាំ ប្រពន្ធរបស់លីងយូហាយក៏ទទួលមរណភាព ចាកអ៊ុឈុនជូនដំណើរលីងតាយអ៊ីទៅដល់ទីក្រុងដល់សំណាក់យ៉ុងគួ ។ ដោយទទួលបានការជួយជ្រោមជ្រែងពីឪពុករបស់លីងតាយអ៊ីមិន បានពីរខែផងចាក អ៊ុឈុនក៏ទទួលបានការតែងតាំងឱ្យទៅកាន់តំណែងនៅសំណាក់អ៊ីងធានដូចដើមវិញ ។ បន្ទាប់ពីនោះ ក៏មានសំណាងល្អនិងឡើងឋានៈរហូត ។

នៅរាជធានី គ្រួសារត្រកូលចាកគឺជាគ្រួសារវណ្ណៈអភិជនដ៏លេចធ្លោដែលមានសំណាក់យ៉ុងគួនិងសំណាក់ណីងគួ ។ ក្រោយពីលីងតាយអ៊ីចូលទៅរស់នៅសំណាក់យ៉ុងគួគាត់ ក៏ទទួលបាននូវការស្រឡាញ់ពីជីដូនគាត់ហើយក៏ស្និទ្ធស្នាលគ្នាជាមួយបងជីដូនមួយចាកប៉ាវអ៊ី ពេលយប់រស់នៅជាមួយគ្នា ពេលថ្ងៃក៏លេងជាមួយគ្នាដែរ ។ មិនយូរប៉ុន្មានក៏ទទួលបានសំបុត្រពីក្រុងជីងលីងសរសេរថា កូនប្រុសរបស់ប្អូនស្រី(ឈ្មោះស៊ាក)អ្នកស្រីវ៉ាងដែលជាមីងរបស់លីងតាយអ៊ីបានវាយសម្លាប់មនុស្ស ហើយបានត្រូវចាប់ទៅសំណាក់អ៊ីងធាន ។ ប៉ុន្តែមិនបានប៉ុន្មានថ្ងៃផង លោកស្រីស៊ាកបាននាំកូនប្រុសនិងកូនស្រី(ស៊ាកប៉ាវឆាយ)មកសំណាក់យ៉ុងគួ ។ តាមពិតអ្នកទទួលខុសត្រូវសំណាក់អ៊ីងធានគឺចាក អ៊ុឈុនជាអ្នកកាត់ក្តី គាត់ឃើញគ្រួសារស៊ាកជាគ្រួសាររាជវង្សហើយមានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រួសារត្រកូលចាក ដូច្នេះ ក៏លែងកាត់ទោសជនល្មើសតែម្តង ។

ស៊ាកប៉ាវឆាយ មានអាយុច្រើនជាងចាកប៉ាវអ៊ី ហើយនាងមានសោមាសមួយ ដែលត្រូវគូជាមួយយក់ធុងលីងរបស់ចាកប៉ាវអ៊ី ពេលនាងទៅដល់សំណាក់ចាកភ្លាមក៏ទទួលបានការស្រឡាញ់ពីគេគ្រប់គ្នាភ្លាម ដែលខុសពីនាងតាយអ៊ីដែលមានអំនួតលើខ្លួនឯងពេក ។

ប៉ាវអ៊ីត្រូវបានបញ្ជូនទៅសាលារៀន ហើយឪពុកគាត់តឹងរឹងណាស់ គឺអនុញ្ញាតឱ្យទន្ទេញសូត្រតែប្រវត្តិសាស្ត្រប៉ុណ្ណោះ ។ គាត់ខ្លាចឪពុកដូចកណ្តុ



រឿងល្បីឈ្មោះ“តាយអ៊ីកប់ផ្កា”ក្នុងប្រលោមលោក“សុបិនវិមានក្រហម”
《红楼梦》“黛玉葬花”的经典片段　cnsphoto

ឃើញឆ្មារត់ពួនសង្ងំអ៊ីចឹង ចំណែកឯយាយប៉ាវអ៊ីស្រឡាញ់និងបណ្ដោយចៅនេះណាស់ ពោលគឺស្រឡាញ់ប៉ាវអ៊ីចាត់ទុកដូចបេះដូងខ្លួនឯងអ៊ីចឹង ។

មិនយូរប៉ុន្មាន លីងយូហាយធ្លាក់ខ្លួនមានជំងឺធ្ងន់ តាយអ៊ីត្រូវបានបញ្ជូនមកផ្ទះវិញ ហើយមិនយូរប៉ុន្មានទៀត កូនប្រសាស្រីរបស់ចាកចិន(ឈិនខឺឆីង)នៅសំណាក់ណីងគួក៏ស្លាប់ ។ មេការជាអ្នកស្រីតូច(វ៉ាងស៊ីហ្វុង)នៅសំណាក់យ៉ុងគួត្រូវបាន ហៅទៅមើលការខុសត្រូវនៅសំណាក់ណីងគួ ។ នៅថ្ងៃហែសព វ៉ាងស៊ីហ្វុងសម្រាកក្នុងអាស្រមនំប៉ាវ ដូនជីចំណាស់នៅក្នុងអាស្រមនំប៉ាវសូមអង្វរឱ្យវ៉ាងស៊ីហ្វុងធ្វើលិខិតលែងលះដើម្បីបោកប្រាស់ប្រាក់ពីគេ ៣០០០ តម្លឹង ។ វ៉ាងស៊ីហ្វុងចាត់ឱ្យគេទៅទំនាក់ទំនងនឹងមន្ត្រីជាន់ខ្ពស់នៅឆាងអាន ដើម្បីបំបែកអាពាហ៍ពិពាហ៍ដ៏រីករាយមួយដោយបានបំផ្លាញជីវិតមនុស្សពីរនាក់ ។

សំណាក់ណីងគួធ្វើពិធីបុណ្យសព្វចរាល់លីងតាយអ៊ីដោយសារឳពុកស្លាប់អស់អ្នកពឹងពាក់ ក៏វិលត្រឡប់ទៅសំណាក់ចាកវិញ ។ មិនយូរប៉ុន្មានកូនស្រីរបស់ចាកយ៉ានឈុន ដែលត្រូវបានរើសចូលវាំងត្រូវបានតែងតាំងជាអ្នកម្នាង ហើយស្ដេចក៏អនុញ្ញាតឱ្យគ្រួសារចាកសាងសង់សំណាក់សួរសុខទុក្ខឳពុកម្ដាយតែម្ដង ។ សំណាក់ចាកនៅចន្លោះសំណាក់ណីងគួនិងយ៉ុងគួ លាតសន្ធឹងជិតពីរគីឡូម៉ែត្រនៃផ្ទៃដី ហើយចាប់ផ្ដើមសាងសង់ចំណាយពេលអស់ជាងកន្លះឆ្នាំនិងចំណាយប្រាក់ជាច្រើន សម្រាប់ទិញសម្ភារៈទិញគ្រឿងតុបតែងនិងឧបករណ៍ផ្សេងៗអស់ប្រាក់ ៣ ម៉ឺន ។ នៅឆ្នាំបន្ទាប់ យ៉ានឈុនត្រឡប់មកសួរសុខទុក្ខឳពុកម្ដាយបានប្ដូរឈ្មោះសំណាក់សួរសុខទុក្ខឳពុកម្ដាយទៅជា"សួនទេសភាពធំ"និងបានប្ដូរឈ្មោះបន្ទប់ដទៃទៀតនៅក្នុងសួនថែមទាំងបានហៅប៉ាវអ៊ីនិងបងប្អូនឯទៀតចូលទៅនៅជាមួយគ្នាទៀតផង ។ ប៉ាវអ៊ីនៅសំណាក់ក្រហមតាយអ៊ីនៅសំណាក់សាវសាំងប៉ាវឆាយនៅសំណាក់ហឹងអ៊្វូ ចំណែកតានឈុនទៅនៅបណ្ណាល័យឈីវយ៉ាន...ប៉ាវអ៊ីនៅក្នុងសួនជួបជុំបងប្អូនស្រីរស់នៅយ៉ាងចុះសម្រុងគ្នាប្រកបដោយសុខដុមរមនា ។

(នៅមានត)



សំណាក់យ៉ុងគួនៅស្រុកជឹងទីងខេត្តហឺប៉ៃ
河北正定荣国府　cnsphoto

故事梗概（1）：

姑苏城有一名叫贾雨村的穷书生，他受乡宦甄士隐的资助，上京赴考，中了进士，做了官。只因他贪赃枉法，不到一年就被革了官职。他来到扬州，做了巡盐御史林如海的幕客，教授林女黛玉念书。过了一年，林如海的妻子贾氏去世，林黛玉由贾雨村护送，到了京都荣国府。贾雨村因此得到黛玉舅父贾政的帮助，不上两月，便复职选任金陵应天府，从此，官运亨通。

京都贾家是显赫的贵族，有荣国府、宁国府两座府邸。黛玉住进荣国府后，外祖母贾母疼爱她，与表兄贾宝玉相处得也十分亲密，晚上住在一起，白天也一道玩耍，过后不久，从金陵来了一封信，说黛玉舅母王夫人的同胞妹妹薛姨妈的儿子打死了人，应天府正在审理。但没过几天，薛姨妈却带着儿子和女儿薛宝钗进了荣国府。原来应天府知府是贾雨村，他见薛家是皇商，又与贾府有亲，便徇私枉法，不再追究凶手。

薛宝钗比贾宝玉年长一些，有一只能同宝玉的通灵玉配对的金锁。她到贾府后处处随分从时，不像黛玉孤僻自傲，很快就得到了贾府上下的喜欢。

宝玉被送到家塾读书。父亲贾政只准宝玉背诵文史经传，要求十分严格。宝玉惧怕父亲，常像老鼠见了猫一样躲避。贾母却非常娇惯这个孙子，把宝玉看作是自己的心肝。

不久，林如海身染重病，黛玉被送回了家。黛玉去后不久，宁国府贾珍的儿媳秦可卿死去。荣国府的管家少奶奶王熙凤被请去协助管理宁国府。在送殡的那天，王熙凤住在馒头庵，庵中老尼求王熙凤办理一件退婚案，为了图别人3000两银子，王熙凤派人去打通长安节度使的关节，竟活活拆散了一对美满姻缘，断送了两条人命。

宁府丧事办完之后，林黛玉因父亲去世，无所依靠，又被接回了贾府。不久，被选入宫的贾政之女贾元春被加封贤德妃，皇帝特许贾府建造省亲别院。于是贾府在荣、宁二府之间丈量出三里半的地面，开始修建省亲别院，历时半年多建成，耗费了大量银钱，单采买戏子和服装道具一项就花银3万。次年正月十五，元春回家省亲，赐省亲别院名为“大观园”，对园内房舍也赐了名称，并叫宝玉和众姐妹搬进大观园，宝玉住怡红院，黛玉住潇湘馆，宝钗住蘅芜院，探春住秋掩书斋……宝玉在园内同众姐妹、丫环相处，倒也自在。

（下期《红楼梦》故事梗概（2））


ស្នាមញញឹមអង្គរ
吴哥的微笑
ការវិលត្រលប់មកវិញនៃទេវ នៅក្នុងចម្លាក់
复活凝固在石块上的神话
ការសំដែងដ៏ធំលំដាប់ទីមួយនៅព្រះរាជាណាចក្រកម្ពុជា
柬埔寨第一大歌舞史诗表演
ពេលវេលាសំដែង: ១៩: ១៥—២០: ២៥ (សំដែងជារៀងរាល់ថ្ងៃ)
表演时间：19:15——20:25（天天上演）
地址：吴哥微笑大剧院（柬埔寨暹粒吴哥会展中心）
ទំនាក់ទំនង: ០៩៧ ៤៥១ ១៧១៧ ០៦៣ ៦៥៥ ០១៦៨
电话： 097 451 1717 063 6550168
គេហទំព័រ: www.smileofangkor.com
网址：www.smileofangkor.com
E-Mail: market@smileofangkor.com


彩雲之南 神秘之釀
国宾特供酒
釣魚臺国宾馆
Two hundred years ago,
French missionaries discovered this
unique highland for growing
excellent wine grapes.
云南红
YunnanRedWine
酒庄
MILE.YUNNAN.CHINA
全汁干型葡萄酒
ក្រេបសុរាហាមបើកបរ
云南红酒庄葡萄酒有限公司
Yunnan Red Chateau Co., Ltd
www.yunnanhong.com